ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jul-2013, 14:55
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី២០៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកកែន
*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក ឡា ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក សុន អរុណ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅថ្ងៃនេះតាមកាលវិភាគដែលបានគ្រោងទុក សវនាការដាក់ឯកសារគន្លឹះរបស់ភាគីនៅចំពោះមុខរបស់អង្គជំនុំជម្រះ ដោយការស្ដាប់ការកត់សម្គាល់ ឬអត្ថាធិប្បាយដោយក្រុមមេធាវីការពារក្ដីលោក នួន ជា លើបណ្ដាឯកសារគន្លឹះដែលបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ដោយសហព្រះរាជអាជ្ញា និងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅសវនាការកាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣។

ក្រឡាបញ្ជីសវនាការ លោក ដារ អានសាន ឡើងរាយាការណ៍អំពីស្ថានភាពវត្តមាន អវត្តមានបុគ្គលដែល -- និងភាគីដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបលោកប្រធាន នៅក្នុងសវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ លោក នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងដោយសារមូលហេតុសុខភាព។ លោកសហមេធាវីនាំមុខតំណាងជាតិ -- តំណាងដើមបណ្ដឹងរដ្ឋប្បវេណីលោក ពេជ អង្គ បានជូនដំណឹងមកថា លោកនឹងមកយឺត។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា អង្គជំនុំជម្រះសូមអញ្ជើញលោកមេធាវី អាកឡូវ វែកគែន ក្រោកឈរ!

[០៩:០៦:០៣]

នៅថ្ងៃព្រហស្បតិ៍ ទី០៤ ខែកក្កដា បន្ទាប់ពីយើងខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនោះ ហើយលោក អាកឡូវ វែកគែន ជាមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន បានស្រែកដោយកំហឹងមកចំពោះយើងខ្ញុំជាប្រធានអង្គជំនុំជម្រះ បន្ទាប់មកមេធាវី

រូបនេះនៅបន្តអង្គុយដោយមិនក្រោកឈរនៅពេលប្រធានអង្គជំនុំជម្រះ និងចៅក្រមផ្សេងទៀតនៃអង្គជំនុំជម្រះចាកចេញពីបន្ទប់សវនាការ។ អាកប្បកិរិយាបែបនេះ គឺជាអាកប្បកិរិយាមួយដែលធ្លាក់ចុះនៅក្រោមកម្រិតបទដ្ឋានស្តង់ដារនៃគោរព -- ការគោរពវិជ្ជាជីវៈដែលជាមេធាវីនានា ត្រូវប្រកាន់យកចំពោះមុខតុលាការនេះ ឬនៅឯតុលាការផ្សេងៗទៀត ទង្វើបែបនេះ គឺជាឧទាហរណ៍មិនល្អមួយចំពោះបណ្តាមេធាវីជំនាន់ក្រោយផ្សេងៗទៀត។

[០៩:០៦:៥៣]

លោកមេធាវីការពារក្តីរូបនេះ មានលក្ខណៈក្រអឺតក្រទម និងមានចរិតរំខានដល់កិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខសាក្សី សហសេវិក រួមវិជ្ជាជីវៈរបស់គាត់ ក៏ដូចជានៅចំពោះមុខសាធារណជន។ អង្គជំនុំជម្រះព្រមានដល់លោកមេធាវីរូបនេះ ស្របតាមវិធាន ៣៧(១) នៃវិធានផ្ទៃក្នុង។ អង្គុយចុះ!

**លោក អាកទូរ វែកកែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប--

**ប្រធានអង្គជំនុំ៖**

បានហើយៗ សូមអញ្ជើញអង្គុយចុះ!

**លោក អាកទូរ វែកកែន៖**

លោកប្រធានខ្ញុំយល់ថា ខ្ញុំគួរតែមានឱកាសក្នុងការនិយាយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការធ្វើអត្ថាធិប្បាយ ឬក៏កត់សម្គាល់លើបណ្តាឯកសារគន្លឹះ ដែលដាក់បង្ហាញដោយក្រុមសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:០៨:៣១]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

ពាក់ព័ន្ធទៅនឹងបញ្ជីឯកសារដែលក្រុម នួន ជា បានចែកជូនកាលពីយប់មិញ ខ្ញុំសូមធ្វើការ

ជំទាស់នៅពាក់កណ្តាលនៃកិច្ចដំណើរការនីតិវិធីនេះ។ ដោយសារបញ្ជីឯកសារ គឺបញ្ជីឯកសារនោះគឺប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ដែលហើយជាបទបង្ហាញរបស់ក្រុម នួន ជា ដែលព្យាយាមសូមធ្វើ ដែលក្រុមយើងខ្ញុំមិនបានធ្វើទេ ទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីនេះ។ ខ្ញុំមិនដឹងថាតើក្រុមគាត់មានចេតនាចង់បង្ហាញសក្ខីកម្មរបស់សាក្សីនោះ ប្រសិនណាវាគ្រាន់តែជាបរិបទមួយ ដូចសេចក្តីផ្តើមចំពោះឯកសារទាំងនោះ ប្រហែលជាយើងខ្ញុំនឹងមិនជំទាស់ទេ។ ប៉ុន្តែបើមានចេតនាចង់ប្រើកិច្ចដំណើរការនីតិវិធីបង្ហាញសក្ខីកម្មរបស់សាក្សី ខ្ញុំយល់ឃើញថា វាស្ថិតនៅក្នុងវិសាលភាពនៃកិច្ចដំណើរការនីតិវិធីដែលនិយាយអំពីការបង្ហាញឯកសារដែលជាមានលក្ខណៈពាក់ព័ន្ធនោះ។

កាលដែលខ្ញុំលើកបញ្ហានេះឡើងដោយសារមានឯកសារមួយចំនួននៅក្នុងបញ្ជីនេះ គឺថាវាមានលក្ខណៈសមស្របក្នុងការលើកធ្វើការជំទាស់នៅក្នុងពាក់កណ្តាលនៃកិច្ចដំណើរការនីតិវិធីនេះតែម្តង។ សូមអរគុណ។

[០៩:១០:០០]

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធានខ្ញុំសូមឆ្លើយតបដោយខ្លីទេ។ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៅក្នុងបញ្ជីឯកសាររបស់យើងខ្ញុំនេះ គឺវាគ្រាន់តែ ខ្ញុំគ្រាន់តែយកមកប្រើប្រាស់ដើម្បីបង្ហាញនូវបរិបទពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាងដោយសារវាផ្តល់នូវប្រវត្តិសាវតារចំពោះការជំទាស់តវ៉ារបស់យើងខ្ញុំ។ ដោយសារយើងខ្ញុំត្រូវការជជែកតវ៉ាទៅលើតម្លៃនៃភស្តុតាងនេះ មិនមែនជាការបង្ហាញបែបលក្ខណៈនៃការជំទាស់តវ៉ាបិទការសួរដេញដោលទេ គ្រាន់តែជាការបង្ហាញនូវបរិបទនេះតែប៉ុណ្ណោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកក្រុមមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សហភាតាទាំងអស់។ ថ្ងៃនេះយើងខ្ញុំនឹងផ្តល់ឲ្យ នួន ជា ធ្វើការឆ្លើយតបទៅនឹងបទបង្ហាញដែលសហព្រះរាជអាជ្ញាបាន និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង ដែលយើងបានស្តាប់ទាំងអស់គ្នាកាលពីសប្តាហ៍

មុន។ ដូចអង្គជំនុំជម្រះបានជ្រាបហើយ ការបង្ហាញឯកសារទាំងអស់ហ្នឹងពាក់ព័ន្ធទៅនឹងប្រធានបទយ៉ាងទូលំទូលាយ។ គឺយើងហៅថា ទី១ សហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងតួនាទីរបស់កូនក្ដីរបស់ខ្ញុំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយលោក សុន អរុណ ក៏ធ្វើការបង្ហាញទៅនឹងផ្នែកដដែលនេះដែរ ហើយក៏ធ្វើការបង្ហាញនៅព្រឹកថ្ងៃស្អែកផងដែរ។

[០៩:១២:១៧]

យើងខ្ញុំនឹងចាប់ផ្ដើមទៅលើការចោទប្រកាន់នូវគោលនយោបាយទាំងប្រាំ និងការពិភាក្សាជារួមទៅលើតួនាទីរបស់ នួន ជា។ យើងខ្ញុំបានប៉ាន់ប្រមាណថា ចម្លើយតបរបស់យើងខ្ញុំនឹងស៊ីពេលពេញ១ថ្ងៃនេះតែម្ដង។ សហភាតារបស់ខ្ញុំ សុន អរុណ នឹងនិយាយអំពីតួនាទីរបស់ នួន ជា យ៉ាងលម្អិតតែម្ដង។

លោក សុន អរុណ និងខ្ញុំមានយោបល់ខ្លះៗទាក់ទងទៅនឹងគុណភាពក៏ដូចយថាភាព ភាពឲ្យជឿជាក់បាននៃឯកសារដែលបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ ចុងក្រោយលោក នួន ជា ខ្លួនឯងផ្ទាល់នឹងប្រើពេលវេលាចុង ក្រោយដើម្បីធ្វើសេចក្ដីថ្លែងការណ៍។ យើងខ្ញុំស្មាន ប៉ាន់ប្រមាណថា យើងនឹងប្រើពេលនៅពាក់កណ្ដាលនៃព្រឹកថ្ងៃស្អែក។

ការដែលខ្ញុំលើកឡើងនេះ គឺវាចាំបាច់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះនេះតែម្ដង។ ដូចអង្គជំនុំជម្រះបានជ្រាបអំពីជំហររបស់ក្រុមយើងខ្ញុំហើយ យើងខ្ញុំបានលើកធ្វើការជំទាស់នៅក្នុងពេលដែលមានការបង្ហាញដោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ តាំងតែពីយើងខ្ញុំបានដាក់បណ្ដឹងសាទុក្ខទៅតុលាការកំពូល បណ្ដឹងសាទុក្ខដែលមានការកោសលុបនោះទៅតុលាការកំពូលដោយយោងទៅលើអ្វីដែលអង្គជំនុំជម្រះបានសម្រេចតាំងពីដើមទីមក។

[០៩:១៤:០០]

ការបំបែករបស់យើងពាក់ព័ន្ធទៅនឹងភស្ដុតាង ទាក់ទងទៅនឹងការចោទប្រកាន់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យនិងការអនុវត្តដែលតាមការយល់ឃើញរបស់យើងខ្ញុំមិនអាចទទួលយកបានទេ។ យើងខ្ញុំយល់ដឹងច្បាស់ហើយ សហព្រះរាជអាជ្ញាក៏ដូចមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើង*(ឮមិនច្បាស់)* ទាក់ទងនឹងការអនុវត្ត។ ហេតុដូច្នោះឯង វាស្ថិតនៅក្នុងផ្នែកផ្សេងៗ ដែលស្ថិតនៅក្រៅពីវិសាលភាព។ ជំហររបស់សហព្រះអាជ្ញា គឺថាមិនមែនចង់ធ្វើដូច្នេះទេ។ ហើយមានការបញ្ជាក់ច្បាស់ហើយទាក់ទងទៅនឹងបញ្ហានេះខ្ញុំសូមបង្ហាញជូនអង្គជំនុំជម្រះនូវប្រតិចារឹកនៅថ្ងៃទី២៦ មិថុនា នៅម៉ោង ២០:២២ ដែលជាការជំទាស់តវ៉ាដដែលនេះឯង។ យើងខ្ញុំមានការជំទាស់យ៉ាងខ្លាំង

ជាពិសេសទាក់ទងទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបាននូវការជំនុំជម្រះដែលគឺថាយើងយល់ឃើញថាតម្លៃនៃភស្តុតាងទាំងអស់នេះគឺថាសូន្យតែម្តង។

[០៩:១៥:១៥]

នៅថ្ងៃទី២៦ មិថុនា អង្គជំនុំជម្រះបានជំទាស់ទៅនឹង -- ច្រានចោលការជំទាស់របស់យើងក្នុងការបង្ហាញនូវឯកសារទាំងអស់នេះ។ ហើយអង្គជំនុំជម្រះបានលើកឡើងថា យើងមានឱកាសក្នុងការដាក់នូវសារណានេះទាក់ទងទៅនឹងតម្លៃនៃភស្តុតាងដែលជាការឆ្លើយតបរបស់យើង។ ហើយវាមានហេតុផលពីរ៖ ទី១ អង្គជំនុំជម្រះបានសម្រេចហើយគឺយើងមិនមានសិទ្ធិក្នុងការធ្វើការជំទាស់ទាក់ទងទៅនឹងភាពទទួលយកបាននៅក្នុងសវនាការនេះទេ។ ភាពពាក់ព័ន្ធគឺបញ្ហាទាក់ទងទៅនឹងភាពអាចទទួលយកបាន។ ខ្ញុំមានអារម្មណ៍គិតឃើញថាអង្គជំនុំជម្រះគឺនឹងសម្រេចនៅពេលថ្មីៗ និងអនុញ្ញាតឲ្យបង្ហាញនូវចំពោះការបង្ហាញនូវភាពពាក់ព័ន្ធ ដែលការបង្ហាញភស្តុតាងនេះ ឯកសារពាក់ព័ន្ធទៅនឹងភស្តុតាងនេះគឺមានលក្ខណៈចំបាច់សម្រាប់តម្លៃនៃភស្តុតាង។ ហើយទាំងអស់នេះ គឺជាឯកសារដែលអង្គជំនុំជម្រះត្រូវយកមកសម្រេច ហើយវាមានលក្ខណៈចាំបាច់បំផុតចំពោះឯកសារទាំងអស់នេះ ដែលមានន័យថាតាមការយល់ឃើញរបស់យើងខ្ញុំ គឺថាត្រូវតែចាប់ផ្តើមធ្វើការបង្ហាញឯកសារទាំងអស់នេះ។

[០៩:១៦:២៦]

ទី២ លោកប្រធាន! ភាពពាក់ព័ន្ធនេះគឺវាមិនជាបញ្ហាអីទេ។ ភស្តុតាងដែលសហព្រះរាជអាជ្ញាបានបង្ហាញនេះគឺថាមិនអាចទទួលយកបានទេ ព្រោះដោយសារថាវាមិនភាពពាក់ព័ន្ធ។ វាមិនអាចទទួលយកបានដោយសារអង្គជំនុំជម្រះបានច្រានចោលនូវក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីទៅហើយ គឺថាមានលក្ខណៈខុសគ្នាពីរ។ កាលពីសប្តាហ៍មុន សហព្រះរាជអាជ្ញាបានជំទាស់តវ៉ាភស្តុតាងទៅលើ គឺថាមានលក្ខណៈស្ថិតនៅក្រោមបទដ្ឋានមួយ ដែលបង្ហាញឲ្យឃើញថា គោលនយោបាយនេះគឺមានភាពពាក់ព័ន្ធ គឺថាតាមការពិត គឺវាពាក់ព័ន្ធទៅនឹងគោលនយោបាយទៅនឹង ទាក់ទងទៅនឹងទាហាននៃរបបលន់នល់ ដែលថាគោលនយោបាយទាំងអស់នេះ នួន ជា ខ្លួនឯងថាមិនមានគោលនយោបាយបែបនេះនោះទេ។ ប៉ុន្តែអង្គជំនុំជម្រះបានលើកឡើងដដែល ដែលថាវាការអនុវត្តទទួលយកភស្តុតាងវាស្ថិតនៅក្នុងក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ ពីសក្ខីកម្មដែលបានទទួលដោយផ្ទាល់នេះ។ អង្គជំនុំជម្រះបានកោះហៅសាក្សី អង្គជំនុំជម្រះបានហាមឃាត់ភាគីមិនឲ្យសួរទៅសាក្សី លើកលែងតែអ្នកជំនាញ ឬក៏រចនាសម្ព័ន្ធដែលពាក់ព័ន្ធ។

ក្នុងការសំណើសុំរបស់យើងខ្ញុំ អង្គជំនុំជម្រះប្រហែលជាមិនអាចអនុវត្តនូវបទដ្ឋានតឹងរ៉ឹងចំពោះការទទួលយកនូវភស្តុតាងរស់ទាំងអស់នេះបានទេ។

[០៩:១៧:៤៩]

ហើយទី២ គឺវាមានបទដ្ឋានដ៏ទូលំទូលាយក្នុងការទទួលយកភស្តុតាងឯកសារនៅក្នុងការពិចារណាថាតើឯកសារនេះ ភស្តុតាងអាចត្រូវបានយកមកពិចារណា ដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ឬក៏អត់នោះ។ ហេតុដូច្នេះយើងត្រូវតែស្នើសុំលើកឡើងនូវសំណួរដូចខាងក្រោម៖

តើបញ្ហាអំពីភស្តុតាងត្រូវបានអនុញ្ញាតនៅក្នុងការផ្តល់សក្ខីកម្មដោយផ្ទាល់ចំពោះមុខនេះបានទេ ប្រសិនបើចម្លើយថាអត់ទេ ឯកសារនេះត្រូវតែកត់ត្រាថាវាមានទម្ងន់សូន្យតែម្តងដោយអង្គជំនុំជម្រះ។ ហើយវាមានលក្ខណៈ -- សុំឱ្យអង្គជំនុំជម្រះគាត់ធ្វើការបញ្ជាក់ផងដែរចំពោះអ្វីដែលបង្ហាញឡើងដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងអ្វីដែលយើងបានជំទាស់ដោយហេតុផលទាំងអស់នេះ។

លោកប្រធាន! នេះគឺជាការជំទាស់តាមផ្លូវគតិយុត្តរបស់យើងខ្ញុំ ទាក់ទងទៅនឹងការអនុវត្តភស្តុតាង។ នេះគឺជាមូលហេតុផ្លូវច្បាប់ដែលថាភស្តុតាងនោះមិនអាចទទួលបានទេ។ ប៉ុន្តែនៅខាងក្រោមនៃបញ្ហានៃផ្លូវច្បាប់នេះ គឺថាវាមានការចាក់ឫសយ៉ាងជ្រៅចំពោះអង្គហេតុនៃរឿងក្តីនេះ។ គឺថាវាមានលក្ខណៈជាសារវន្តទាក់ទងទៅនឹងការចោទប្រកាន់ប្រឆាំងមកកូនក្តីរបស់យើងខ្ញុំ គឺសិទ្ធិជាមូលដ្ឋានរបស់ នួន ជា ប្រឆាំងទៅនឹងការចោទប្រកាន់ទាំងអស់នេះ។ ហើយវាក៏ជាមានលក្ខណៈជាមូលដ្ឋានចំពោះសវនាការនេះដែលត្រូវគិតអំពីចរិតលក្ខណៈនៃការទទួលខុសត្រូវរបស់ នួន ជា នូវអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:១៩:៣០]

លោកប្រធាន លោក លោកស្រីចៅក្រម ដូចអង្គជំនុំជម្រះបានជ្រាបហើយ នួន ជា មិនបានបដិសេធអំពីឧត្តមភាពនៃតួនាទីរបស់ក្នុងកម្ពុជាប្រជាធិបតេយ្យទេ ហើយគាត់ក៏មិនបដិសេធនូវអ្វីដែលគាត់ពាក់ព័ន្ធក្នុងការចូលរួមទាក់តែងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ។ ប៉ុន្តែគាត់បានបដិសេធថា គោលនយោបាយទាំងអស់នេះ គឺមិនមានចេតនាដើម្បីឱ្យមានបទល្មើសទាំងអស់នេះកើតឡើងនោះទេ។ គឺដូច នួន ជា បានអះអាងថាហើយ បើសិនណាជាកម្មាភិបាលថ្នាក់ក្រោមប្រព្រឹត្តឧក្រិដ្ឋកម្មណានោះ គឺគេប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះដោយជំទាស់ទៅនឹងបញ្ជារបស់មជ្ឈិមបក្ស។ យើងខ្ញុំសូម

លើកឡើងថា ភស្តុតាងនេះគឺគាំទ្រទៅដល់តួនាទីរបស់ នួន ជា។ ភស្តុតាងបង្ហាញយ៉ាងច្បាស់ហើយថា អំពើព្រហ្មទណ្ឌនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានប្រព្រឹត្តដោយកម្មាភិបាលមូលដ្ឋាន ដែលគេប្រព្រឹត្តដោយខ្លួនឯង ដោយគ្មានការណែនាំណាមួយនោះឡើយ។ ភស្តុតាងក៏បានបង្ហាញយ៉ាងច្បាស់ថាទង្វើព្រហ្មទណ្ឌនេះគឺថាត្រូវបានកើតឡើងនៅទូទាំងប្រទេសកម្ពុជា ហើយវាអាស្រ័យទៅលើមេដឹកនាំថ្នាក់មូលដ្ឋានតែម្តង។ ហេតុដូច្នេះឯងបានជាយើងសូមលើកឡើងម្តងហើយម្តងទៀត ថាគោលនយោបាយនេះស្ថិតនៅខាងក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។

[០៩:២០:៤៩]

អង្គជំនុំជម្រះគួរពិចារណាថាមិនមានការអនុវត្តនូវភស្តុតាងបែបនេះទេ។ អង្គជំនុំជម្រះគឺថាធ្វើការសន្និដ្ឋានយ៉ាងច្បាស់លាស់ ដែលថាឱកាស យើងត្រូវផ្តល់ឱកាសឲ្យយើងគ្រប់គ្រាន់ក្នុងការបង្ហាញអំពីអង្គហេតុទៅលើមូលដ្ឋាននៅក្នុងសហករណ៍ ក៏ដូចជាមន្ទីរសន្តិសុខដែលកើតចេញអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

ចំពោះហេតុផលនេះ យើងខ្ញុំស្នើសុំឲ្យធ្វើការវាយតម្លៃភស្តុតាងដែលបានដាក់នៅចំពោះមុខអស់លោក លោកស្រីចៅក្រម ដោយមានការសម្រេចយ៉ាងយកចិត្តទុកបំផុត។ ប្រសិនបើយើងផ្តោតការយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ទៅលើអ្វី ដែលថាបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមិនមានចេតនាប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងអស់នេះទេ។ បក្សកុម្មុយនីស្តកម្ពុជាមានបំណងអនុវត្តនូវបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

[០៩:២១:៤៥]

យើងខ្ញុំសូមដកស្រង់នូវអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺឯកសារ E284/4/3 ដែលជាចម្លើយតបសហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់យើង ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីម្តងទៀត។

សហព្រះរាជអាជ្ញាបានលើកឡើងថា សូមដកស្រង់ -- សហព្រះរាជអាជ្ញាសូមលើកឡើង -- "នេះគឺជាសវនាការនយោបាយដែលជនជាប់ចោទកំពុងតែត្រូវបានចោទប្រកាន់ ថាបាន -- ដែលពួកគឺជាជនកុម្មុយនីស្ត ជាអ្នកសង្គមនិយម និងជាជនបដិវត្តន៍"។

លោកប្រធានយើងខ្ញុំសូមលើកឡើងថា ការបង្ហាញរបស់សហព្រះរាជអាជ្ញាបង្ហាញថា វាជាការ

មិនត្រឹមត្រូវទេ ជាការភូតកុហកទេ។ ឯកសារនីមួយៗក្នុងការបង្ហាញរបស់ខ្លួន គឺពិតជាពាក់ព័ន្ធទៅនឹងគោលនយោយអំពីគោលបំណងនយោបាយទូទៅរបស់បដិវត្តន៍។ មិនមានឯកសារណាមួយដែលបានណែនាំហ្នឹង គឺថាសទ្ធត ឬក៏មានចេតនាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ។

[០៩:២៣:០២]

ទាក់ទៅនឹងគោលនយោបាយទាំងប្រាំនេះ យើងខ្ញុំបង្ហាញថាឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញា គឺថាមានការខកខានជាទូទៅតែម្តង ជាប្រព័ន្ធតែម្តង ក្នុងការបង្ហាញអំពីចេតនាព្រហ្មទណ្ឌទៅលើមជ្ឈិមបក្សនោះ។ យើងនឹងស្នើសុំឲ្យអង្គជំនុំជម្រះរំឭកឡើងវិញនូវការបង្ហាញរបស់សហព្រះរាជអាជ្ញាដែលបញ្ជាក់ទៅលើឯកសារទាំងអស់នោះ ហើយវាក៏វាមានការទាក់ទាញផងដែរថា មជ្ឈិមបក្សនោះមិនមានចេតនាឲ្យប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ។ ហើយទាក់ទងទៅនឹងគោលនយោបាយពីរ ដែលស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះ យើងខ្ញុំធ្វើការបង្ហាញជាបឋមថា ភស្តុតាងនៅចំពោះមុខនេះគឺវាស៊ីសង្វាក់គ្នាទៅនឹងតួនាទីរបស់ នួន ជា ដែលថាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនេះ ប្រព្រឹត្តទៅតាមសហកាលប្រព្រឹត្តិមិនស៊ីសង្វាក់គ្នា ហើយប្រព្រឹត្តិឡើងដោយកម្មាភិបាលមូលដ្ឋានតែប៉ុណ្ណោះ។

លោកប្រធាន ឥឡូវនេះខ្ញុំសូមចូលទៅនឹងការបង្ហាញភស្តុតាង ក៏ដូចដែលសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញផងដែរ។ សូមអនុញ្ញាតឲ្យខ្ញុំធ្វើការផ្តល់មតិទូទៅទាក់ទងទៅនឹងឯកសារគន្លឹះដែលសហព្រះរាជអាជ្ញាបានបង្ហាញជូន។

[០៩:២៤:១៨]

យើងខ្ញុំចង់បង្ហាញជាពិសេសទាក់ទងទៅនឹងការបង្ហាញប្រភពទី២ ដោយសហព្រះរាជអាជ្ញា គឺសៀវភៅដែលសរសេរឡើងដោយដូចជា ប៉ែន យៀវនិន, ហ្វីលីព ស្បត ជាដើម។ សៀវភៅទាំងអស់នេះត្រូវបានសរសេរដោយអ្នកសិក្សាស្រាវជ្រាវ ដែលបានប្រមូលភស្តុតាងក្រោយពីចុងបញ្ចប់នៃរបបនេះ។ ពួកគេបានពិនិត្យមើលទៅលើឯកសារទាំងអស់នេះ និងសម្ភាសសាក្សីមួយចំនួន ហើយករណីនៅក្នុងរបស់ ហ្វីលីព ស្បត គឺថាចាប់ផ្តើមធ្វើការស្រាវជ្រាវ២០ឆ្នាំ ក្រោយពីរបបនេះដួលបញ្ចប់ទៅ។ លោកស្បត មិនចេះនិយាយ ឬក៏សរសេរខ្មែរនោះទេ។

ប្រសិនណាអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំនិយាយក្នុងនាមជាមេធាវី មិនមែនគ្រាន់តែក្នុងនាមឲ្យលោក នួន ជា នោះទេ គឺថានិយាយក្នុងនាមវិជ្ជាជីវៈតែម្តង ខ្ញុំឃើញថាការអនុវត្តនេះគឺៗឲ្យ គឺអាចឲ្យជំទាស់បាន។ នេះជាមធ្យោបាយមួយដែលដែលកំពុងតែចាត់ចែងនៅក្នុងសវនាការនេះ។ ហើយបង្ហាញ

ថាបុគ្គលរូបនេះ គឺមិនមានពិរុទ្ធភាពនោះទេ។ ខ្ញុំចង់រំឭកដល់អង្គជំនុំជម្រះផងដែរថា ការបង្ហាញរបស់សហព្រះរាជអាជ្ញាគឺវាជាការបង្ហាញនូវឯកសារគន្លឹះ។ ចំណុចស្នូលនៃរឿងក្ដីនេះ ដែលលោក នួន ជា និង ខៀវ សំផន ត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ខ្ញុំមិនមានម៉ែយថា ការវិភាគរបស់អ្នកជំនាញគឺមានសារប្រយោជន៍ ហើយគោលបំណងខ្លះមិនមានសារប្រយោជន៍នោះទេ។ អង្គជំនុំជម្រះកាលពីមុននោះគឺថាក៏បានយកឯកសាររបស់អ្នកជំនាញយក អេវ៉ាតាបូ – បណ្ឌិត អេវ៉ាតាបូ – ទាក់ទងទៅនឹងៗកម្ពុជានៅក្នុងឆ្នាំទសវត្សរ៍១៩៧០។ ហើយខ្ញុំយល់ឃើញថាយ៉ាងហោចណាស់នេះ គឺថាវាជាយោបល់របស់អ្នកជំនាញ ប៉ុន្តែវាស្ថិតនៅខាងក្រៅសមត្ថភាពរបស់អង្គជំនុំជម្រះតែម្ដង។

[០៩:២៦:២៦]

សម្រង់ចេញពីសៀវភៅរបស់ ហ្វីលីព ស្សត និង ប៊ែន ឃៀរនិន ដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់ថាវាជាអង្គហេតុអំពីអ្វីៗដែលគិតថា បានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការអះអាងខ្លះគឺវាពាក់ព័ន្ធទៅនឹងទង្វើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ អនុវត្តទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ភស្តុតាងនៃទង្វើ ហើយនិងការប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងចម្លើយរបស់សាក្សីគឺមិនអាចទទួលយកបានទេ។ នេះគឺជាកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីដែលត្រូវបានស្បថ។

ផ្ទុយទៅវិញគឺថា គឺនៅក្នុងប្រទេសកម្ពុជាយើង គឺគេបានចំណុចខ្លះគេបានលើកឡើងចំពោះបញ្ហា នួន ជា និង ខៀវ សំផន។ នេះគឺជាអ្វីដែលគេបានសរសេរនៅក្នុងឯកសារទាក់ទងទៅនឹងវិទ្យាសាស្ត្រនយោបាយ ថ្នាក់បង្រៀនផ្នែកវិទ្យាសាស្ត្រនយោបាយនៅក្នុងសាកលវិទ្យាល័យ។ ប៉ុន្តែ នេះមិនមែនជាប្រភេទនៃឯកសារដែលត្រូវមកប្រើប្រាស់ ដែលត្រូវរកឃើញឲ្យឃើញពិរុទ្ធភាពឲ្យលើសពីវិមតិសង្ស័យនោះទេ។

[០៩:២៧:៣៥]

សហព្រះរាជអាជ្ញាគឺថាបានសំអាងយ៉ាងខ្លាំងទៅលើសៀវភៅរបស់ ថេត សម្បត្តិ។ ជាក់ស្ដែងសៀវភៅរបស់ ថេត សម្បត្តិ នេះគឺវាខុសពី ហ្វីលីព ស្សត ហើយនិង ប៊ែន ឃៀរនិន។ ហើយ ថេត សម្បត្តិ អះអាងថាបញ្ហាដែលខ្លួនរៀបរាប់នេះ គឺថាត្រូវបាន នួន ជា ប្រាប់ខ្លួន។ ប៉ុន្តែគួរក៏ចាំផងដែរថា វាមានទម្ងន់តិចតួចបំផុត។

ហើយចំណុចមួយទៀតគឺថា ចំណុចមានការអះអាងទៅនឹងការជម្លៀសប្រជាជនទៅចេញពីក្រុងភ្នំពេញ។ ដូចដែលបង្ហាញហើយគឺថាគាត់ជាមេឃុំ គ្មានការទាក់ទងអ្វីជាមួយនឹងមេដឹកនាំជាន់ខ្ពស់

របស់កម្ពុជាប្រជាធិបតេយ្យទេ។

សហព្រះរាជអាជ្ញាក៏បានយោងទៅលើឯកសាររបស់ ថេត សម្បត្តិ ហ្នឹង បានយោងយ៉ាងខ្លាំងតែម្ដង ហើយបានយកមកពិភាក្សាយ៉ាងវែងអន្លាយ។ ដែលថា -- ហើយមួយទៀតសៀវភៅរបស់ ថេត សម្បត្តិ វាខុសពី ហ្វីលីព ស្បូត ឬក៏ ប៉ែន ឃៀរនិន។

[០៩:២៨:៣៦]

ថេត សម្បត្តិ អះអាងថា ការរៀបរាប់រឿងរ៉ាវទាំងអស់នេះគឺជាការរៀបរាប់ដោយ នួន ជា។ ប៉ុន្តែសៀវភៅនេះផងដែរ គឺថាអាចមានទម្ងន់តិចតួចបំផុតនៅចំពោះអង្គជំនុំជម្រះហ្នឹង។ ថេត សម្បត្តិ និយាយថាសៀវភៅរបស់គាត់ហ្នឹង គឺយោងទៅលើកិច្ចសម្ភាសន៍ចម្រុះជាមួយនឹង នួន ជា ដែលជាប្រតិចារឹកបានផ្ដល់ទៅឲ្យ នួន ជា -- ថេត សម្បត្តិ ដោយ នួន ជា។ ហើយ ថេត សម្បត្តិ ធ្វើសេចក្ដីសន្និដ្ឋានដោយខ្លួនឯងតែម្ដង។

ប៉ុន្តែនៅក្នុងសម្រង់ភាគច្រើនដែលបានដកស្រង់សហព្រះរាជអាជ្ញា គឺថាមិនអាចយកមកពិចារណាថាតើប្រភពណាមួយក្នុងប្រភពទាំងអស់នេះ បង្កើតបានទៅជាមូលដ្ឋានសម្រាប់សេចក្ដីថ្លែងរបស់ ថេត សម្បត្តិ នោះ។ មិនមានកិច្ចសម្ភាសន៍ដើមរបស់ណាមួយបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ មិនមានប្រតិចារឹកណាមួយរបស់ នួន ជា ដែលផ្ដល់ទៅឲ្យ ថេត សម្បត្តិ នោះគឺថាមាននៅសំណុំរឿង។ ប៉ុន្តែអង្គជំនុំជម្រះបានស្នើសុំឲ្យសហព្រះរាជអាជ្ញាយោងទៅលើសេចក្ដីសង្ខេបរួមនៅក្នុងទស្សនាវដ្ដី វ៉លស្ត្រេត ដែលរាយការណ៍ដោយអ្នកកាសែតនេះ ហើយនិង ថេត សម្បត្តិ ហើយនិងប្រវត្តិសាវតារនៃឯកសារទាំងអស់នេះ។

[០៩:២៩:៤៧]

ប្រសិនជាអង្គជំនុំជម្រះជឿថា ថេត សម្បត្តិ គឺថាមានភស្តុតាងនៅក្នុងដៃរបស់គាត់ជារឿងសំខាន់នោះ មេធាវីក្រុម នួន ជា ស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅ ថេត សម្បត្តិ។ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅគាត់ពីរដងរួចមកហើយ។ អង្គជំនុំជម្រះបានសម្រេចថាសក្ខីកម្មរបស់គាត់មិនចាំបាច់ដើម្បីមកបង្ហាញនៅចំពោះក្នុងសវនាការនេះទេ។ ហើយគឺយើងចង់ឲ្យបង្ហាញចំពោះការដែលគាត់ធ្វើការដាក់ពិរុទ្ធភាពមកលើ នួន ជា។

លោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមយោងចូលទៅលើគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលសហព្រះរាជអាជ្ញាបានអះអាង។ ខ្ញុំសូមដកស្រង់ថា សូមដកស្រង់៖ "ការ

កម្ចាត់ តាមរយៈការប្រើប្រាស់អំពើហិង្សា ហើយនិងការ -- ខ្មាំងដែលគេ -- អ្នកដែលគេចាត់ទុកថាជាខ្មាំង"។ ខ្ញុំនឹងពិភាក្សាឯកសាររបស់សហព្រះរាជអាជ្ញាម្តងមួយៗ យើងនឹងមិនពិភាក្សាឯកសារទាំងអស់នេះទេ ប៉ុន្តែយើងនឹងពិភាក្សាឯកសារភាគច្រើន។ ការពិភាក្សារបស់យើងខ្ញុំនឹងបង្ហាញថាឯកសារទាំងអស់នេះ គឺវាស៊ីសង្វាក់គ្នាទៅនឹងការចោទប្រកាន់ជាយូរយារណាស់មកហើយទៅលើតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:៣១:០៩]

យើងខ្ញុំបង្ហាញថាឯកសារទាំងអស់នេះ វានឹងបញ្ជាក់ -- មិនបញ្ជាក់នូវផែនការ ឬចេតនាណាមួយដែលនឹងប្រព្រឹត្តនៅឧក្រិដ្ឋកម្មនោះទេ។ យើងនឹងបង្ហាញថា ភាសាដែលសហព្រះរាជអាជ្ញាបានយកមកប្រើប្រាស់នេះ គឺថាមិនមែនជាសេចក្តីណែនាំដោយជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការវាយប្រហារទៅលើប្រជាជន ប៉ុន្តែជាការជំទាស់ខាងផ្នែកនយោបាយប្រឆាំងទៅនឹងប្រព័ន្ធនៃការជំទាស់ ដោយការប្រើកម្លាំង។ យើងខ្ញុំនឹងបង្ហាញថាឯកសារទាំងអស់នេះអំពីគោលបំណងនៃនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា។

ឯកសារមួយនៅក្នុងឯកសារពីរខាងដើមដែលសហព្រះរាជអាជ្ញាបង្ហាញ គឺជាសម្រង់ដែលដកស្រង់ចេញពីសៀវភៅរបស់ ហ្វីលីព ស្សូត និង ថេត សម្បត្តិ ដូចដែលខ្ញុំទើបតែលើកឡើង។ ឯកសារទាំងពីរនេះគឺមាន E3/9 និង E3/152.2។ ឯកសារទាំងពីរប្រហែលជាមិនមែនជាឯកសារដ៏សំខាន់ដែលបង្ហាញដោយសហព្រះរាជអាជ្ញាដែរ ក៏ប៉ុន្តែការប្រើប្រាស់ដោយសហព្រះរាជអាជ្ញាគឺដើម្បីទាមទារឲ្យប្រើប្រាស់ឯកសារនេះតែម្តង។

[០៩:៣២:២៨]

សហព្រះរាជអាជ្ញាបានលើកឡើងថា សៀវភៅដែលរៀបរាប់អំពីដែលថា គឺគេហៅថា "បក្សកុម្មុយនីស្តកម្ពុជា" អានសម្រាប់យុវជន យុវនារីនៅក្នុងទសវត្សរ៍១៩៤០។ ព្រះរាជអាជ្ញាក៏បានស្នើសុំឲ្យបង្ហាញជូននូវមូលដ្ឋានអ្វីដែលបានកើតឡើងចន្លោះពី៧៥ ទៅ ៧៩ ដោយការបង្ហាញនូវសៀវភៅដែលកូនសិស្ស ដែលកំពុងតែអានជាង៣០ឆ្នាំមុន។ សៀវភៅដែលប្រជាជនរាប់រយលានអានមួយឆ្នាំៗ។ សៀវភៅដែលនិយាយអំពីមនោគមន៍វិជ្ជានយោបាយ។ ភស្តុតាងនេះលោកប្រធាន គឺថាវាជាផ្នែកមួយនៃការខិតខំប្រឹងប្រែងរបស់សហព្រះរាជអាជ្ញា ដើម្បីបង្ហាញដោយមិនច្បាស់លាស់ ដែលទាក់ -- ជាដំណើររឿងមួយមានលក្ខណៈទាក់ទង ហើយដែលថាត្រូវបានយកមកប្រើប្រាស់ ដើម្បីបំផ្លិចបំផ្លាញ

ប្រទេសជាតិនេះ ប៉ុន្តែរឿងនេះគឺជារឿងមួយដែលស្មុគស្មាញណាស់។ ដូច្នេះភស្តុតាងរបស់ ស្បូត និង សម្បត្តិ នេះគឺថាវាមានតម្លៃភស្តុតាងសូន្យតែម្តង ទាក់ទងទៅនឹងការពិចារណានៅក្នុងសវនាការនេះ។

[០៩:៣៣:៤០]

ភស្តុតាងនេះក៏អាចនឹងជំទាស់បានផងដែរ ដោយសារថាភស្តុតាងអះអាងថា អ្នកពិន្ទជាពិសេស លោក ហ្វីលីព ស្បូត មានការពាក់ព័ន្ធទៅនឹងការអះអាងទាំង ហ្វីលីព ស្បូត គឺគ្រប់គ្រាន់ហើយក្នុងការ លាក់កំបាំងនូវអ្វីដែលបានកើតឡើងនៅពេលក្រោយមកទៀតនេះ។ គាត់បានអះអាងថា វាជាសម្រង់ វាជាទស្សនៈ វាការរៀនសូត្រនូវទស្សនទានរបស់ម៉ាក្ស-ស្តាលីន វាគឺជាការគិតគូរចំពោះអនាគតបដិវត្តន៍ ហើយការអះអាងត្រូវបានលើកឡើងជាង៣០ឆ្នាំហើយ ដោយបុគ្គលដែលមិនមានប្រវត្តិនយោបាយ និង វប្បធម៌របស់កម្ពុជាអីបន្តិចសោះ។ ដែលគេយក គេហៅថា យកមកធ្វើការរៀបរាប់ដើម្បីឱ្យមានការប្រទូសរ៉ាយដូចគ្នា វាមិនមានតម្លៃនៃភស្តុតាងអ្វីតែម្តង។ អ្វីដែល -- នេះគឺជាអ្វីដែលលោកហ្វីលីព ស្បូត បានធ្វើ។ ដូច្នេះអង្គជំនុំជម្រះគួរតែពិចារណាក្នុងការវាយតម្លៃទៅលើភស្តុតាងទាំងអស់នេះក្នុងលក្ខណៈទូទៅតែម្តង។

[០៩:៣៤:៥៥]

ឯកសារបន្ទាប់ដែលសហព្រះរាជអាជ្ញាបង្ហាញនៅខែកញ្ញា ឆ្នាំ១៩៧២ គឺឯកសារទង់បដិវត្ត ឯកសារ E3/11។ ហើយខ្ញុំសូមបញ្ជាក់ជាទូទៅថា ឯកសារនេះជាឯកសារទី១។ នេះអាចនឹងបង្ហាញម្តងហើយម្តងទៀត នៅពេលដែលយើងមើលឯកសារនេះរហូតមកដល់ពេលនេះ។ ខ្ញុំសូមជម្រាបថា -- លោកប្រធាន យើងត្រឡប់ទៅមើលកាលវិភាគរបស់សហព្រះរាជអាជ្ញាលើឯកសារទាំងនេះ ហើយប្រៀបធៀបទៅនឹងឯកសារខ្លួនឯងនោះ ហើយខ្ញុំសូមជម្រាបថា គឺវាមានភាពមិនត្រឹមត្រូវទេ។ ហើយយើងសូមជម្រាបថា សហព្រះរាជអាជ្ញា -- ខ្ញុំប្រើពាក្យនេះ ដោយប្រុងប្រយ័ត្ន -- សហព្រះរាជអាជ្ញាបានប្រើពាក្យដោយបំផ្លើសពាក្យនេះ ហើយជ្រើសរើស គាត់បានផ្តោះចោលនូវផ្នែកខ្លះដែលគាត់ថាមិនមានសារប្រយោជន៍សម្រាប់គាត់។ ហើយពួកគាត់មិនបានប្រឹងប្រែងជូនអង្គជំនុំជម្រះអំពីភាពត្រឹមត្រូវ ហើយនិងភាពស្មោះត្រង់នៃឯកសារនេះនោះឡើយ។ នេះគឺជាទម្រង់ប្រព័ន្ធស៊ីវិលឡ ក៏ប៉ុន្តែត្រូវតែមានកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ដើម្បីពិនិត្យមើលដោយខ្លួនឯងនោះដែរ គឺមិនគ្រាន់តែខ្លួនគ្រាន់តែចង់ឱ្យឈ្នះរឿងក្តីរបស់ខ្លួនប៉ុណ្ណោះជាជាងការប្រើតុលាការ។

ជាពិសេសទាក់ទងទៅនឹងទង់បដិវត្តទាំងអស់នេះ អ្វីដែលគាត់និយាយ គឺគាត់បានជ្រើសរើស

មួយចំនួនតូច ហើយចោលផ្នែកមួយ គឺចង់ឲ្យវិធីមួយ គឺថាគាត់មិនបានប្រើអត្ថន័យត្រឹមត្រូវរបស់ទង់បដិវត្តនោះទេ។ នេះជាស្ថានភាពមួយដ៏អកុសល។ យើងសូមអនុញ្ញាតពិនិត្យមើលឯកសារទី១ នេះដោយប្រុងប្រយ័ត្ន។ ដោយហេតុថា សហព្រះរាជអាជ្ញាបានដកស្រង់យ៉ាងទូលំទូលាយ។ នៅក្នុងសេចក្តីដកស្រង់របស់សហព្រះរាជអាជ្ញាបានប្រើពាក្យ -- ERN ជាភាសាសអង់គ្លេស 00486227, ខ្មែរ 00063138, បារាំង ERN 00492814។ ភាសាដែលត្រូវបានដកស្រង់នោះ ខ្ញុំសូមបញ្ជាក់ថា "បេសកម្មនៃទង់បដិវត្តជាតិ គឺធ្វើការវាយប្រហារ និងបំផ្លាញនូវចក្រពត្តិដើម្បីរំដោះប្រទេស"។

យើងយល់ស្រប់ទាំងស្រុង គឺថាយ៉ាងហោចណាស់ គឺមានសេចក្តីសង្ឃឹមថា សហព្រះរាជអាជ្ញាមិនព្យាយាមប្រើអ្វីដែលខុសច្បាប់នោះទេ។ តាមពិតទាក់ទងទៅនឹងបក្សកុម្មុយនីស្តកម្ពុជា គប្បីតែពិនិត្យមើលគោលបំណងដ៏ត្រឹមត្រូវក្នុងការរំដោះប្រទេសកម្ពុជា។

[០៩:៣៧:៤៥]

បន្ទាប់មកសហព្រះរាជអាជ្ញាបានដកស្រង់ភាសាអំពីវណ្ណៈនៅក្នុងកម្ពុជា ហើយនិងទំនាស់រវាងវណ្ណៈនោះ។ ERN ភាសាអង់គ្លេស 00486228, ខ្មែរ 00063138, បារាំង 00492815។ យ៉ាងហោចណាស់នៅទំព័រ៣៧ ដល់ ៣៨ នៃប្រតិចារឹកដែលបានព្រាង ខ្ញុំមិនដកស្រង់ទាំងស្រុងទេ។ ខ្លឹមសារនោះគឺថា គឺមានការទំនាស់ជាច្រើនរវាងវណ្ណៈទាំងនោះ។ ខ្ញុំដកស្រង់ប្រយោគមួយដែលមានន័យថា "ទំនាស់គឺមានលក្ខណៈស្មុគស្មាញ ហើយនិងពិបាកយល់ណាស់"។ តាមអត្ថន័យនេះ គឺភាសាហ្នឹងគឺចង់បញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាពិនិត្យមើលសង្គមខ្មែរថា ជាបញ្ហាស្មុគស្មាញ គេមិនព្យាយាមទៅបំបាត់វណ្ណៈមួយទុកវណ្ណៈមួយទៀតនោះទេ។ ដើម្បីបញ្ជាក់ពីការចាប់អារម្មណ៍ សហព្រះរាជអាជ្ញាបានមើលចម្លើយខ្លឹមសារផ្សេងទៀត នៅក្នុងទំព័រដដែល។ ទី១ នោះ គឺបានដកស្រង់ "គឺពីម្ចាស់ដី កសិករ គឺជាអ្នករងគ្រោះបំផុត ភាពខុសគ្នា ហើយនិងអ្នកដែលរងការគាបសង្កត់។ ប្រជាជន ៨៥ភាគរយជាកសិករ គឺមានទំនាស់ជាមួយវណ្ណៈកេងប្រវ័ញ្ចជិះជាន់"។

[០៩:៣៩:២២]

វណ្ណៈទី២ -- ចំណុចទី២សូមដកស្រង់៖ "ទំនាស់ គឺជាទំនាស់ស្លាប់រស់។ នេះគឺជាទំនាស់ដ៏ជ្រាលជ្រៅក្នុងសង្គមកម្ពុជា ដែលប៉ះពាល់ដែលប្រជាជន ៨៥ភាគរយ។ ដោយហេតុនេះហើយដែលថាសមាជទី១របស់បក្សនោះបានកំណត់និយមន័យរបស់ការទំនាស់នេះថាជាទំនាស់បដិបក្ខ។ នៅក្នុងករណីនេះ ថាតើអាចនឹងដោះស្រាយដូចម្តេចបាន? កសិករត្រូវធ្វើការតស៊ូប្រឆាំងនឹងវណ្ណៈជិះជាន់ ហើយ

និងវណ្ណៈសក្តិភូមិម្ចាស់ដី" សូមបញ្ចប់សេចក្តីដកស្រង់។ ដូច្នេះសហព្រះរាជអាជ្ញាបានធ្វើឱ្យអង្គជំនុំជម្រះសម្រេចថា បក្សកុម្មុយនីស្តកម្ពុជា ពិនិត្យឃើញ ៨៥ភាគរយនៃប្រជាជនគឺជារងទំនាស់ស្លាប់រស់ ហើយអ្នកនោះស្ថិតនៅក្នុងប្រជាជន។

នៅក្នុងប្រយោគបន្ទាប់ទៀត ឯកសារនោះបាននិយាយដូចខាងក្រោមនេះសូមដកស្រង់៖ "ត្រូវតែមានដំណោះស្រាយជាទូទៅ។ ប៉ុន្តែដើម្បីឈ្នះបាន កសិករត្រូវតែប្រមូលផ្តុំ គឺយកតែអ្នកណាដែលនៅខាងខ្លួន។ បទពិសោធន៍ជាក់ស្តែងរបស់យើងបានបង្ហាញជាក់ស្តែងថា នៅពេលដែលយើងជោគជ័យក្នុងការកៀងគរប្រជាជន ៨៥ភាគរយ អ្នកផ្សេងទៀតនឹងតាមដាន។ លើកលែងតែអ្នកភាគតិចដែលមិនដើរតាមយើងនេះដែលយើងបានកំណត់ពីបេសកកម្មនៃបដិវត្តន៍ប្រជាធិបតេយ្យ។ តាមន័យនេះយើងនិយាយថាការរំដោះប្រជាជន។ ជាក់ស្តែងគឺជាការរំដោះប្រជាជនភាគច្រើន ៨៥ភាគរយដែលជាវណ្ណៈកសិករ។ ដើម្បីរំដោះកសិករដែលបង្កើតបាន៨៥ភាគរយនៃប្រជាជន គឺការរំដោះប្រជាជនទាំងអស់តែម្តង។ ក្នុងចំណោមប្រជាជនដែលនៅសល់១៥ភាគរយ គឺត្រូវតែដើរតាមភាគច្រើនជាកម្មករ កសិករដែលជាកម្លាំងបដិវត្តន៍ដ៏មានកម្លាំងនោះ"។ សូមបញ្ចប់សេចក្តីដកស្រង់។

ដូច្នេះភាសាដែលប្រើដោយសហព្រះរាជអាជ្ញានេះ គឺបានបំភ្លេចចោលពីចំណុចជាក់លាក់ដែលថា ហើយវណ្ណៈកសិករ និងពលករគឺថាមិនត្រូវបានដកចេញពីសង្គមនោះទេ ប៉ុន្តែផ្ទុយទៅវិញគេត្រូវចូលរួមកម្លាំងនៅក្នុងភាគច្រើននៃប្រជាជន ប្រឆាំងនឹងក្រុមតូចមួយ គឺវណ្ណៈម្ចាស់ដីហើយនិងអ្នកមាន។

[០៩:៤២:០៥]

បន្ទាប់លោកប្រធាន ខ្ញុំនឹងបន្តដកស្រង់នូវឯកសារទង់បដិវត្ត ERN ភាសាអង់គ្លេសគឺ 0048 6233, ខ្មែរ 000633145, បារាំង 00492820។ នៅក្នុងសេចក្តីដកស្រង់នោះឯកសារនោះនិយាយថាមេដឹកនាំដែលបង្ហាញពីចេតនាផ្សព្វផ្សាយនូវព័ត៌មានពីការខ្វែងគំនិតនេះ ហើយមិនឱ្យយើងមើលឃើញនូវទំនាស់នោះបាន។ តាមពិតនេះជាន័យត្រង់ ហើយគឺជាមតិនិងការប្រៀបធៀបជាពិសេស គឺនិយាយអំពីមហាជន។ ហើយយើងអាចពិនិត្យឃើញការសិក្សារាប់ពាន់អំពីបញ្ញវន្តបស្ចិមប្រទេស ជាពិសេសនៅក្នុងសង្គមរបស់គេនៅបច្ចុប្បន្ននេះ។

បន្ទាប់ទៅទៀត--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកមេធាវី។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:៤៣:២១]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការជំទាស់នូវផ្នែកមួយចំនួនដែលសហមេធាវីបានលើកឡើងនូវបញ្ហានេះ គឺថាខ្ញុំឃើញថាគាត់អះអាងថាយើងយកឯកសារ -- បើសិនជាគាត់យល់ថា ភាពណាមិនពាក់ព័ន្ធយើងមិនបានបង្ហាញនោះ គឺគាត់អាចលើកបែបនោះបាន។ នេះជាឱកាសសម្រាប់គាត់ធ្វើដូច្នោះបាន។ ប៉ុន្តែអ្វីដែលខ្ញុំជំទាស់នោះក្នុងការរៀបរាប់ពាក្យពេចន៍អំពីបទបង្ហាញរបស់យើងគាត់បាន -- គាត់ប្រើនូវមតិយោបល់ដ៏ខ្លាំងៗ ដូចដែលគាត់ផ្ទាល់ហ្នឹងគឺជាអ្នកជំនាញខាងកុម្មុយនីស្តដូច្នោះឯង។ ហើយគាត់អាចនឹងផ្អែកទៅលើអត្ថបទផ្សេងៗទៀតដែលយើងមិនបានប្រើ។ មេធាវីអាចនឹងអានផ្នែកនៃឯកសាររបស់គាត់ត្រង់ណាដែលមិនពាក់ព័ន្ធ ប៉ុន្តែគាត់ដាក់នូវសេចក្តីយោបល់ជាសេចក្តីសន្និដ្ឋានដោយប៉ុនប៉ងនៅក្នុងការផ្តល់ភស្តុតាងដោយខ្លួនឯងអំពីអត្ថន័យនៃឯកសារទាំងអស់នេះជូនអង្គជំនុំជម្រះ ខ្ញុំគិតថាមិនជាការសមស្របទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានយោបល់ថាអ្វីនឹងត្រូវធ្វើយ៉ាងណាទេ ប៉ុន្តែអ្វីដែលយើងធ្វើក្នុងឋានៈជាមេធាវីការពារក្តីយើងនិយាយអំពីតម្លៃជាភស្តុតាងនៃឯកសារដែលបង្ហាញនោះ។ អ្វីដែលយើងធ្វើគឺស្របទៅតាមទស្សនៈនិងគោលការណ៍យើងដូច្នេះនោះឯង។ ដូច្នេះសូមអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំបន្ត។

[០៩:៤៥:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៨:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះមិនចាត់ទុកថានេះជាការជំទាស់នោះទេ ហើយអង្គជំនុំជម្រះក៏មិនចង់រំខានវិធីដែលមេធាវីការពារក្តីនឹងដាក់បង្ហាញនូវយោបល់របស់ខ្លួន គឺថាឯកសារទាក់ទងទៅនឹងអ្វីដែលខ្លួនលើកនោះ។ ប៉ុន្តែគ្រាន់តែជូនដំណឹងទៅមេធាវីការពារក្តីថា យោបល់មួយចំនួនគឺដែលធ្វើឡើងមិនផ្អែកទៅលើភស្តុតាងដែលដាក់ដេញដោល ឬក៏មិនផ្អែកលើឯកសារភស្តុតាងនោះទេ

គឺយើងនឹងមិនវាយតម្លៃជាភស្តុតាងនោះទេ។ ខ្ញុំយល់ថាលោក កូប៉េ យល់អំពីសេចក្តីពន្យល់នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម។ លោកប្រធាន សហសេវិកបានប្រាប់ខ្ញុំថា ខ្ញុំអានដូចល្បឿនពេក ខាងបកប្រែបកមិនទាន់ ដូច្នេះខ្ញុំនឹងទៅដោយយឺតបន្តិច។

ខ្ញុំនិយាយអំពីឯកសារទង់បដិវត្តមុនពេលដែលយើងមានការជំទាស់នេះ។

សហព្រះរាជអាជ្ញាបានបន្តដកស្រង់នៅក្នុងបទបង្ហាញរបស់ខ្លួនអំពីទង់បដិវត្តដដែលនោះ គឺឯកសារ E3/11 ហើយពួកគាត់បានប្រើនូវសេចក្តីដកស្រង់នៅក្នុងភាសាអង់គ្លេស ERN 00486233, ខ្មែរ 00063145, បារាំង 00492820។ សូមដកស្រង់៖ "នៅពេលដែលយើងធ្វើការវិភាគអំពីទំនាស់នៅក្នុងសង្គមកម្ពុជា តើយើងកំណត់ថាតើអ្នកណាជាខ្មាំងរបស់បដិវត្តន៍ ហើយអ្នកណាគឺជាកងកម្លាំងរបស់បដិវត្តន៍។ មានខ្មាំងពីរយ៉ាងដែលយើងត្រូវប្រយុទ្ធ។ ទី១ គឺចក្រពត្តិនិយម ជាពិសេសចក្រពត្តិនិយមអាមេរិក។ ទី២ គឺវណ្ណៈសក្តិភូមិ ម្ចាស់ដី ហើយនិងពួកប្រតិកិរិយា"។ បញ្ចប់សេចក្តីដកស្រង់។

[០៩:៥០:៥៣]

តាមពិត សហព្រះរាជអាជ្ញាបានបញ្ចប់សេចក្តីដកស្រង់នៅក្នុងទីកន្លែងមួយដែលខ្លួនយល់ថាសមស្រប។ ដោយហេតុថានៅប្រយោគបន្ទាប់មួយទៀតនៅក្នុងឯកសារនេះ គឺបាននិយាយដូចខាងក្រោមនេះ។ សូមដកស្រង់ម្តងទៀត៖ "កន្លែងបដិវត្តន៍ គឺកម្មករ កសិករ ហើយនិងអនុធន នាយទុនថ្នាក់ជាតិ ហើយនិងវណ្ណៈស្នេហានឹងត្រូវបានគេជិះជាន់។ ហើយយើងត្រូវតែយើងពិនិត្យមើលនៅក្នុងសង្គមជាតិឲ្យបានប្រមូលផ្តុំពួកគេ។ ប្រសិនបើយើងមិនប្រមូលទេ ពួកគេនឹងមិនជោគជ័យក្នុងការតស៊ូទេ ប្រសិនបើយើងប្រមូលពួកខ្លះ បានខ្លះ យើងជោគជ័យទៅខ្លះ។ ប្រសិនបើយើងប្រមូលទាំងអស់យើងនឹងជោគជ័យទាំងស្រុង។ ប្រសិនបើយើងប្រមូលនូវកម្លាំងធំធេង យើងនឹងជោគជ័យដ៏អស្ចារ្យ។ នេះគឺជាកត្តាដែលកំណត់ថាតើបដិវត្តន៍ត្រូវឈ្នះ ឬត្រូវចាញ់នោះ។ ដូច្នេះយើងត្រូវតែដឹងអំពីការប្រមូលកម្លាំងកម្មករ កសិករ ហើយនិងអនុធន ហើយនិងទាយទុនថ្នាក់ជាតិ ហើយនិងអ្នកស្នេហាជាតិ។ ដូច្នេះតើយើងអាចប្រមូលកម្មករ កសិករ អនុធន ហើយអនុធនអ្នកស្នេហាជាតិដូចម្តេច។ យើងបន្តទៅតាមមាគ៌ានៅក្នុងការពិនិត្យមើលទំនាស់ដែលយើងត្រូវវាយប្រហារ។ ទំនាស់សំខាន់ ប្រព័ន្ធម្ចាស់ដីសក្តិភូមិ និងចក្រពត្តិនិយមនោះទេឯង។ ចំពោះទំនាស់តូចតាចត្រូវដោះស្រាយនៅក្នុងវគ្គតូចៗ ដែលអនុញ្ញាតឲ្យមានសាមគ្គីភាពនៅក្នុងកងកម្លាំង។ ជាពិសេសយើងអាចវាយប្រហារចក្រពត្តិអាមេរិកាំង សក្តិភូមិ ម្ចាស់ដី

ហើយប្រតិកិរិយា"។ សូមបញ្ចប់ការសេចក្តីដកស្រង់។

[០៩:៥៣:០៦]

ឯកសារនេះបន្តទៅតាមខ្លឹមសារនេះ នៅក្នុងកថាខណ្ឌនៅខាងចប់ និយាយអំពីការពិភាក្សារវាងវណ្ណៈទាំងពីរនេះ ហើយចូលទៅដល់ជំហរមួយដែលមានសារប្រយោជន៍។ នៅខាងក្រោមនៅទំព័រដដែលនោះ គឺអាចធ្វើឲ្យមានសេចក្តីថ្លែងការណ៍មួយដ៏សំខាន់ គួរឲ្យចាប់អារម្មណ៍។ "អនុធន កូនសិស្សនិស្សិត បញ្ញវន្តគ្រប់វណ្ណៈគ្រប់ស្រទាប់ គឺជាសម្ព័ន្ធមិត្តរបស់កម្មករ កសិករ ហើយដូចក្នុងអតីតកាលហើយដូចគ្នាដែរនៅបច្ចុប្បន្ននេះ នៅក្នុងវណ្ណៈដើម វណ្ណភាពដើមរបស់ខ្លួននោះ។

នៅក្នុងកថាខណ្ឌបន្ទាប់ ហើយអ្វីដែលហៅថា នាយទុនជាតិក៏បានរៀបរាប់ "គឺជាមិត្តរបស់បដិវត្តន៍"។ សហព្រះរាជអាជ្ញាមិនបានដកស្រង់អំពីកម្លាំងជាមូលដ្ឋាន ប៉ុន្តែគេបាននិយាយថា ជំនួសជាយុទ្ធសាស្ត្រ។

នៅក្នុងកថាខណ្ឌបន្ទាប់ ទោះបីជានៅក្នុងអំពីវណ្ណៈសក្តិភូមិ ហើយពួកម្ចាស់ដីក្តីដែលជាស្នូលនៃក្រុមរបស់វណ្ណៈដែលត្រូវគេជិះជាន់នោះ គឺគេនិយាយពីកម្លាំងតាក់តិកមួយដើម្បីគាំទ្រដល់បដិវត្តន៍។ នៅទីបញ្ចប់ ERN ជាភាសាអង់គ្លេស 00486233 ហើយនិងខ្មែរ 00063145, បារាំង 00492820។ ការពិភាក្សានេះក៏បាននិយាយដូចខាងក្រោមនេះ -- ដែលសហព្រះរាជអាជ្ញាបានលើកឡើង -- សូមដកស្រង់៖ "យើងបែងចែកខ្មាំងទៅជាបីក្រុម។ ទី១ ដើម្បីឈ្នះខ្មាំងគឺថាត្រូវតែឈ្នះឲ្យបានគ្រប់កាលៈទេសៈ។ ទី២ ដើម្បីធ្វើឲ្យអ្នកណាៗដែលអាចមានកម្លាំងកុំឲ្យមានកម្លាំង។ ទី៣ គឺធ្វើឲ្យគេឯកកោ ដើម្បីវាយប្រហារពួកគេបាន"។

[០៩:៥៥:២០]

ដូច្នេះលោកប្រធាន លោក លោកស្រីចៅក្រម! ប្រសិនបើយើងអានទាំងអស់នេះរួមបញ្ចូលគ្នាចលនាបដិវត្តន៍ គឺរៀបរាប់ គឺជាសម្ព័ន្ធនៃសង្គមខ្មែរទាំងមូលគ្រប់ស្រទាប់វណ្ណៈ។ ហើយប្រឆាំងតែនឹងក្រុមម្ចាស់ដីតូចតាច ដែលទាក់ទងថាជាវណ្ណៈជិះជាន់លើកម្មករ។ ទោះបីជាខ្មាំងអស់នោះ ត្រូវបានឈ្នះលើ ឬក៏ត្រូវបានផ្តាច់នូវអំណាចក៏ដោយ គឺថានេះគឺជារឿងមួយដែលថាសហព្រះរាជអាជ្ញាបាននិយាយមិនដកស្រង់ដល់នោះទេ។ ដែលយើងអាចធ្វើ និងឲ្យត្រឹមត្រូវគឺអានទាំងស្រុង យើងបានខ្លឹមសារទាំងស្រុងដើម្បីជាមូលដ្ឋាន។

សហព្រះរាជអាជ្ញាបានបន្តដកស្រង់ពីឯកសារដដែលនេះ គឺពាក់កណ្តាលទំព័រ៤០ នៅក្នុង

ប្រតិចារឹកព្រាងនៅទំព័រ៤៣ បានដកស្រង់ នូវសេចក្តីដកស្រង់អំពីការប្រើនូវហិង្សានយោបាយ និងហិង្សាយោធានៅក្នុង១៩៦៨-១៩៧៥។ ទាំងអស់នោះគឺ ERN អង់គ្លេស 00486251 ដល់ 54, ខ្មែរ 00063148 ដល់ 49, បារាំង ERN 00492824។ នេះនៅតែជាឯកសារ E3/11 ដដែល។

ទាក់ទងទៅនឹងសេចក្តីដកស្រង់ដែលយើងមិនទាន់ច្បាស់ ថាតើយើងដឹងអំពីគោលបំណងសហព្រះរាជអាជ្ញាដែរនោះទេ ប៉ុន្តែតាមពិតសហព្រះរាជអាជ្ញាបានទទួលស្គាល់ថា អំពើហិង្សាអាចនឹងត្រូវបានគេប្រើនៅក្នុងសង្គ្រាមស៊ីវិល។ ដោយពិតប្រាកដហើយ គេទទួលស្គាល់អំពីកម្លាំងខ្ទាមដែលងើបឡើងប្រឆាំងបដិវត្តន៍ ជាពិសេសប្រឆាំងនឹងឈ្លានពានបរទេស ហើយនិងពួកអាណានិគម ពួករបប លន់ នល់ គឺជាមុខការមួយ។ ដូច្នេះហើយបញ្ហាទាំងអស់នេះ មិនមានបដិ -- មិនមានទាក់ទងអ្វីទៅនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទេ។

[០៩:៥៧:៣៥]

មុននឹងបញ្ចប់ឯកសារនេះ ខ្ញុំចង់ដកស្រង់សេចក្តីដកស្រង់ចុងក្រោយដែលសហព្រះរាជអាជ្ញាបានដកស្រង់ ពីព្រោះខ្ញុំគិតថាចំណុចនេះគាំទ្រយ៉ាងសំខាន់ដល់គោលជំហររបស់កូនក្តីរបស់ខ្ញុំ។ សហព្រះរាជអាជ្ញាបានសម្រេចដកស្រង់ថាជាការខុសច្បាប់ ដែលឆ្លុះបញ្ចាំងពីការខកខានមិនបានគិតអំពីអ្វីជាមធ្យោបាយ។ គឺថាអង់គ្លេស ERN គឺ00486248, ខ្មែរ 00063163, បារាំង 00492837 ដែលនិយាយថា -- មាគ៌ាបក្សដែលនិយាយក្នុងឆ្នាំ១៩៦០ -- បាននិយាយថា “១) ដើម្បីធ្វើបដិវត្តន៍ជាតិ ដើម្បីលុបបំបាត់នូវចក្រពត្តិនិយម ជាពិសេសចក្រពត្តិអាមេរិក។ ទី២ ធ្វើបដិវត្តន៍ប្រជាធិបតេយ្យដោយលុបបំបាត់ចោលនូវប្រតិកិរិយា ហើយនិងសក្តិភូមិ ហើយនិងកុំប្រាដ័រ។ ហើយយើងទទួលស្គាល់ភារកិច្ចទាំងពីរទាំងស្រុងនៅថ្ងៃ -- ធ្វើឲ្យសម្រេចគោលការណ៍នេះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥”។ សូមបញ្ចប់។

[០៩:៥៨:៤១]

យើងឃើញច្បាស់ហើយ អ្នកណាក៏មើលឃើញដែរ ដែលអានអំពីបរិបទនេះ ដែលថាមិនយោងទៅរកៗជនជាតិអាមេរិកាំងជាមនុស្សម្នាក់ៗនោះទេ។ ហើយក៏មិនបានយោងទៅរកសក្តិភូមិ ហើយនិងនាយទុននោះដែរ។ គឺយោងទៅរកប្រព័ន្ធនៃចក្រពត្តិនិយម សក្តិភូមិ ហើយនិងនាយទុននិយម។ គឺប្រព័ន្ធទាំងអស់នោះហើយ ដែលជាទិសដៅនៃបក្សកុម្មុយនីស្តកម្ពុជា។ ហើយខ្ញុំបញ្ជាក់ថា នេះជាភាសាច្បាស់ដែលនៅក្នុងអត្ថបទនោះ។ ប៉ុន្តែភាពមិនច្បាស់លាស់ គឺនឹងត្រូវដោះស្រាយដោយប្រយោគបន្ទាប់ ដែលនិយាយថាយើងទទួលបានជោគជ័យការងារនេះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជាក់ស្តែងបក្ស

កុម្មុយនីស្តមិនបានពិឃាដជនជាតិអាមេរិកាំង នាយទុន ហើយនិងសក្តិភូមិនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះទេ។ អ្វីដែលគេបានធ្វើនោះ សូមដកស្រង់ "គឺលុបបំបាត់នូវប្រព័ន្ធនយោបាយដែលធ្វើឲ្យអ្នកទាំងអស់នោះកាន់អំណាច។ នោះគឺជាគោលបំណងនៃបក្សកុម្មុយនីស្តកម្ពុជា ដែលនេះហើយជាអត្ថន័យនៃឯកសារនេះ"។

[១០:០០:០៣]

ដើម្បីភ្ជាប់ចំណុចនេះទៅនឹងផ្នែកខាងដើម ដែលខ្ញុំបានបញ្ជាក់ខាងដើម គឺថាន័យនេះហើយដែលសហព្រះរាជអាជ្ញាបញ្ជាក់ថាជាគោលនយោបាយដ៏មូលដ្ឋាន។ ដោយហេតុថាខ្លួនបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបង្កឲ្យមានអន្តរាយដល់ប្រជាជន ហើយនិងធ្វើឲ្យសង្គ្រាមប្រឆាំងនឹងប្រព័ន្ធ។

ឯកសារពីរដែលខ្ញុំលើកឡើងនេះគឺជាឯកសារមិនពាក់ព័ន្ធទាក់ទងនឹង -- ដែលមិនពាក់ព័ន្ធនឹងមូលហេតុនេះទេ។ ឯកសារនុ៎ងគឺ E3/2072 ហើយនិង E3/147។ ឯកសារនេះនឹងបញ្ចូលនូវសុន្ទរកថារបស់ ប៉ុល ពត ហើយនិង នួន ជា។ មួយទៀត នីមួយៗនៃឯកសារនោះគឺនិយាយអំពីហិង្សាបដិវត្តន៍នៅក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥។ ដោយហេតុនោះហើយដែលយើងខ្ញុំបានបញ្ជាក់ថា ជាឯកសារមិនពាក់ព័ន្ធនឹងអ្វីទាល់តែសោះ។ យើងក៏កត់សម្គាល់ថា សុន្ទរកថាទាំងអស់នោះគឺនិយាយអំពីកិច្ចប្រឹងប្រែងដើម្បីយកជ័យលើចក្រពត្តិ ហើយនិងសក្តិភូមិ ដែល ប៉ុល ពត និង នួន ជា បាននិយាយអំពីកម្លាំងសង្គម។

[១០:០១:២៦]

សហព្រះរាជអាជ្ញាបង្ហាញនូវទង់បដិវត្តចំនួនបួនទៀត ដែលមានគោលបំណងបង្ហាញថា នេះជាគោលនយោបាយបន្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមបញ្ចប់សេចក្តីដកស្រង់។

ឯកសារទី១ គឺនៅថ្ងៃ -- នៅខែមិថុនា ឆ្នាំ១៩៧៦, ឯកសារ E3/760 ជាឯកសារទង់បដិវត្ត។ សហព្រះរាជអាជ្ញាបានផ្តល់ឲ្យយើងនូវសេចក្តីដកស្រង់ដ៏ខ្លីអំពីបញ្ហានេះ។ ហើយមូលហេតុនោះគឺថា យើងអានឯកសារនេះទាំងស្រុង គឺថាភាសា គឺចាប់ផ្តើម វាមានលក្ខណៈស្រាលទេ។ សេចក្តីដកស្រង់ដែលព្រះរាជអាជ្ញានោះគឺយកពីអង់គ្លេស 00509614, ខ្មែរ 00062849, បារាំង 00487759។ នៅទំព័រ៤៥ និង ៤៦ នៃប្រតិចារឹកសេចក្តីព្រាង មានខ្លឹមសារថា "អ្វីដែលខ្មាំងនឹងធ្វើបន្ទាប់ តើពួកគេខ្លាំង ឬក៏ពួកគេចុះខ្សោយ? យើងអាចឆ្លើយតបដោយនិយាយថាគេនឹងអនុវត្តសកម្មភាពប្រឆាំងយើង ប្រឆាំងបដិវត្តន៍ក្នុងរូបភាពច្រើនយ៉ាង។ នេះគឺជាការតស៊ូជាបន្តបន្ទាប់ប្រឆាំងនឹងអ្នកណាដែលប្រឆាំងបដិវត្តន៍។ យើងនឹងមិនបញ្ឈប់ ហើយយើងបំពាក់អាវុធ និងប្រកាន់ជំហររបស់យើងកាលណាខ្មាំងនៅតែមាន

ពីព្រោះគេអាចនឹងមាន១០, ២០ ឬក៏ ៣០ឆ្នាំទៅទៀត។ ការតស៊ូជាតិ គឺថា គឺដូចនឹងការតស៊ូវណ្ណៈនោះដែរ។ បញ្ហានេះគឺមិនអាស្រ័យទៅលើពួកគេនោះទេ គឺអាស្រ័យនៅលើយើង។ ប្រសិនបើយើងប្រកាន់វិធានការដាច់ខាតម្តងហើយម្តងទៀត ពួកគេនឹងចុះខ្សោយ ហើយពួកគេនឹងរប៉ាត់រប៉ាយ”។ សូមចប់សេចក្តីដកស្រង់។

[១០:០៣:២៤]

ទោះបីជាសេចក្តីដកស្រង់ដែលសហព្រះរាជអាជ្ញា ដែលជ្រើសរើសយកមកបង្ហាញ យើងយល់ឃើញថាគឺជាការព្រមានអំពីខ្មាំងដែលអាចនឹងមាន។ អ្នកណាដែលអាចនឹងជាខ្មាំង គេអាចនឹងតស៊ូប្រឆាំង ប៉ុន្តែបន្ទាប់មក -- ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ថា បើយើងអានឯកសារទាំងស្រុងនោះ យើងអាចនឹងឃើញកាន់តែច្បាស់ថា តើវាអាចមានអត្ថន័យដូចម្តេច? យើងនឹងដកស្រង់ឯកសារនេះទៀតគឺថាប្រយោគនូវដំបូង បន្ទាប់ពីបញ្ចប់ពីសេចក្តីដកស្រង់របស់សហព្រះរាជអាជ្ញានោះ ខ្ញុំសូមដកស្រង់ម្តងទៀត។ ជាសេចក្តីដកស្រង់ដ៏វែង សូមអភ័យទោស។

“កាលណាយើងខ្សោយ ពួកគេខ្លាំង។ កាលណាយើងខ្លាំង អ្វីដែលខ្ញុំចង់និយាយគឺយើងមានទស្សនៈ ហើយយើងមានវិធានការយោធា និងនយោបាយល្អនៅគ្រប់ភូមិភាគតំបន់ ហើយនិងស្រុក ហើយនៅក្នុងភូមិ នៅក្នុងសហករណ៍ គឺដូចគ្នា។ នៅពេលសហករណ៍ខ្លាំង ខ្មាំងមិនអាចចូលបាន ប៉ុន្តែសហករណ៍ចុះខ្សោយ ខ្មាំងអាចនឹងបង្កនូវបញ្ហាបាន ការមិនខ្លាំង បើយើងមិនខ្លាំងទេ ប្រជាជនក៏មិនខ្លាំងដែរ។ នៅពេលថ្នាក់ដឹកនាំខ្លាំង ប្រជាជនក៏ខ្លាំង។ បញ្ហាគឺអាស្រ័យថាតើប្រជាជនយល់ ឬមិនយល់ ហើយនិងទទួលការអប់រំបានល្អ ហើយជីវភាពរបស់ប្រជាជនអាចនឹងដោះស្រាយបាន។ ដូច្នេះគឺអាស្រ័យលើយើង គឺលើបក្ស ហើយនិងបដិវត្តន៍ គឺមិនអាស្រ័យទៅលើខ្មាំងនោះទេ”។ សូមបញ្ចប់សេចក្តីដកស្រង់។

[១០:០៥:២៥]

ប៉ុន្តែនៅទំព័របន្ទាប់ -- លោក លោកស្រី លោកប្រធាន! -- ឯកសារហ្នឹងបានពន្យល់អំពីថាអ្វីដែលថាភាគីអាចនឹងក្តាប់បានប្រជាជន ហើយខ្ញុំសូមដកស្រង់ម្តងទៀត៖ “ចំណុចសំខាន់គឺត្រូវចាត់វិធានការដើម្បីក្តាប់សហករណ៍ឲ្យបាន បក្សត្រូវតែក្តាប់សហករណ៍ទាំងអស់ តើបក្សអាចក្តោបក្តាប់សហករណ៍ដូចម្តេចបានតាមក្របខ័ណ្ឌប្រឆាំងនឹងខ្មាំង? គឺត្រូវក្តាប់តាមនយោបាយធ្វើឲ្យគេយល់អំពី យល់ពីមាគ៌ារបស់បក្ស ក្តាប់ខាងមនោគមន៍វិជ្ជា ធ្វើឲ្យគេច្បាស់ យល់ច្បាស់ បេសកម្មមួយៗរបស់ផែនការរបស់

បក្ស ត្រូវតែពន្យល់ដល់គេឱ្យបានយល់ឱ្យច្បាស់។ ទំនប់ ប្រឡាយ ហើយគោលការណ៍បីតោនក្នុងមួយហិកតា ជាការកសាងប្រទេស ការពារប្រទេស។ ហើយយើងត្រូវពន្យល់គេឱ្យបានច្បាស់ដើម្បីឱ្យគេយល់បាន។ កាលនិយាយច្បាស់ហើយ គេនឹងគេយល់ច្បាស់ហើយ គេអាចនឹងពេញចិត្ត គេអាចនឹងមានកូន មានចៅ ចូលកងកម្លាំង កងចល័ត ហើយនិងលើកទំនប់ ជីប្រឡាយ ធ្វើស្រែបាន។ លើសពីនេះទៅទៀត គឺថាក្ដាប់អំពីមហាជន ហើយត្រូវក្ដាប់ប្រវត្តិរូបរបស់គេឱ្យបាន ត្រូវប្រើកម្លាំងមហាជននៅក្នុងសហករណ៍ ដើម្បីប្រឆាំងនឹងខ្មាំង។ អង្គការបក្ស ជាស្នូលបួនទៅដប់ មិនអាចប្រឆាំងយើងបាននោះទេ"។ នេះគឺសូមបញ្ចប់នៃសេចក្ដីដកស្រង់នេះ។

[១០:០៧:១៦]

សូមអភ័យទោស ដែលថាយើងដកស្រង់ខ្លឹមសារវែងពេក។ យើងយល់ថា អាចនឹងពិបាកហ្នឹងតាម ក៏ប៉ុន្តែការពិតជាចំណុចដែលយើងចង់បញ្ជាក់ដែលថា ត្រូវតែមិនអាចយល់ច្បាស់បានទេបើយើងដកស្រង់តូចៗនោះ ទាល់តែវែងបែបនេះ គឺឯកសារ គឺវាមានលក្ខណៈខ្លឹមសារអត្ថន័យរបស់វា។ ហើយយើងខ្ញុំសូមជម្រាបថា នៅពេលដែលយើងអានខ្លឹមសារទាំងស្រុង ដូចជា ប្រសិនបើសហករណ៍ធ្វើការបានល្អ គឺធ្វើឱ្យកងកម្លាំងនឹងរឹងមាំ ប្រជាជនរឹងមាំ ខ្មាំងមិនអាចចូលបាននោះទេ។ ដូច្នេះមិនមែនជាកិច្ចប្រឹងប្រែងដើម្បីនៅការឱ្យគាំទ្រតែម្ខាងនោះទេ ប៉ុន្តែជាការអំពាវនាវឱ្យគោរពតាមគោលការណ៍បដិវត្តន៍។

ក្រោយពីសហព្រះរាជអាជ្ញាបង្ហាញទង់បដិវត្តបីទៀត គឺចុះកាលបរិច្ឆេទខែមេសា ៧៧, មិថុនា ៧៧ និង ឧសភា ៧៨។ លេខឯកសារ គឺ E3/742, E3/135 និង E3/727។

លោកប្រធាន យើងខ្ញុំនឹងធ្វើការសម្រេចសេចក្ដីពិបាកទៅលើចំណុចនេះ ដោយមិនចូលបង្ហាញឯកសារនេះលម្អិតនោះទេ។ មានហេតុផលពីរបីដែលថា ទី១ គឺយើងមានពេលវេលា និងធនធានមានកម្រិតសម្រាប់ថ្ងៃនេះនៅក្នុងការបង្ហាញរបស់យើង និងទី២ ឯកសារទាំងអស់នេះគឺថាមិនពាក់ព័ន្ធទៅនឹងផ្នែកសវនាការនេះទេ។ ដោយហេតុថាឯកសារទាំងអស់នេះ គឺថាវាស្ថិតនៅខាងក្រោយុត្តាធិការតែម្ដង ហើយគោលនយោបាយទាំងនេះ ក៏មិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការសំណុំរឿង០០២/០១ដែរ។ ដូច្នេះយើងខ្ញុំនឹងលើកយកមកបង្ហាញឯកសារនេះ នៅក្នុងសេចក្ដីសន្និដ្ឋានសួរបញ្ចប់ៗដេញដោល។

[១០:០៩:១៨]

ខ្ញុំនឹងលើកឡើងនូវបញ្ហាមួយទៅលើឯកសារទាំងអស់នេះ ដែលថា ហាក់បីដូចច្បាស់ហើយភាសានៅក្នុងឯកសារទាំងនេះ គឺថាជាពិភាក្សាមួយដែលគេហៅថា ភាសាគេប្រើប្រាស់នៅពាក់កណ្ដាល

នៃទសវត្សរ៍ ១៩៧០ ហើយវាពាក់ -- ជាពិសេសនៅពេលពាក់ព័ន្ធទៅនឹងការកើនឡើងដល់កំពូលនៃជម្លោះរវាងកម្ពុជានិងវៀតណាមនោះ។ ជាអ្វីកើតឡើងនៅក្នុងពេលមានសង្គ្រាមនៅក្នុងប្រទេសជាច្រើន អ្នកនយោបាយក៏ចាប់ផ្តើមនិយាយអំពីបញ្ហាផ្សេងៗ ប៉ុន្តែមិនមែនមានន័យថាគេជា -- ហើយយើងខ្ញុំនឹងបង្ហាញជូនថាហេតុដូចម្តេចបានជាមានការចាំបាច់ក្នុងការបង្ហាញឯកសារទាំងអស់នេះ? ទាក់ទងទៅនឹងទង់បដិវត្តន៍ ១៩៧៦ ខែមិថុនា ហើយនិងទង់បដិវត្តន៍មិថុនា ១៩៧៨ អង្គជំនុំជម្រះគួរតែបង្ហាញឲ្យឃើញនូវតម្លៃនូវភស្តុតាងទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយនៅក្នុងឆ្នាំ១៩៧៥ និង ៧៦។

[១០:១០:៣៩]

បន្តទៅទៀតលោកប្រធាន សហព្រះរាជអាជ្ញាគឺថាបានបង្ហាញនូវឯកសារប្រាំ ពីគណៈអចិន្ត្រៃយ៍ ពីគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍។ ឯកសារទី១ គឺE3/1173, ចុះកាលបរិច្ឆេទ ខែកុម្ភៈ ១៩៧៦ ដែលពាក់ព័ន្ធទៅនឹងការបំផ្ទុះគ្រាប់បែកនៅសៀមរាប ដែលអង្គជំនុំជម្រះបានជ្រាបរួចមកហើយ។ ហើយអ្វីដែលឯកសារនោះនិយាយគឺសូមដកស្រង់៖ "គឺដើម្បីអប់រំផ្ទៃក្នុងឡើងវិញ"។ យើងខ្ញុំយល់ឃើញថាមិនមានអ្វីដែលគេហៅថាវាខុសច្បាប់ ឬជាឧក្រិដ្ឋកម្ម ចំពោះបញ្ហានោះទេ។ ដូច្នេះខ្ញុំយល់ឃើញថា នេះមិនបានបង្ហាញអ្វី អំពីអ្វីដែលយើងថាគោលនយោបាយឧក្រិដ្ឋកម្មទាក់ទងទៅនឹងខ្មាំងនោះទេ។

ឯកសារទី២ គឺE3/232 ជាកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះខែមីនា ១៩៧៦។ វាជាការពិតហើយដែលថាកម្មាភិបាលថ្នាក់ក្រោមបានរាយការណ៍ ជូនគណៈកម្មការអំពីការព្រួយបារម្ភពីបញ្ហាសន្តិសុខ ប៉ុន្តែមិនមានការបញ្ជាក់ណាមួយថាការនោះគឺរឿងខុសច្បាប់ទេ។ ជនដែលជាប់សង្ស័យខ្លះក៏ត្រូវបានចាប់ខ្លួននិងសួរចម្លើយ។ យើងមិនមានអ្វីមានការ ភ្ញាក់ផ្អើលទេដែលថាមានការរាយការណ៍ជូនមកគណៈអចិន្ត្រៃយ៍មួយ អំពីបញ្ហានៃកម្មវត្ថុជាទូទៅនោះទេ។ ដូច្នេះ យើងខ្ញុំមិនច្បាស់ថាតើឯកសារនេះវាមានភាពពាក់ព័ន្ធដោយរបៀបណានោះទេ។

[១០:១២:១២]

ឯកសារបន្ទាប់គឺ E3/12 ដែលបញ្ជាក់អះអាងអំពីសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងបញ្ហាមួយចំនួន។ ទី១ គឺសិទ្ធិកម្ទេចនៅខាងក្នុង និងខាងក្រៅជួរបក្ស។ ខ្ញុំសូមលើកឡើងនូវយោបល់សង្ខេបពីរពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ទី១ គឺថាឯកសារមិននិយាយអ្វីអំពីខ្មាំងនោះទេ។ ហើយវាមិនមានសេចក្តីណែនាំអ្វីទាក់ទងទៅនឹងបុគ្គល ឬក៏ក្រុមណាមួយនោះដែរ។ មិនមានភស្តុតាងដែលថាធ្វើឲ្យប៉ះពាល់ទៅដល់បុគ្គលណាម្នាក់នោះទេ។ ទី២ ដូចយើងបានឃើញនៅក្នុងបណ្តាឯកសារទាំងនេះ

ពាក្យថាកម្ទេច គឺថាប្រើប្រាស់នៅក្នុងបរិបទខុសៗគ្នា។ យើងខ្ញុំនឹងពិភាក្សាលម្អិតបន្តិចនៅពេលបន្តិចទៀតនេះ។ ដោយសារតែឯកសារមួយក្នុងបណ្តាឯកសារទាំងអស់នេះ ដែលសហព្រះរាជអាជ្ញាបានបង្ហាញយ៉ាច្បាស់នោះថា -- គឺថាឥឡូវខ្ញុំសូមនិយាយអំពីពាក្យ “*ស្មះ*” ក្នុងន័យទូទៅ។ ជាការពិតហើយមិនមែនមានន័យថា “សម្លាប់” នោះទេ។

ឯកសារបន្ទាប់មួយទៀតគឺ E3/763 ជាឯកសារមកពីគណៈមជ្ឈិមចុះថ្ងៃខែមិថុនា ១៩៧៨។ ខ្ញុំសូមរំលងឯកសារនេះបន្តិច ដោយសារវាមិនបានបង្ហាញដោយផ្ទាល់ទាក់ទងទៅនៅក្នុងទង់បដិវត្តន៍ចុះកាលបរិច្ឆេទពាក់កណ្តាលឆ្នាំ១៩៧៧នោះទេ។

ឯកសារទី៥ និងឯកសារចុងក្រោយគឺឯកសារ E3/99 ជាឯកសាររបស់បក្សចុះខែវិច្ឆិកា ១៩៧៥ ហើយខ្ញុំគិតឃើញថា អង្គជំនុំជម្រះនឹងពិនិត្យឃើញថាវានឹងមិនមានអ្វីពាក់ព័ន្ធទៅនឹងបញ្ហាឧក្រិដ្ឋកម្មនោះទេ។ ហើយសម្រង់ដែលលើកឡើងដោយសហព្រះរាជអាជ្ញា គឺបានបកស្រាយអំពីការផ្លាក់ចុះនៃការឃោសនា។ *(ឮមិនច្បាស់)* បាននិយាយអំពីភាសាសំខាន់ៗជាពិសេសនៅ ក្នុងពេលដែលខ្លួនស្ថិតនៅភាពជាវ័យជាសង្ឃសូមដកស្រង់គឺៈ “នេះគឺជាវណ្ណៈពិសេសមួយនៅក្នុងសង្គម ដែលយើងមិនត្រូវមានការព្រួយបារម្ភអ្វីតទៅទៀតនោះទេ ហើយភាពសម្ងាត់របស់បដិវត្តន៍កម្ពុជាគឺ យោងទៅលើព្រះសង្ឃហើយដែលត្រូវចូលរួមនៅក្នុងសង្គមក៏ដូចជាកម្មករប្រជាពលរដ្ឋទូទៅផងដែរ។ គឺថានៅក្នុងឯកសារមានរៀបរាប់ថាព្រះសង្ឃគឺជាខ្មាំងនោះទេ។ ដូច្នេះឯកសារនេះគឺមិនមានភាពពាក់ព័ន្ធនោះទេ។

[១០:១៥:០០]

លោកប្រធាន ចាប់ពីពេលនេះទៅមុខទៀតនេះ ទៅមុខមក គឺការបង្ហាញរបស់ឯកសារស្ទើរតែទាំងស្រុងជូនអង្គជំនុំជម្រះហ្នឹងគឺវាបញ្ហានៃការអនុវត្តតែម្តង។ សហព្រះរាជអាជ្ញានិយាយអំពីការអនុវត្តនៅតាមបណ្តាក្រសួង នៅតាមបណ្តាមន្ទីរសន្តិសុខ និងកន្លែងកងទ័ពផ្សេងៗដូចបានដឹងហើយ គឺថាយើងរកឃើញថាការបង្ហាញនូវឯកសារទាំងអស់នេះ ក្រោយពីសវនាការ២០ខែនៅក្នុងពេលដែលម្នាក់ៗគឺថាទទួលស្គាល់ថាវាស្ថិតនៅខាងក្រៅនៃវិសាលភាពនេះតែម្តង។ ឯអ៊ីចឹងហើយបានខ្ញុំយល់ឃើញថាអង្គជំនុំជម្រះមិនត្រូវពិចារណាទៅលើឯកសារហ្នឹងទេ។ មិនត្រូវយកឯកសារណាមួយនៅក្នុងបណ្តាឯកសារទាំងអស់នេះ យកមកពិចារណានៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួននោះទេ។ ការធ្វើផ្ទុយពីនេះគឺថាវាអាចរំលោភទៅដល់សិទ្ធិរបស់កូនក្តីរបស់យើងខ្ញុំ នៅក្នុងការប្រឈមតទល់ទៅនឹងឯកសារទាំងអស់នេះ។

មានឯកសារពីរច្រឡូកច្របល់នៅទីនេះដែលក៏វាស្ថិតនៅក្នុងវិសាលដ៏ចង្អៀតនៃអត្ថិភាពគោលនយោបាយសហឧក្រិដ្ឋកម្មរួម។ យើងខ្ញុំនឹងនិយាយអំពីឯកសារទាំងពីរនេះ។ អង្គជំនុំជម្រះបាននិយាយមកហើយថា ពាក្យឯកសារនេះគឺគោលជំហររបស់យើងយល់ឃើញថា ឯកសារទាំងនេះស្ថិតនៅខាងក្រៅនៃវិសាលភាពនៃសវនាការនេះ។ យើងនឹងមិនត្រូវចំណាយពេលវេលាទៅលើឯកសារណាមួយក្នុងបណ្តាឯកសារទាំងអស់នេះទេ។

[១០:១៦:៣៥]

មួយទៀតគឺឯកសារជាសុន្ទរកថារបស់ ប៉ុល ពត ថ្លែងក្នុងខែមេសា ៧៦, ឯកសារគឺ E3/818។ តាមធម្មតាសម្រង់ដែលលើកឡើងដោយសហព្រះរាជអាជ្ញាហ្នឹងនាំឲ្យយើងយល់ខុសទាំងស្រុងតែម្តង។ សហព្រះរាជអាជ្ញា ទី១ គឺដកស្រង់ឯកសារពី ERN 00143463, ខ្មែរ 00072756 និងបារាំង 00548896។ សូមដកស្រង់៖ “ដោយមិនគិតថាយើងធ្វើបានល្អប៉ុនណានោះទេ ប្រសិនណាដែលពួកចក្រពត្តិនៅរក, ពួកសេ.អ៊ី.អា វានៅតែមាននៅរស់រាននោះ ហើយប្រសិនថាក្រុមប្រតិកិរិយា គឺថាមិនទាន់បានកម្ចាត់ចោលពីមុខមាត់ពិភពលោកនោះទេ គេនឹងបន្តប្រឆាំងបដិវត្តន៍ ប្រឈមតតាំងយើងប្រឈមតតាំងជាមួយការរីកចម្រើនទាំងពីចម្ងាយផងដែរ។ សូម្បីតែនៅក្នុងពាក្យរួម គឺថាសម្រង់នេះជាក់ស្តែងហើយ គឺវាជារឿងនយោបាយទូទៅមួយ”។ បាទ នេះបញ្ចប់ការដកស្រង់នៃសុន្ទរកថារបស់ ប៉ុល ពត ហើយ។

[១០:១៧:៥៦]

សូម្បីតែក្នុងពាក្យផ្ទាល់របស់នោះគឺថា វាគ្រាន់តែបញ្ញានយោបាទូទៅតែប៉ុណ្ណោះ។ ប៉ុន្តែបរិបទនៃឯកសារនេះ គឺច្បាស់ហើយថាតើភាសានេះវាមានន័យយ៉ាងដូចម្តេច។ វាពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធនោះ។ បរិបទនៃការពិភាក្សានេះ គឺថាការប្រឆាំងទៅនឹងរដ្ឋាភិបាលនៅក្នុងពិភពលោកចំពោះរបបបក្សកុម្មុយនីស្តកម្ពុជា។ ចំណងជើងនៃផ្នែកនេះគឺមានន័យថា “អត្តសញ្ញាណបុគ្គល ហើយនិងការប្រឆាំងនៅជុំវិញពិភពលោកចំពោះការបង្កើតនូវរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់យើង”។

នេះនៅទំព័រមុនៗដែលពីសម្រង់ចុងក្រោយ។ ហើយឯកសារក៏បង្ហាញផងដែរថា “ថ្ងៃមុនៗនោះបដិវត្តន៍នៅសូវៀត និងចិននោះ ពិភពលោកក៏បានចំអកឡកឡឺយចំពោះការបែបពាក្យពេចន៍ទាំងអស់នេះផងដែរ។ ហើយ១៥ឆ្នាំក្រោយមក ក្រោយពីរំដោះ ចំនួនបណ្តាលប្រទេស គឺថាមានការទាក់ទងជាមួយនឹងចិន។ ហើយអ្នកប្រឆាំងទៅនឹងបដិវត្តន៍សង្គមនិយម គឺថាមិនមែនមានន័យថាជាកម្មាភិបាលផ្ទៃ

ក្នុងដែលត្រូវតែកម្ទេចចោលនោះទេ។ នេះជារឿងធម្មតា”។ បញ្ចប់ការដកស្រង់។

[១០:១៩:២០]

សម្រង់ទី២ ពីឯកសារនេះជាសុន្ទរកថា ប៉ុល ពត។ សូមនិយាយ ERN ជាភាសាអង់គ្លេស 00143467, ខ្មែរ 0072760 ដល់ 61 និងបារាំង 00548899 ដល់ 900។ សូមដកស្រង់៖ “ការពារអាជ្ញាធររដ្ឋបដិវត្តន៍ ការពារផ្នែការបដិវត្តន៍ ការពារបក្សប្រជាជន កងទ័ព ឯករាជ្យភាព អធិបតេយ្យភាព ប្រឆាំងនឹងសកម្មភាពខ្មាំងទាំងក្នុង ទាំងខ្មាំងចំហ ទាំងខ្មាំងលាក់មុខ។ យើងត្រូវតែប្រឆាំង ត្រូវតែខិតខំប្រឹងប្រែងការពារបដិវត្តន៍ ដើម្បីមានភាពម្ចាស់ការ”។ ម្តងទៀត ទាក់ទងទៅនឹងបញ្ហានេះ ដើម្បីធានាថាការការពារជាតិ ការការពារប្រទេសត្រូវបានការពារយ៉ាងល្អនោះ ហើយនិងមួយទៀតដើម្បីការពារទៅដល់ឯករាជ្យភាព ធិបតេយ្យភាពរបស់រដ្ឋ ពីការគំរាមកំហែងទាំងលាក់មុខ និងទាំងចំហ។

ការដាក់បញ្ជូននូវផ្នែកមួយនៃឯកសារនេះ ដែលសហព្រះរាជអាជ្ញាបានលុបចោល ដោយសារថាឃ្លានេះយ៉ាងដូច្នេះ សូមដកស្រង់៖ “យើងអាចក្លាយទៅជា -- យើងអាចមានម្ចាស់ការ គឺយើងត្រូវ -- លុះណាតែយើងអប់រំមហាជននៅតាមបណ្តាក្រសួង មន្ទីរ និងក្នុងអង្គភាពកងទ័ព សហករណ៍ និងអង្គភាពនានា។ល។ ហេតុដូច្នោះមិនត្រូវគិតតែអំពីគណៈកម្មការនានានោះទេ លុះណាតែពេលណាមហាជនជ្រួតជ្រាប មហាជនដែលជាផ្នែកជាច្រមុះរបស់យើង នោះយើងនឹងអាចការពារ និងអាចក្លាយទៅម្ចាស់ការបានទេហើយ”។ ដូច្នេះនៅក្នុងទង់បដិវត្តចុះខែមិថុនា ឆ្នាំ៧៦ ដែលយើងបានពិភាក្សាខាងដើមនោះគឺពាក្យថា “ការការពារ” នោះគឺវាមកអំពីការអប់រំនោះឯង។ ជាថ្មីម្តងទៀត នេះមិនមានន័យអ្វីពាក់ព័ន្ធទៅនឹងការប្រើប្រាស់អំពីហិង្សានោះទេ។

[១០:២១:២៥]

ឯកសារបន្ទាប់ទៅទៀត គឺសុន្ទរកថារបស់ ប៉ុល ពត នៅក្នុងទង់បដិវត្តកម្ពុជាចុះខែកក្កដា ឆ្នាំ ១៩៧៥ ឯកសារនេះគឺ E3/5។ ហើយជាថ្មីម្តងទៀត គឺមិនមានការណែនាំណាមួយតាមបក្សកុម្មុយនីស្តកម្ពុជា នៅពេលបក្សកុម្មុយនីស្តឈ្នះសង្គ្រាមហើយ ដែលគេថាត្រូវតែ គឺថាត្រូវតែបន្តតាមដានប្រុងប្រយ័ត្នចំពោះសមាសភាពប្រឆាំងទៅនឹងបដិវត្តន៍។

នៅសុន្ទរកថា ដែលសហព្រះរាជអាជ្ញាបានលើកឡើងថា “ពិត ឬមិនពិតនោះ” គឺមិនពិតនោះទេ។ បេសកកម្មរបស់កងទ័ព -- សូមដកស្រង់៖ “គឺដើម្បីការពារប្រទេស”។ តើវាមិនពិតទេឬ ដែលថាចក្រពត្តិហើយនិងពួកអាណានិគមនៅតែបន្តគំរាមកំហែងមកដល់ប្រទេសកម្ពុជា មកដល់សង្គមនិយម

នៅក្នុងខែមេសា ឆ្នាំ១៩៧៥? វាមិនពិតនោះទេឬ ដែលថាពួកមូលធននិយម សក្តិភូមិនៅតែបន្តប្រឆាំងជាមួយបដិវត្តន៍កុម្មុយនីស្តរបស់យើងក្រោយពីយើងទទួលបានអំណាចហើយនោះ? តើវាមានឧក្រិដ្ឋកម្ម ឬ ក្នុងការដែលយើងត្រូវតែតាមឃ្លាំ តាមដានប្រឆាំងទៅនឹងការគំរាមកំហែងផ្ទៃក្នុង ឬក៏ពីរដ្ឋប្រទេស? តើគេអាចចោទប្រកាន់បានទេក្នុងនាមជាប្រទេសមួយដែលថា ដែលមិនមានការយកចិត្តទុកដាក់ឬក៏យ៉ាងណានោះ? ហើយតើវា -- មិនមែនជាសេចក្តីណែនាំនោះទេដែលគ្រាន់តែយើងឲ្យយើងគឺថាធ្វើការប្រុងប្រយ័ត្នចំពោះបដិវត្តន៍។ ជាពិសេសឃ្លាបន្ទាប់ ដែលជាសម្រង់មួយសហព្រះរាជអាជ្ញាបានអានហើយនិងសូមដកស្រង់ -- ប៉ុល ពត បាននិយាយរៀបរាប់អំពីទិសដៅរបស់ពួកសក្តិភូមិ ពួកមូលធន។ សូមដកស្រង់ ៖“ការបំផ្លិចបំផ្លាញបដិវត្តន៍ ការកម្ទេចបដិវត្តន៍ គឺជាការដណ្តើមអំណាចពីយើងទៅវិញ”។ លើកលែងអត្ថន័យនៃពាក្យថា “កម្ទេច” វាផ្លាស់ប្តូរអត្ថន័យពីឃ្លាមួយទៅអត្ថបទ*(ឮមិនច្បាស់)* គឺថាមិនមានបញ្ហាទាល់តែសោះ ដែលថាពាក្យហ្នឹងមានចេតនាណាមួយនោះ ដែលអាក្រក់ណាមួយនោះទេ។

[១០:២៣:៥៤]

ដោយសារតែពេលវេលា ខ្ញុំសូមបង្ហាញឯកសារមួយចុងក្រោយ។ ខ្ញុំអាចផ្អាកត្រឹមនេះសិនក៏បាន លោកប្រធាន ឬក៏សូម ឬក៏អាចបន្តទៅទៀត?

**ប្រធានអង្គជំនុំ៖**

នៅ៥នាទីទៀត អាចបន្តបានមួយឯកសារទៀតបាទ។

**លោក វ៉ិចទ័រ កូប៉េះ**

ឯកសារចុងក្រោយ គឺខ្ញុំសូមបង្ហាញ និយាយ -- គឺឯកសារទាក់ទងទៅនឹងសារទូលេខ ដែលជាផ្នែកមួយដ៏សំខាន់នៃការពិភាក្សានោះ។ គឺវាមានពីទំព័រ៧៩ ទៅដល់ ទំព័រ៩៥ ដែលមានចុះជាភាសាអង់គ្លេស ចុះខែមិថុនា, ប្រតិចារឹកចុះថ្ងៃទី២៥ ខែមិថុនា។ ខ្ញុំនឹងមិនបង្ហាញឯកសារទាំងអស់នេះទេ ដោយសារឯកសារភាពច្រើនវាស្ថិតនៅក្រៅវិសាលភាពនៃអង្គជំនុំជម្រះ។

[១០:២៤:៤៥]

ហេតុផលដែលខ្ញុំយកមកយោងនៅពេលនេះ គឺដោយសារថាវាជាឯកសារគាំទ្រពាក់ព័ន្ធទៅនឹងគណៈកម្មការ៨៧០ ឬក៏អង្គការនោះ។ ចំពោះអ្វីដែលអង្គជំនុំជម្រះបានសម្រេចថា សារទូលេខទាំងអស់នេះគឺមានបំណងបញ្ជូនទៅឲ្យ នួន ជា។ នៅក្នុងចំណោមទាំងអស់នេះគឺថាគឺថាគេត្រូវបានពិចារណាពាក់ព័ន្ធទៅនឹងបញ្ហានៃតួនាទីរបស់គាត់។ ខ្ញុំដែលបានធ្វើការបង្ហាញយ៉ាងវែងឆ្ងាយនៅថ្ងៃទី២៧ ខែ

មិថុនា។ ហើយការពិតទៅក្នុងបណ្ដាសារទូរលេខទាំងអស់នោះគឺត្រូវបង្ហាញ ហើយជាថ្មីម្ដងទៀតនៅថ្ងៃទី០៧ ខែមិថុនា។ ហើយជាពិសេសគឺឯកសារនេះត្រូវបានលើកឡើងដោយសហការីរបស់ខ្ញុំ គឺលោក សុន អរុណ ប៉ុន្តែចាប់តាំង -- នៅក្នុងបណ្ដាឯកសារទាំងអស់នេះ ហើយសហការីក៏នឹងលើកឡើងដូចគ្នានោះដែរ។

មានសារទូរលេខចំនួន១៥ ដែលត្រូវបានយកមកបង្ហាញនៅក្នុងផ្នែកនៃសវនាការនេះ។ គឺឯកសារទី១ ចុះខែមិថុនា ១៩៧៦ គឺ E3/871។ ខ្ញុំគិតថា អង្គជំនុំជម្រះបានពិនិត្យមើលឯកសារមួយចំនួន ហើយថាមិន -- ឯកសារខ្លះគឺថាមិនមានប្រយោជន៍អ្វីនោះទេ។

ឯកសារបន្ទាប់ដែលមិនបានចម្លងជូនទៅ នួន ជា នោះគឺឯកសារចុះខែសីហា ១៩៧៦។ ឯកសារបន្ទាប់មកទៀតនេះ គឺចុះខែមីនា ១៩៧៧។ ដូចជារួមគឺសហព្រះរាជអាជ្ញាមិនបានរកឃើញនូវឯកសារណាមួយយកមកបង្ហាញអំពីតួនាទីរបស់កូនក្ដីរបស់យើងខ្ញុំ ទាក់ទងទៅនឹងខ្មាំងនៅក្នុងយុត្តាធិការពេលវេលានៃសវនាការនេះទេ។ ឯកសារបង្ហាញពីដំបូងៗគឺប្រហែលជា២ឆ្នាំ បន្ទាប់ពីទួលពោធិ៍ជ្រៃ ដែលជាការចោទប្រកាន់នៅក្នុងសវនាការនេះ ទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណខ្មាំង។

[១០:២៦:៤៧]

ចំណុចទី២ ដែលខ្ញុំចង់លើកឡើង គឺមិនមានឯកសារណាមួយបង្ហាញថា នួន ជា បានធ្វើសកម្មភាពណាមួយណានោះទេ វាគ្រាន់តែបង្ហាញថាគាត់ទទួលឯកសារនេះតែប៉ុណ្ណឹង។ ហើយមិនអាចនិយាយអ្វីឲ្យលើសពីនេះទេ គឺថាការនិយាយពីខ្មាំងគឺមិនមានពាក់ព័ន្ធនោះទេ។ ខ្ញុំគ្រាន់តែលើកឡើងអំពីការកត់សម្គាល់ជាក់លាក់មួយចំនួនក្នុងចំណោមការកត់សម្គាល់ពីរ។

ឯកសារនៅក្នុងរបស់ព្រះរាអាជ្ញា ទាក់ទងទៅនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួមចំពោះខ្មាំង។ ដើម្បីបញ្ចប់ការឆ្លើយតបរបស់យើងខ្ញុំ ឯកសារទាំងអស់នេះ ត្រូវតែស្ថិតនៅក្នុងបរិបទមួយឲ្យមានលក្ខណៈទូលំទូលាយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៨នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការអត្ថាធិប្បាយ ឬក៏ធ្វើការកត់សម្គាល់លើបណ្តាឯកសារគន្លឹះដាក់ឡើងដោយភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំទទួលដំណឹងថា ខ្ញុំអានលឿនពេកដោយសារអ្នកបកប្រែតាមមិនចង់ទាន់។ ដូច្នេះខ្ញុំត្រូវតែអានឲ្យយឺតបន្តិច ប្រសិនបើខ្ញុំលឿនពេកសូមឲ្យដំណឹងខ្ញុំផងបាទ។

លោកប្រធាន លោក លោកស្រីចៅក្រម មុនសម្រាកនេះ ខ្ញុំបានធ្វើសេចក្តីសន្និដ្ឋាន ខ្ញុំបានបញ្ចប់ការពិភាក្សានីមួយៗ ឯកសាររបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួមប្រឆាំងនឹងខ្មាំង។ ដើម្បីបញ្ចប់ការឆ្លើយតបរបស់យើងខ្ញុំ ឯកសារទាំងអស់នេះតាមពិតត្រូវតែដាក់នៅក្នុងបរិបទទូលំទូលាយជាងនេះ សេចក្តីបញ្ជាក់អំពីអ្វីដែលគេហៅថា “ខ្មាំង” ដែលធ្វើឡើងដោយ ឬក៏ក្នុងនាមបក្សកុម្មុយនីស្តកម្ពុជា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពុំមានអ្វីខុសគ្នាអំពីវោហាសាស្ត្រដែលគេប្រើប្រាស់មេដឹកនាំពិភពលោកផ្សេងៗនោះទេ។

[១០:៥៤:០៥]

គំនិតដែលបក្សកុម្មុយនីស្តកម្ពុជាមាននយោបាយសម្លាប់ខ្មាំងនោះ គឺអ្វីដូចដែលនិយាយថា រដ្ឋនីមួយៗមានយោធា ហើយមាននយោបាយពីរឿងសង្គ្រាម។ ការការពាររដ្ឋាភិបាល ហើយនិងពលរដ្ឋរបស់ខ្លួនទល់នឹងខ្មាំងក្នុង និងខ្មាំងខាងក្រៅនោះ គឺជាផ្នែកមួយនៃមុខងារដ៏សំខាន់របស់រដ្ឋនោះឯង។

សូមអនុញ្ញាត ហើយខ្ញុំនឹងនិយាយដោយសង្ខេបលោកប្រធានអំពី -- យើងខ្ញុំជូនជាឧទាហរណ៍មួយចំនួន។ សុន្ទរកថាដែលផ្សាយនៅក្នុងឆ្នាំ២០១១ លោកប្រធានាធិបតី ចច ប៊ូស គឺថាបានប្រកាស

 

ស្វែងរកខ្មាំង និងសម្លាប់ខ្មាំងរបស់សហរដ្ឋអាមេរិក។ រកថាតើអ្នកណាជាអ្នកធ្វើហ្នឹង? យើងនឹងតាមដានរកឲ្យឃើញ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:៥៥:១០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តីទទួលបានការណែនាំឲ្យកម្រិតឯកសារហើយនិងសេចក្តីថ្លែង។ ឥឡូវនេះគាត់បង្ហាញអំពីសុន្ទរកថារបស់មេដឹកនាំពិភពលោក ដែលមិនមែនជាភស្តុតាងដែលជាផ្នែកនៃសវនាការនេះទេ។ ហើយអ្វីដែលលើកឡើងគឺថា គាត់បានឃ្លាតឆ្ងាយពីវិសាលភាពដែលថាមិនមែនឆ្លើយតបទៅនឹងឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ដេញដោលទេ ឧទាហរណ៍ដែលមេធាវីលើកឡើងនេះ។

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយ គឺថាខ្ញុំមិនឆ្លើយតបទៅនឹងភស្តុតាងទេ ខ្ញុំនឹងបង្ហាញរូបភាពជាទូទៅ ជាបរិបទទូទៅ។ ខ្ញុំដកស្រង់ជាខ្លឹមសារប្អូនបន្ទាត់នោះទេ ដែលថាមេដឹកនាំពិភពលោកបាននិយាយ។ ហើយនេះគឺជាចំណេះដឹងការយល់ដឹងទូទៅ។ ខ្ញុំនឹងផ្តល់សេចក្តីដកស្រង់មួយពីរតទៅទៀត ដើម្បីបង្ហាញរូបភាពជាទូទៅដែលមិនបានបង្ហាញនៅក្នុងភស្តុតាងតែប៉ុណ្ណោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៦:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះការបង្ហាញរបៀបនេះរបស់មេធាវីការពារក្តីលោក នួន ជា គឺមានលក្ខណៈសមស្របហើយ។ ដូច្នេះ សូមមេធាវីជំទាស់ទៅលើបណ្តាឯកសារគន្លឹះដែលដាក់បង្ហាញដោយភាគីម្ខាងទៀត មិនគប្បីទៅលើកអ្វីនៅក្រៅវិសាលភាពនៃក្របខ័ណ្ឌឯកសារគន្លឹះដែលភាគីម្ខាងទៀតបានដាក់បង្ហាញកន្លងមកនោះទេ។

**លោក វិុចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំនឹងព្យាយាម។ ខ្ញុំមានសេចក្តីដកស្រង់ល្អៗជាងនេះ ខ្ញុំមិនដកស្រង់ទេ ប៉ុន្តែការ

ប៉ុនប៉ងរបស់ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបង្ហាញពីបរិបទទូលំទូលាយ គោលនយោបាយដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានិយាយទាក់ទងទៅនឹងខ្មាំង គឺថាវាស្រដៀងទៅនឹងអ្វីដែលសហរដ្ឋអាមេរិកបានធ្វើថ្មីៗនេះ ដូចជានៅក្នុងសង្គ្រាមលោកលើកទី២ ដែលទាក់ទងទៅនឹងការប៉ុនប៉ងទៅលើប្រជាជនជប៉ុនរបស់សហរដ្ឋអាមេរិកជាដើមនោះ។

[១០:៥៨:១៩]

ដូច្នេះ គួរឲ្យខកចិត្តបន្តិចដែរ ប៉ុន្តែខ្ញុំនឹងបន្តទៅមុខ។ ខ្ញុំនឹងនិយាយអំពីការកំណត់ទិសដៅប្រឆាំងនឹងទាហាន លន់ នល់។ លោកប្រធាន និងលោក លោកស្រីចៅក្រម! អ្វីដែលគេអះអាងថាជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់អតីតទាហាន និងមន្ត្រីរបស់ ទាហាន លន់ នល់នោះ ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ យើងបានជំទាស់អំពីគោលនយោបាយដែលបានអះអាងនេះ។ អ្វីដែលយើងបានស្តាប់កាន់តែច្រើនដែលសហព្រះរាជអាជ្ញាបានផ្តល់ជាភស្តុតាងនោះ យើងកាន់តែឃើញច្បាស់ យើងមិនឃើញថាមានភស្តុតាងអ្វីជាក់ស្តែងនោះទេ ហើយមិនមានគោលនយោបាយនោះដែរ។

យើងនឹងប្រើពេលបន្តិចដើម្បីនិយាយអំពីប្រធានបទនេះ។ ខ្ញុំសូមអនុញ្ញាត និងផ្តល់ជូននូវគម្រោងដែលអ្វីដែលខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះ។ យើងនៅមានបីផ្នែកដើម្បីជម្រាប ជូន។ ទី១ យើងនឹងផ្តល់នូវសេចក្តីសង្កេតទូទៅអំពីការកម្រិតនៃឯកសារភស្តុតាងចំពោះមុខអង្គជំនុំជម្រះ។ នេះគឺជាសេចក្តីសង្ខេបទូទៅអំពីចំណុចខ្សោយដែលយើងបានឃើញនៅក្នុងឯកសារទាំងនេះ។

ទី២ យើងនឹងពិនិត្យមើលឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញជូន។ យើងនឹងធ្វើយ៉ាងលម្អិត ហើយនិងព្យាយាមជម្រាបជូនអង្គជំនុំជម្រះថាតើចំណុចខ្សោយទាំងអស់នេះនឹងត្រូវយកមកអនុវត្តដូចម្តេចនៅក្នុងភស្តុតាងទាំងអស់នោះ។

[១១:០០:០៧]

ទី៣ យើងនឹងនិយាយបន្តិចអំពីការវិភាគផ្ទាល់ខ្លួនរបស់យើង ទាក់ទងទៅនឹងចម្លើយរបស់សាក្សីនៅក្នុងសំណុំរឿង ដែលបានដកស្រង់ពីខាងដើមដោយសហព្រះរាជអាជ្ញា។ យើងនឹងបង្ហាញថាចម្លើយទាំងអស់នេះ គឺមិនអាចជឿជាក់បានទេ ហើយមិនបាននិយាយខ្លឹមសារ ហើយក្នុងចំណុចមួយទៀត គឺវាមិនស្របទៅតាមការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាបក្សកុម្មុយនីស្តកម្ពុជាសំដៅ កំណត់យកមន្ត្រី ទាហានលន់នល់ របស់សាធារណរដ្ឋជាទិសដៅនោះ។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញអំពីយោបល់ទូទៅ ទាក់ទងទៅនឹងគំនិតនេះ។ ជួនកាលនៅក្នុងចំណុចដ៏សំខាន់បំផុតអំពីភស្តុតាងនៅក្នុងសំណុំរឿង គឺមិនបានដាក់បញ្ចូលទេ។ តើភស្តុតាងអ្វីដែលមិនបានដាក់បញ្ចូលនៅក្នុងរឿងក្តីនេះ។

[១១:០០:៤៥]

ចំណុចទី១ គឺដាក់បញ្ចូលនៅក្នុងការបង្ហាញរបស់សហព្រះរាអាជ្ញា គឺថាមានផ្នែកមួយនៃភស្តុតាងដែលថាមានទាហានណាម្នាក់ត្រូវបានសម្លាប់កន្លែងណាមួយនៅក្នុងកម្ពុជា។ គឺមិនមានការគាស់កកាយផ្នូរ រណ្តៅរួម ដែលមានការវិភាគដោយអ្នកជំនាញនោះទេ។ នេះគឺជាការអនុវត្តនៅក្នុងការស៊ើបអង្កេតមនុស្សឃាតនោះ។ ប៉ុន្តែនៅទីនេះយើងមិនមានស្តង់ដារបែបនោះទេ។ នៅក្នុងអតីតយូហ្គោស្លាវីអ្នកស៊ើបអង្កេតបានចុះទៅមូលដ្ឋាន បានជីករណ្តៅ គេរកឃើញសាកសពរួមជាមួយគ្នានៅក្នុងកន្លែងមួយ ហើយគេអាចកំណត់ថាតើគេសម្លាប់អ្នកណានៅកន្លែងណា? ដោយវិធីណា? នោះគឺជាភស្តុតាងនោះគឺវត្ថុតាង ដែលគេប្រមូលបាន។ ហើយចំណុចមួយទៀត ដែលថាឯកសារមិនរាប់បញ្ចូលនោះ គឺថាសាក្សីតែមួយដែលបង្ហាញអំពីការសម្លាប់ទាហានណាម្នាក់នោះ។

ឥឡូវនេះ យើងនិយាយអំពីបញ្ហានេះឲ្យបានលម្អិតនៅពេលក្រោយ នៅពេលដែលយើងពិនិត្យមើលភស្តុតាងនីមួយៗ ហើយយើងនឹងនិយាយអំពីចម្លើយសរបស់សាក្សីទាំងនោះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមអនុញ្ញាតដើម្បីជូនជាសេចក្តីសន្និដ្ឋានដំបូងមួយ: មិនមានសាក្សីណាម្នាក់បានឃើញការសម្លាប់តែមួយគ្មានផង ហើយនៅក្នុងការស៊ើបអង្កេតមនុស្សឃាតនៅក្នុង ធម្មតានៅក្នុងប្រព័ន្ធច្បាប់ជាតិ គឺថាមិនមានភស្តុតាងអំពីពេលវេលា ទីកន្លែង ឬក៏វិធីដែលសម្លាប់នោះ។ ហើយគេមិនអាចប្រើសម្តីបែបនេះដែលគ្មានមូលដ្ឋានដើម្បីធ្វើការកាត់ទោសនោះទេ។ កូនក្តីរបស់ខ្ញុំគឺថា រងការចោទប្រកាន់អំពីការសម្លាប់មនុស្សឃាតទ្រង់ទ្រាយធំ។ ដូច្នេះហើយ ភស្តុតាងត្រូវតែមានគ្រប់គ្រាន់មិនតិចជាងស្តង់ដារដែលយកមកអនុវត្តនៅក្នុងតុលាការនេះទេ។ គឺត្រូវតែខ្ពស់ស្តង់ដារអប្បបរមានោះឯង។

[១១:០៣:២០]

ក្នុងឋានៈជាមេធាវីការពារក្តី យើងមានការប៉ុនប៉ងក្នុងការបញ្ជាក់ថាភស្តុតាងនិយាយអំពីការគោលនយោបាយក្នុងការសម្លាប់ទាហាន លន់ នល់ និងមន្ត្រី លន់ នល់។ មិនមែន -- ភស្តុតាងនោះមិនមែនខ្លាំងនោះទេ គឺឯកសារភស្តុតាងគឺវាមានលក្ខណៈខ្សោយណាស់។ ខ្សោយហួសពេកដែលថាយើងស្ទើរតែយើងមិនអាចយកមកប្រើក្នុងសាលសវនាការបាន។ យើងក្រែងថា ការប្រើភាសាអង់គ្លេស

ថា គឺគេប្រើគោលដៅដំបូង គឺយើងបានប្រើស្តង់ដារបែបនេះដើម្បីនឹងកំណត់ ហើយយើងសុំជំរុញអង្គជំនុំជម្រះប្រយ័ត្នទូវការប្រើខ្លឹមសារនេះ ដើម្បីឲ្យធានាថាភស្តុតាងឯកសារនេះត្រូវកំណត់ឲ្យកម្រិតខ្ពស់ទៅតាមដែលច្បាប់កំណត់។

ខ្ញុំមិនចង់និយាយថា នៅក្នុងករណីមនុស្សជាតិមិនមានភស្តុតាងកាលៈទេសៈទេ គឺថាអាចប្រើបានកាលណាភស្តុតាងនោះវារឹងមាំ។ បើតាមពិត គឺថាយើងមិនមានភស្តុតាងផ្ទាល់បែបនោះទេ ដែលថានឹងមានប្រយោជន៍នោះ។ យើងគប្បីថា ធានាថាទាក់ទងទៅនឹងភស្តុតាងដែលអាចនឹងជឿជាក់បាន។ ដោយចាំនឹងគំនិតនេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលចំណុចខ្សោយ ចំណុចខ្វះខាតដែលស្ថិតនៅក្នុងឯកសារភស្តុតាងនោះ ទាំងនៅក្នុងចម្លើយរបស់សាក្សីនៅក្នុងឯកសារផងដែរ។ ចំណុចខ្វះខាត គឺថាមិនមានឯកសារណាមួយដែលសហព្រះរាអាជ្ញាបានលើកឡើងនោះ បាននិយាយអំពីអ្វី នៃការកាប់សម្លាប់នោះទេ។ គេនិយាយអំពីជនរងគ្រោះដែលគេអះអាងថា ត្រូវបានគេបំបែកយកទៅបាត់ ត្រូវបានចាប់ខ្លួនបញ្ជូនទៅអង្គការ។ ប៉ុន្តែគ្មានភស្តុតាងណាមួយដែលថាមនុស្សទាំងអស់នោះត្រូវបានសម្លាប់នោះទេ។ ហើយមិនមាន មួយក៏មិនមានផង។ ឯកសារទាំងអស់នោះមិនបានបង្ហាញពីភាពពាក់ព័ន្ធទេនៅក្នុងការជំនុំជម្រះនេះ។ អង្គជំនុំជម្រះត្រូវបានបង្ខំខ្លួនឲ្យសន្និដ្ឋានថា ដោយសារថាមានការទិសដៅទៅលើមនុស្សគឺជាចាំបាច់ត្រូវតែមានការកាប់សម្លាប់នោះហើយ។ ប៉ុន្តែការយោងបែបនេះ គឺវាមានលក្ខណៈធ្ងន់ធ្ងរហួសហេតុពេក ហើយមិនមានភស្តុតាងគាំទ្រទេ។ ហើយនៅក្នុងការអះអាង គឺថាការបំពាន ការយោងបែបនេះ គឺមិនអាចមានប្រៀបនោះទេ។ នេះគឺមធ្យោបាយជាច្រើនដែលយើងអាចបង្ហាញថា ការបំពានទៅលើការត្រឹមតែមានគោលនយោបាយប៉ុណ្ណោះ។ ដូច្នេះខ្ញុំសូមជូនជាឧទាហរណ៍ដោយសង្ខេបបី។

[១១:០៦:០៨]

ឧទាហរណ៍ទី១ គឺចេញពីសាក្សីដែលបង្ហាញ មកធ្វើសក្ខីកម្មថ្មីៗនេះឯង។ គាត់ឈ្មោះ នូ មោក គឺថានៅថ្ងៃទី២០ ខែមិថុនា សហព្រះរាជអាជ្ញាបានសួរដេញដោល នូ មោក បានរៀបរាប់អំពីហេតុការណ៍មួយ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអភ័យទោសលោកប្រធាន ដែលខ្ញុំបានក្រោកឈរម្តងជាថ្មីទៀត ប៉ុន្តែនេះគឺជាចំណុចមួយ

ដែលខ្ញុំលើកឡើងចាប់ពីចំណុចចាប់ផ្ដើមដែលថាមេធាវីការពារក្ដី ខ្ញុំជឿថាទៅឆ្ងាយអំពីគោលបំណងនៃសវនាការនេះ។ យើងនឹងមានសេចក្ដីសន្និដ្ឋានបិទ។ ដូច្នេះមេធាវីមិនអាចលើកឡើងបញ្ហាផ្សេងៗអំពីបន្ទុកនៃការបង្ហាញភស្ដុតាង និយាយអំពីសក្ខីកម្មសាក្សី។ នេះមិនទាន់ដល់ពេលក្នុងធ្វើសក្ខីកម្មបិទការដេញដោលនោះទេ។ ឥឡូវនេះមេធាវីប៉ុនប៉ងអានពីផ្នែកមួយនៃខ្លឹមសារនៃសក្ខីកម្មរបស់សាក្សីដែលជាបន្ទុកនៃការបង្ហាញភស្ដុតាង។ គឺថានេះមិនមែនជាគោលបំណងនៃសវនាការរឿងក្ដីព្រហ្មទណ្ឌ។ ដូច្នេះយើងខ្ញុំសូមជំទាស់ការអានសក្ខីកម្មរបស់ការជំនុំជម្រះ ហើយធ្វើយោបល់ទៅរឿងនេះ។

[១១:០៧:៣៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន គោលបំណងរបស់ខ្ញុំ គឺគ្រាន់តែរៀបជាឃ្លាប្រយោគមួយ ឬពីរអំពីប្រតិចារឹកនៃសវនាការ។ ខ្ញុំមិនទាន់ធ្វើសេចក្ដីសន្និដ្ឋានបិទទេ ខ្ញុំចង់បង្ហាញភស្ដុតាងអំពីតម្លៃជាភស្ដុតាងនៃឯកសារដែលថាខ្ញុំប្រើសាក្សីតែម្នាក់ដើម្បីជាគំរូ។ នេះជាបរិបទដែលទាក់ទងទៅនឹងតម្លៃជាភស្ដុតាង ហើយខ្ញុំមិនធ្វើសក្ខីកម្មសន្និដ្ឋានបញ្ចប់ការដេញដោលអំពីភស្ដុតាងរបស់ នួ មោក នោះទេ។ គ្រាន់ប្រើជាគំរូដើម្បីបង្ហាញថាតើវាមានតម្លៃជាភស្ដុតាងដែរឬអត់។ នេះហើយជាគោលបំណងខ្ញុំ មិនមានអ្វីលើសពីហ្នឹងទេ។

[១១:០៨:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១០:០៨]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា អំពីវិធីសាស្ត្រក្នុងការបង្ហាញ អត្ថាធិប្បាយ ឬការកត់សម្គាល់របស់មេធាវីការពារក្ដីលោក នួន ជា, សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាហ្នឹងមានលក្ខណៈសមស្រប។ លោកមេធាវីសូមលោកធ្វើការអត្ថាធិប្បាយ ឬក៏ធ្វើការកត់សម្គាល់ពាក់ព័ន្ធនឹងបណ្ដាឯកសារគន្លឹះដែលភាគីបានដាក់ចំពោះមុខអង្គជំនុំជម្រះ មិនគប្បីដកស្រង់នូវសក្ខីកម្មរបស់សាក្សីមកផ្ទះបញ្ចាំង ឬក៏មកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះទេ។ ព្រោះពេលនេះគឺជាការឆ្លើយតប ឬអត្ថាធិប្បាយតបទៅនឹងបណ្ដាឯកសារគន្លឹះ ដែលដាក់ដោយភាគីម្ខាងទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំមានចេតនានឹងផ្ដល់ឧទាហរណ៍បួន បង្ហាញអំពីការគ្រោះថ្នាក់ក្នុងការ

យោងទៅរកភស្តុតាងនៃការធ្វើមនុស្សឃាត ខ្ញុំជូនជាឧទាហរណ៍បី។ ខ្ញុំនិយាយតែពីករណី នូ មោក។ ឧទាហរណ៍ទី២ គឺដូចខាងក្រោមនេះ គឺជាឧទាហរណ៍អំពីសារទូរលេខដែលសហព្រះរាជអាជ្ញាបានបង្ហាញ គឺឯកសារ E3/807។ ហើយយើងនឹងនិយាយអំពីការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាឯកសារនេះមានលក្ខណៈដូចម្តេច ប៉ុន្តែពេលនេះខ្ញុំនឹងចង្អុលបង្ហាញអង្គជំនុំជម្រះនូវប្រយោគនៅក្នុងឯកសារនេះ។

[១១:១១:៤៥]

ឯកសារនោះនិយាយថា សូមដកស្រង់៖ "កុមារជាយោធា ប្រធានស្រុក ហើយនិងនគរបាលនឹងត្រូវបានបោសសម្អាត ហើយបញ្ជូនទៅឱ្យបង្កបង្កើនផលនៅកន្លែងមួយ"។ អ្វីដែលយើងចាប់អារម្មណ៍គឺថាពាក្យ "បោសសម្អាត" ឯកសារជាច្រើននៅក្នុងនេះគឺប្រើពាក្យ "បោសសម្អាត"។ ជាពិសេសសហព្រះរាជអាជ្ញាបានស្នើឱ្យអង្គជំនុំជម្រះបកស្រាយថា ពាក្យនេះមានន័យថា "សម្លាប់"។ ប៉ុន្តែជាក់ស្តែងគឺថាមិននិយាយបែបនេះទេក្នុងឯកសារនេះ។ ជាក់ស្តែងនេះមាននិយាយថា គ្រាន់តែថា "បំបែក" ពីព្រោះគេមិនអាចសម្លាប់ ហើយបញ្ជូនឱ្យទៅបង្កបង្កើនផលបានទេបើមានន័យថា "សម្លាប់" នោះ។

ឧទាហរណ៍ទី៣ -- ឧទាហរណ៍ទី២ នោះគឺពីសៀវភៅរបស់ ហ្វីលីព ស្ស៊ត គឺឯកសារ E3/9។ ខ្ញុំនឹងដកស្រង់អំពី ERN ជាភាសាអង់គ្លេស 00396488។ មិនមានអត្ថបទខ្មែរបកប្រែទេ សូមអភ័យទោស ហើយខ្ញុំក៏មិនមាន ERN ជាភាសាបារាំងដែរ។

[១១:១២:៥២]

អនុលោមតាមលោក ស្ស៊ត គឺក្នុងពេលជម្លៀសកម្មករទីក្រុងភ្នំពេញនោះ គឺត្រូវបានបំបែកចេញពីប្រជាជនទូទៅ ស្ស៊ត និយាយថា "ប៉ុន្តែមានអ្វី យើងមិនឮច្រើនទេថាពួកគេនោះបានសម្លាប់នោះទេ"។ តាមពិតលោក ស្ស៊ត និយាយថាភាគច្រើនគេយកមកឱ្យភ្នំពេញ ដើម្បីឱ្យមកបង្កបង្កើតផលនៅរោងចក្រដែលគេធ្វើការពីមុននោះដដែលវិញទេ។

ឧទាហរណ៍មួយទៀតលោកប្រធាន នោះគឺថាដែលយើងឃើញពីខាងដើមហើយ ដែលពាក្យប្រើថា "កម្ទេច" មិនមែនមានន័យថា "សម្លាប់" នោះទេ។ យើងបានបង្ហាញនៅក្នុងការពិភាក្សាឯកសារ E3/5។ ការកម្រិតនៅក្នុងភស្តុតាងនោះ ថាបែបនេះ គឺថាមិនមានភស្តុតាងផ្ទុយអ្វីនោះទេ។ អង្គជំនុំជម្រះមិនអាចនឹងធ្វើការកត់សម្គាល់នៅក្នុងសេចក្តីសន្និដ្ឋានដែលថាមានគោលនយោបាយទូទាំងប្រទេសដើម្បីសម្លាប់ខ្មែរទាហានសាធារណរដ្ឋខ្មែរនោះទេ។ ប៉ុន្តែមានភស្តុតាងផ្ទុយ ដែលថាភស្តុតាងរបស់សហ

ព្រះរាជអាជ្ញាគឺមិនត្រឹមត្រូវទេ។ ភស្តុតាងផ្ទុយបានបង្ហាញច្បាស់ថា មជ្ឈិមបក្សបាននិយាយយ៉ាងច្បាស់ កងកម្លាំង ហើយនិងកម្មាភិបាលមិនឲ្យសម្លាប់ទាហាន ហើយនិងមន្ត្រីរដ្ឋការសាធារណរដ្ឋទេ។ ហើយ យើងនឹងអានចម្លើយទាំងអស់នោះ សេចក្ដីថ្លែងការណ៍ទាំងអស់នេះនៅព្រឹកនេះ ឬក៏អាចនៅល្ងាចនេះ។

[១១:១៤:២៥]

មានចម្លើយពីមនុស្សជាច្រើន ដែលធ្វើការជិតស្និទ្ធជាមួយ ប៉ុល ពត, នួន ជា ហើយអ្នកដទៃទៀត ដែលស្ថិតនៅក្នុងស្នូលនៃមជ្ឈិមបក្ស។ នេះជាមនុស្សដែលពឹងផ្អែកម្ដងហើយម្ដងទៀតទៅលើសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ គេពឹកផ្អែកទៅលើអ្នកជំនាញ ដែលអង្គជំនុំជម្រះបានកោះអញ្ជើញថាជាសាក្សីសំខាន់ ជាសាក្សីផ្ទៃក្នុង ហើយពួកគេបាននិយាយថា "ទេ! មិនមែន ប៉ុល ពត និង នួន ជា នោះមិនបានធ្វើការបញ្ជាឲ្យសម្លាប់នោះទេ"។ ចម្លើយទាំងអស់នោះគឺថា ការណែនាំគឺមិនឲ្យសម្លាប់ទាហានដែលចាប់នៅក្នុងសមរភូមិទេ។

ឯកសារមិនគ្រប់គ្រាន់ដែលមានកំហុសរបស់សហព្រះរាជអាជ្ញានោះ គឺមានភស្តុតាងទី១នោះដែរ។ ទាំងអស់នោះគឺសាក្សីជាអ្នកដឹងពីអង្គហេតុដែលគេបានប្រាប់ដល់អង្គជំនុំជម្រះ។ នេះជាសេចក្ដីសន្និដ្ឋានទូទៅ។

ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីឯកសារជាក់លាក់ដែលសហព្រះរាជអាជ្ញាបានដាក់បង្ហាញ។ ខ្ញុំនឹងចាប់ផ្ដើមក្នុងការដកស្រង់នៅលើពាក្យមួយចំនួននៅក្នុងបទបង្ហាញរបស់សហព្រះរាជអាជ្ញានោះ។ សហព្រះរាជអាជ្ញាបាននិយាយដូចខាងក្រោមនេះ។ នៅទំព័រ៩៨ នៃប្រតិចារឹកព្រៀងថ្ងៃទី២៦ ខែមិថុនា។ ខ្ញុំសូមដកស្រង់ "ឥឡូវនេះខ្ញុំត្រឡប់ទៅឯកសារដែលឆ្លើយនូវសំណួរដែលមេធាវី នួន ជា បានសួរជាច្រើនពេល គឺថានេះជាឯកសារដែលបានបង្ហាញអំពីគោលនយោបាយសំដៅទៅរកមន្ត្រី និងទាហាន លន់ នល់"។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១១:១៦:១៥]

ឥឡូវនេះ លោក លោកស្រីចៅក្រម ខ្ញុំបានឮ ខ្ញុំបានភ្ញាក់ផ្អើលណាស់នឹងពាក្យនេះ។ ខ្ញុំចាំថា ខ្ញុំអង្គុយនៅកន្លែងនេះគឺថាខ្ញុំផ្អែកបន្តិច ហើយខ្ញុំគិតថាដោយមានមូលហេតុមួយចំនួនឬយ៉ាងម៉េច? មួយនោះគឺថាសហព្រះរាអាជ្ញាបានស្ដាប់យើងដែរឬទេ? យើងមិនច្បាស់ពីរឿងនេះទេពីមុនមកនោះ។ ប៉ុន្តែសហព្រះរាជអាជ្ញាបានចំណាយពេលជាច្រើនក្នុងការបង្ហាញឯកសាររបស់ខ្លួន អំពីគោលនយោបាយដែលខ្លួនអះអាងថាតម្រង់ទៅរកមន្ត្រី លន់ នល់ នោះ។ ឥឡូវយើងពិនិត្យឃើញថា យើងតាមពិតយើង

ពីទំព័រដូចគ្នានោះឯង។ យើងមានការព្រួយបារម្ភថាតើមានការភស្តុតាងជាក់ស្តែងឬទេ ដែលថាមានគោលនយោបាយបែបនេះនោះ។

មូលហេតុទី២ ដែលខ្ញុំភ្ញាក់ផ្អើលនោះគឺថា ខ្ញុំចង់ឲ្យអង្គជំនុំជម្រះបានស្តាប់អ្វីដែលមានសារ-ប្រយោជន៍នោះ ហើយសហព្រះរាជអាជ្ញាបានបង្ហាញថា នេះហើយជាឯកសារដែលលោកបាន -- ដែលអង្គជំនុំជម្រះកំពុងរង់ចាំ។ ហើយគឺជាការភ្ញាក់ផ្អើល ហើយខ្ញុំត្រូវសហព្រះរាជអាជ្ញាបង្អាក់ ដោយហេតុថាសហព្រះរាជអាជ្ញាពិតជាបង្ហាញនូវភស្តុតាងរបស់គេមែន។ នៅលើអេក្រង់ ឯកសារទាំងអស់នោះ គឺមិនបាន មិនបង្ហាញតុលាការនូវភស្តុតាងបន្តិចសោះនោះទេ ដែលថាអ្នកណាម្នាក់នៅមជ្ឈិមបក្សអាចនឹងបានពាក់ព័ន្ធនឹងគោលនយោបាយនៅក្នុងសម្រេចអតីតទាហានមន្ត្រីសាធារណរដ្ឋខ្មែរនោះទេ។ តាមពិតនៅក្នុងសេចក្តីដកស្រង់នោះ ដែលសហព្រះរាជអាជ្ញាបានដកស្រង់នៅតុលាការនោះ ជួនកាលមិនបានបង្ហាញបែបនោះ តែបង្ហាញថាមជ្ឈិមបក្សមិនមានគោលបំណង និងសម្លាប់អ្នកទាំងអស់នោះទៅវិញ។

[១១:១៨:២០]

ដើម្បីបង្ហាញពីនេះ គឺក្នុងឯកសារនេះ គឺខ្ញុំនឹងនិយាយលម្អិត។ ខ្ញុំពិនិត្យមើលនៅក្នុងលំដាប់លំដោយដែលសហព្រះរាជអាជ្ញាបានបង្ហាញនូវឯកសារទាំងអស់នោះ។ ទី១ សហព្រះរាជអាជ្ញាបានបង្ហាញឯកសារពីរដែលមានបង្ហាញអំពីមូលដ្ឋានមនោគមន៍វិជ្ជា អំពីគោលនយោបាយដែលខ្លួននិយាយថាតម្រង់ទៅរកមន្ត្រីរាជការលន់នល់។ គឺថាឯកសារទី១ គឺថាទង់បដិវត្តនៅក្នុងឆ្នាំ១៩៧៤ គឺថាឯកសារ E3/146។

ឯកសារទី២ គឺឯកសារទង់បដិវត្តឆ្នាំ១៩៧៦ ខែតុលា។ ឯកសារនោះ គឺ E3/10។ ខ្ញុំសូមបញ្ជាក់អំពីសេចក្តីសង្កេតដែលខ្ញុំបានធ្វើពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឯកសារស្រដៀងគ្នានេះ ដោយពាក់ព័ន្ធទៅនឹងអ្វីដែលគេហៅថាគោលនយោបាយកម្ទេចខ្លាំងនោះ។ យើងឃើញច្បាស់ថាឯកសារទាំងអស់នេះ មិនសម មិនគ្រប់គ្រាន់ក្នុងការបង្ហាញពីអត្ថិភាពនៃគោលនយោបាយជាក់ស្តែងក្នុងការសម្លាប់មនុស្សណាក្រុមណាមួយនោះទេ។ គេគ្រាន់តែនិយាយពីសេចក្តីរៀបរាប់ទូទៅខ្លាំងអំពីការបែងចែកវណ្ណៈតែប៉ុណ្ណោះ។

[១១:១៩:៥១]

អង្គជំនុំជម្រះគប្បីតែពិនិត្យមើលការប្រើប្រាស់ឯកសារទាំងអស់នេះរបស់សហព្រះរាជអាជ្ញាថាតើវាចង្អុលបង្ហាញពីភាពខ្សោយនៃឯកសារទាំងមូលដែលជាភស្តុតាងហ្នឹង ត្រូវតែវាយតម្លៃដូចម្តេចនោះ។ ប៉ុន្តែទោះបីជាយើងទទួលស្គាល់ថានេះជាឯកសារតាមពាក្យរបស់សហព្រះរាជអាជ្ញានោះក៏ដោយ

យើងនឹងពិនិត្យមើលថា មិនបានបង្ហាញពីអ្វីដែលត្រឹមត្រូវជូនអង្គជំនុំជម្រះពីអ្វីដែលឯកសារនោះនិយាយទេ។ ពួកគាត់បានដកស្រង់នៅក្នុងចំណុចមួយដែលធ្វើឲ្យមានការភ័ន្តច្រឡំពីអត្ថន័យ។ យើងអាចនឹងសន្និដ្ឋានអំពីថា មិនបានយកខ្លឹមសារទាំងស្រុងនោះទេ។ ដូច្នេះមេធាវីការពារក្ដីមិនមានពេលពិនិត្យនូវឯកសារទាំងនោះទេ។ សហព្រះរាជអាជ្ញាបានប្រើឯកសារ E3/146 និយាយអំពីវណ្ណៈពីរយ៉ាង គឺវណ្ណៈសក្តិភូមិ ហើយនិងវណ្ណៈបញ្ញវន្ត ហើយនិងនាយទុននិយម។

[១១:២១:០៥]

ដែលសហព្រះរាជអាជ្ញានិយាយត្រូវ -- នៅក្នុង ERN ជាភាសាអង់គ្លេស 00538746, ខ្មែរ 00283409, ហើយបារាំង 00611810។ ឯកសារបានកំណត់និយមន័យនៃវណ្ណៈសក្តិភូមិដែលរាប់បញ្ចូលទាំងស្តេច ហើយនិងមន្ត្រីថ្នាក់ខ្ពស់ដូចជារដ្ឋមន្ត្រី អភិបាលខេត្ត អភិបាលស្រុករហូតទៅដល់មេឃុំជំទប់។ល។ សហព្រះរាជអាជ្ញាបានផ្តោះចោលមួយទំព័រមួយ ហើយយើងមិនភ្ញាក់ផ្អើលទេ ហើយគាត់និយាយថា សូមដកស្រង់៖ “អាកប្បកិរិយារបស់យើងទាក់ -- សំដៅលើក្រុមទាំងអស់នេះ យើងត្រូវបញ្ចុះបញ្ចូលពួកគេឲ្យចូលចលនា ចូលរណសិរ្ស ហើយលុបបំបាត់ជំហរនយោបាយរបស់គេ ហើយមនោគមន៍ចាស់របស់គេ ហើយអប់រំជាបន្តបន្ទាប់ឲ្យគេកែខ្លួន។ ប៉ុន្តែនេះជាចំណុចសំខាន់ដែលយើងបានពិនិត្យការបែងចែក ហើយនិងពលកម្មឲ្យពួកគេ ដើម្បីឲ្យគេបង្កបង្កើនផល គាំទ្រពួកគេ” បញ្ចប់។

នៅក្នុងបន្ទាប់ ទំព័រខាងក្រោម ឯកសារនោះបានរៀបរាប់ពីប្រភេទនៃវណ្ណៈសក្តិភូមិ ដែលហៅថា “វណ្ណៈសក្តិភូមិមានដីធ្លី” ដែលនេះរាប់បញ្ចូលទាំង -- ដកស្រង់ “បុគ្គលដែលមានដី ហើយមានដីមានអំណាចត្រួតត្រាលើដី”។ សូមបញ្ចប់សេចក្តីដកស្រង់។ ហើយមួយកថាខណ្ឌនៅខាងក្រោមនិយាយថា សូមដកស្រង់ “យើងមិនគប្បីវាយទៅលើមនោគមន៍វិជ្ជា យើងត្រូវតែបញ្ចុះបញ្ចូលឲ្យចូលនៅក្នុងជួររបស់យើង។ យើងត្រូវតែតស៊ូឲ្យគេលុបចោល ហើយយើងត្រូវប្រើស្រែដូចដែលកសិករយើងមានដើម្បីបង្កបង្កើតផល”។ សូមចប់សេចក្តីដកស្រង់។

[១១:២៣:២០]

ដោយការផ្តោះចោលនូវចំណុចនេះ នៅទំព័រដ៏ចាប់អារម្មណ៍នេះ សហព្រះរាជអាជ្ញាធ្វើឲ្យមានការភ័ន្តច្រឡំ។ ឯកសារហ្នឹងគឺថា ដោយសារគាត់យោងទៅរកនិយមន័យអំពីបញ្ញវន្តនៅក្នុងនាយទុនលំដាប់ទី២, នៅក្នុងភាសាអង់គ្លេសគឺ 00538746, ខ្មែរ 00283409, បារាំង 00611810។ សហ

ព្រះរាជអាជ្ញាបាននិយាយត្រឹមត្រូវដោយបញ្ចូលវណ្ណៈនេះថា និស្សិត មន្ត្រីរាជការដែលគេប្រើថាជាបញ្ញវន្ត នៅក្នុងការរស់នៅ ប៉ុន្តែគាត់បានផ្តោះចោលនូវផ្នែកមួយខាងដើម មួយប្រយោគនោះនិយាយថា បើយើងដកស្រង់ទាំងមូលមានន័យថា៖ "វណ្ណៈនាយទុនទី២ និយាយជារួមនេះហៅថាគឺវណ្ណៈកណ្តាលមធ្យម ពួកគេមិនជិះជាន់អ្នកណាម្នាក់ គាបសង្កត់អ្នកណាម្នាក់ គេមានសេដ្ឋកិច្ចជាធម្មតា ហើយនិងមានទស្សនៈនយោបាយធម្មតា។ ពួកគេរស់ដោយសន្តិភាព។ មានប្រភេទពីរនៃនាយទុនថ្នាក់ទី២, ទី១គេហៅថានាយទុនទី២ ជាបញ្ញវន្ត មានរាប់បញ្ចូលទាំងនិស្សិត មន្ត្រីរាជការ ដែលប្រើនូវបញ្ញារបស់គេដើម្បីរស់រាន។ ចំណុចសំខាន់គឺថាពួកគេស្នេហាជាតិ គេស្រឡាញ់បដិវត្តន៍ គេចង់ធ្វើបដិវត្តន៍ដោយសារពួកគេ -- ក្នុងកម្រិតមួយនោះគេរងការគាបសង្កត់ពីខ្មាំង"។

ចំណុចសំខាន់មួយទៀតដែលខ្លាំងនោះ គឺថាយើងអាចយល់យើងអាចយល់ពីគំនិត និងទ្រឹស្តីរបស់គេឆាប់ៗ ប៉ុន្តែចំណុចខ្សោយគឺពួកគេខ្លាចការលំបាក។ គេចង់នៅដោយសុខ ហើយគេស្រួបយកមាគ៌ាបក្សឃើតពេក នេះគឺជាការដែលគេពិបាកនឹងទទួលការលំបាក។ ហើយគេនឹងរងការគាបសង្កត់យ៉ាងខ្លាំងពីខ្មាំងនោះ។ ការយកឯកសារ E3/10 ដោយសហព្រះរាជអាជ្ញានេះគឺថា គាត់មិនមានភាពស្មោះត្រង់ទាំងស្រុងនោះទេ។ មិនគួរ -- យើងឃើញថាមិនត្រឹមតែភ្ញាក់ផ្អើលប៉ុណ្ណោះទេ។ ក៏ប៉ុន្តែវាមិនបង្ហាញអ្វីជាសំខាន់ទេ តាមពិតគឺចង្អុលបង្ហាញពីការទទួលស្គាល់អំពីសក្តិភូមិ និងនាយទុន ហើយក៏យើងឃើញថា មន្ត្រីរដ្ឋាភិបាលមាន នគរបាល ទាហាន និស្សិត ក៏មិនមែនជាអ្នកញុះញង់នោះដែរ ប៉ុន្តែសក្តិភូមិ នាយទុន។ ដូច្នេះ គេបង្ហាញឲ្យពួកហ្នឹងបង្ហាញមុខ។ ពួកគេមិនមានអំណាច ហើយមានភ្នាក់ងារផ្សេងទៀតដែលនឹងត្រូវគេកំណត់ជាទិសដៅ។

[១១:២៦:៣៧]

នៅបន្ទាប់ សហព្រះរាជអាជ្ញាបានបង្ហាញសេចក្តីដកស្រង់បទសម្ភាសន៍របស់លោក អៀង សារី នៅក្នុងខែមេសា ឆ្នាំ១៩៧៨, ឯកសារនោះគឺ E3/707។ នៅក្នុងសេចក្តីដកស្រង់ដែលព្រះរាជអាជ្ញាបានលើកឡើងនោះ -- លោក អៀង សារី នោះ -- គឺថាសូមដកស្រង់៖ បានរៀបរាប់អំពីកម្លាំងផ្សេងៗនៅក្នុងកម្ពុជាដែលជាវណ្ណៈដឹកនាំនៅក្នុងពេលនោះ ដែលចង្អុលបង្ហាញថាមានក្រុម ការចងក្រងក្រុមបីធំៗ។ នៅខាងស្តាំមានអ្នកដូចជា លន់ នល់ ដែលជាប្រតិកិរិយាទាំងស្រុង ហើយជាបរិវាររបស់ចក្រពត្តិនិយមបរទេស។ នៅកណ្តាល សីហនុ ដែលជាប្រមុខរដ្ឋហើយមានមនុស្សមួយចំនួនចូលចិត្តព្រះអង្គដែលជាកុម្មុយនីស្តជំទាស់នោះ គឺថាដែលគាំទ្រគោលនយោបាយពិតប្រាកដនៃឯករាជ្យរបស់

ប្រទេស។ ហើយខាងឆ្វេង មានមនុស្សមួយចំនួនដូច ខៀវ សំផន ដែលបច្ចុប្បន្ននេះជាប្រធានគណៈប្រធានរដ្ឋ ដែលពេលមួយនោះគេស្គាល់គាត់ថាជាបញ្ញវន្តនិងអ្នកនយោបាយ។ សូមបញ្ចប់សេចក្តីដកស្រង់។

[១១:២៨:០៦]

លោក លោកស្រីចៅក្រម ខ្ញុំអាចនឹងចំណាយពេល១ថ្ងៃអំពីសេចក្តីដកស្រង់ទាំងអស់នេះ គឺថាដែលជាការលើកឡើងអះអាងនៅក្នុងការជំនុំជម្រះនេះ។ ជាដំបូងនោះគឺថាអ្វីដែលនិយាយនៅទីនេះគឺអំពីសមាជិកថ្នាក់ខ្ពស់ អំពីវណ្ណៈនយោបាយរបស់កម្ពុជា។គាត់ខ្លួនឯងហៅពួកគេថាជាវណ្ណៈដឹកនាំ មិនមាននិយាយអំពីទាហានលន់នល់ ឬក៏មន្ត្រីលន់នល់នោះទេ។ ចំណុចទី២ ជាថ្មីម្តងទៀតនោះគឺជាការវិភាគនយោបាយដែលមិនច្បាស់លាស់ មិនមានទំនាក់ទំនងថាទៅអ្នកណាម្នាក់ ទោះបី លន់ នល់ ខ្លួនឯងក្តីដែលត្រូវសម្លាប់នោះទេ។

ចំណុចទី៣ វាស្ទើរតែថាសហព្រះរាជអាជ្ញានោះភ្លេចហើយថា អៀង សារី បានរៀបរាប់នៅពេលនោះ ដែលថាគាត់ជាមេដឹកនាំម្នាក់ដែរនៅក្នុងចលនាបះបោរក្នុងពេលប្រយុទ្ធសង្គ្រាមស៊ីវិលប្រឆាំងនឹង លន់ នល់។ សហព្រះរាជអាជ្ញារំពឹងឲ្យ អៀង សារី ឲ្យបំពេញបន្ថែម ពេញចិត្តទៅនឹងជំនាញថ្នាក់ដឹកនាំរបស់ លន់ នល់ ទេ។ នៅក្រោមកាលៈទេសៈនេះគឺភាសានោះ គឺថាអាចនឹងរៀបរាប់បានជាបន្តិចបន្តួចប៉ុណ្ណោះ។

[១១:២៩:៣៧]

ចំណុចទី៤ អាចនឹងចំណុចសំខាន់។ តើអ្នកណាម្នាក់នៅទីនេះគឺថាឆ្ងល់ទេថា ការវិភាគអំពីលោក អៀង សារី នេះគឺតាមពិត លន់ នល់ គឺជាអ្នកកាន់ជើងសហរដ្ឋអាមេរិក។ តាមពិតគឺត្រូវដើរតាមនយោបាយនោះឯង ហើយក៏ជារដ្ឋាភិបាលមួយដែលមានអំពើពុករលួយភស្តុតាងជាច្រើនបង្ហាញគឺថាអ្នកដែលមានទ្រព្យធននៅក្នុងភ្នំពេញកាលណោះ ដែលសហព្រះរាជអាជ្ញាដែលត្រូវដាក់ថាបញ្ជីទី១ -- អ៎! ក្នុងបញ្ជីទី១នោះ គឺថាអាចនឹងមន្ត្រី លន់ នល់។ អៀង សារី ក៏បានជំទាស់។ លន់ នល់ គឺថាមិនមែនជាទិសដៅរបស់ ស៊ី.ភី.ខេ (បក្សកុម្មុយនីស្តកម្ពុជា) ទៅលើប្រជាជនណាមួយនោះទេ។ គឺមានចំណុចសំខាន់តែមួយគត់នៅក្នុងចំណុចនេះ។ អនុលោមតាម អៀង សារី គឺថាសម្តេច សីហនុ មិនមែនជាអ្នកនៅខាងឆ្វេងទេ ប៉ុន្តែគឺជាការគាំទ្រនៅក្នុងឯករាជ្យនៅកម្ពុជាតែប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៥ សម្តេច សីហនុ ក៏បានតំណាងឲ្យប្រជាជនមួយចំនួនធំនៅកម្ពុជា។ លន់ នល់ មិនតំណាងឲ្យប្រជាជនផ្នែកណាមួយ

ទាល់តែសោះ។

[១១:៣១:០៣]

សហព្រះរាជអាជ្ញាបានដកស្រង់ផ្នែកមួយទៀតនៅក្នុងឯកសារនេះ ដែលខ្ញុំនឹងបញ្ជាក់ឡើងវិញជូនអង្គជំនុំជម្រះ។ សូមដកស្រង់៖ "យើងប្រមូលផ្តុំផ្នែកដឹកនាំទាំងឆ្វេង និងទាំងកណ្តាល អៀង សារី និយាយ ហើយយើងកសាងឲ្យរួមរួបនៅក្នុងរណសិរ្សដើម្បីជៀសឲ្យរួចពីការគ្រប់គ្រងបរទេស។ ហើយយើងត្រូវផ្តាច់ជនក្បត់ពី លន់ នល់"។ ដូច្នេះយើងនឹងប្រើសេចក្តីដកស្រង់នេះ។

ហើយគួរឲ្យចាប់អារម្មណ៍ណាស់ដែលថា អៀង សារី បានរៀបរាប់មេដឹកនាំនយោបាយរដ្ឋាភិបាលដែលគាត់ចង់ផ្តួលនោះ ដែលថាជាជនក្បត់។ លន់ នល់ បានត្រូវបានទៅរស់នៅសហរដ្ឋអាមេរិកដើម្បី -- ដោយសារឲ្យប្រទេសបានរំដោះពីការទម្លាក់គ្រាប់បែក បេ-៥២។ ដូច្នេះហើយនៅក្នុងឆ្នាំ១៩៧៥ គេមិនបានជួប លន់ នល់ ជាជនក្បត់។ តើមានមនុស្សប៉ុន្មាននាក់ដែលថា លន់ នល់ មិនមែនជាអ្នកកាន់ជើងអាមេរិកាំងនោះ។ ម្នាក់ៗយល់ដែរឬទេថា លន់ នល់ ត្រូវចាប់ជាជនក្បត់ ហើយតើគេត្រូវសម្លាប់ម្នាក់ៗរបស់គាត់ទេ? ឯកសារនេះ គឺសមស្របទេទៅតាមខ្លឹមសារដែលលើកឡើងនោះទេ។

បន្ទាប់ សហព្រះរាជអាជ្ញាបានយោងទៅរកឯកសារមួយចំនួនដែលរៀបរាប់ពីសារដែលបញ្ជូនដោយខ្មែរក្រហមនៅក្នុងផ្នែកចុងក្រោយនៃសង្គ្រាមនោះ។ ខ្ញុំនឹងជម្រាបជូនឯកសារនេះដោយសង្ខេប។ ឯកសារ E3/783, E3/117, E3/334, E3/120 និង E3/118។ ឯកសារភាគច្រើនដែលត្រូវបានដកស្រង់ដោយសហព្រះរាជអាជ្ញានេះ បាននិយាយឡើងវិញថា អំពីការប្រកាសឲ្យមានការសម្លាប់ជនមហាក្បត់ទាំងប្រាំពីរ។ ឯកសារទាំងអស់នេះគឺថាបានលើកឡើងនៅក្នុងប៉ុន្មានថ្ងៃចុងក្រោយមុនឆ្នាំ១៩៧៥ ថ្ងៃទី១៧ ខែមេសានោះ។

[១១:៣៣:២១]

នៅទីបំផុតនោះ គឺថាខ្ញុំសូមជម្រាបជូនទាក់ទងទៅនឹងឯកសារដែលនិយាយអំពីជនមហាក្បត់ទាំងប្រាំពីរ សហព្រះរាជអាជ្ញាបានទទួចបញ្ជាក់ហើយម្តងហើយម្តងទៀតពីរឿងនេះ ប៉ុន្តែការអះអាងពីបទឧក្រិដ្ឋនេះ គឺមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនោះទេ ហើយសារដែលនិយាយពីបញ្ហានេះ គឺថាអ្នកណាម្នាក់នៅទីនោះ គឺនឹងត្រូវបានទុកជីវិតនោះ។ ប៉ុន្តែអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងនោះ គឺបានយោងទៅរកពីចេតនា ពីការសម្លាប់នូវជនទាំងប្រាំពីរនោះ។ ប៉ុន្តែមិនសម្លាប់គ្រប់ៗគ្នាផ្សេងទៀតទេ ដោយរាប់បញ្ចូលទាំងបទ -- ជនរងគ្រោះដែលគេអះអាងថារងបទឧក្រិដ្ឋដែលជាបញ្ហានៃជំនុំជម្រះនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជំទាស់នៅទីនេះ ដោយថានេះគឺជាឱកាសរបស់មេធាវីការពារក្តី ប៉ុន្តែគាត់បន្តធ្វើនូវសេចក្តីថ្លែងការណ៍មិនត្រឹមត្រូវអំពីវិសាលភាពនៃការជំនុំជម្រះ។ គាត់បានមានកំហុសជាច្រើនហើយ ប៉ុន្តែចំណុចមួយដែលសំខាន់ ខ្ញុំកត់សម្គាល់ មិនគប្បីលើកតទៀតទេ គឺមិនមែនជាបញ្ហាទេ។ ប្រសិនជាគាត់អានដីកាដំណោះស្រាយ ដែលថាការកាប់សម្លាប់នូវជនមហាក្បត់ពីរដែលនៅក្នុងភ្នំពេញ វាជាស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងនេះឯង។ ហើយគេដាក់ចូលនៅក្នុងការចោទប្រកាន់អំពីការជម្លៀសលើកទី១ លើកទី២។ ហើយប្រសិនបើមេធាវីអះអាងពីរឿងនេះ គឺមិនត្រឹមត្រូវថាមិនពិតនោះទេ។ ហើយគាត់មានឱកាសនឹងលើកឡើងពីឯកសារ។ ប៉ុន្តែមិនត្រូវនិយាយបំភ័ន្តអំពីវិសាលភាពការជំនុំជម្រះនាពេលនេះទេ។ សូមអរគុណ។

[១១:៣៥:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានអានដីកាដំណោះស្រាយ ហើយយើងបានឃើញថាដីកាដំណោះស្រាយមិនបាននិយាយជាក់លាក់អំពីការសម្លាប់ជនពីររូបនេះទេ ប៉ុន្តែយើងធ្វើទឡ្ហីករណ៍ផ្អែកលើឯកសារទាក់ទងទៅនឹងការកាប់សម្លាប់នូវជនមហាក្បត់ទាំងប្រាំពីរ គឺថាមិនគប្បីមានតម្លៃភស្តុតាងត្រូវបានកាត់បន្ថយទេ។ កាលនោះ យើងនិយាយអំពីការកាប់សម្លាប់នូវទាហាន លន់ នល់ ជាធម្មតានោះ។ នេះជាគោលជំហររបស់ខ្ញុំ។ ប្រសិនបើសហព្រះរាជអាជ្ញាមិនយល់ស្រប គឺមិនជាបញ្ហាទេ។ អានេះជំហររបស់មេធាវីការពារក្តីបាទ។

[១១:៣៦:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៨:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា សូមអញ្ជើញបន្តទៀតបាទ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

ចំណុចផ្សេងៗទៀតទាក់ទងទៅនឹងជនមហាក្បត់ទាំងប្រាំពីរនេះគឺថាផ្នែកផ្សេងទៀតនៃឯកសារទាំងអស់នេះ គឺបានពង្រឹងនូវការចាប់អារម្មណ៍របស់យើងខ្ញុំ។ សហព្រះរាជអាជ្ញាបានដកស្រង់ពីឯកសារ E3/118, ជាសេចក្តីថ្លែងការណ៍របស់រណសិរ្សរួបរួមជាតិកម្ពុជាតាមវិទ្យុដោយ ខៀវ សំផន ដែលរៀបរាប់អំពីមេដឹកនាំរដ្ឋាភិបាល លន់ នល់ នៅថ្ងៃទី១៣ ខែមេសា។ ខៀវ សំផន បាននិយាយថា "គណៈកម្មការកំពូលនេះ គឺមិនតំណាងអ្នកណាម្នាក់ទៀតទេ ប៉ុន្តែមានតែជនក្បត់មួយចំនួនតូច។ ការបង្កើតនូវអង្គការនេះ គឺផ្ទុយនឹងជាតិ ហើយនិងផ្ទុយអំពីប្រជាជន ហើយគឺបង្កើតបន្តនូវអំពើក្បត់របស់ជនក្បត់នេះឯង។ ដោយហេតុនេះហើយគាត់បាននិយាយថា បងប្អូនទាំងអស់នៅភ្នំពេញ ហើយនិងប្រជាជននៅក្នុងខេត្តផ្សេង ដែលនៅក្រោមខ្លាំងនោះគប្បីរួបរួមគ្នា ហើយនិងផ្តួលអង្គការក្បត់។" សូមបញ្ចប់សេចក្តីដកស្រង់មួយវគ្គនេះ។

[១១:៣៩:៤៤]

យើងជឿថា ខៀវ សំផន បានបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជាទាំងអស់ គប្បីរួមគ្នាដើម្បីផ្តួលនូវជនក្បត់ទាំងអស់នេះដែលមេកំពូលរបស់រដ្ឋាភិបាល។ សំខាន់បំផុតនៅក្នុងសេចក្តីដកស្រង់នេះ លោក ខៀវ សំផន បានយោងទៅរកជនរួមជាតិបងប្អូនទាំងអស់នៅភ្នំពេញ ដែលគាត់បានបដិសេធការអះអាងរបស់សហព្រះរាជអាជ្ញាដែលគ្មានមូលដ្ឋានថា ថាអ្នកភ្នំពេញទាំងអស់ត្រូវបានចាត់ទុកជាខ្មាំងនៅក្នុងខែមេសា ឆ្នាំ១៩៧៥។ អ្នកជនរួមជាតិបងប្អូនទាំងអស់រាប់បញ្ចូលទាំងមន្ត្រី ហើយនិងអតីតទាំងអស់ អ្នកដែលធ្វើការនៅក្រៅឧត្តមក្រុមប្រឹក្សានៅកាលនោះឯង។

លោកប្រធាន ឯកសារបន្ទាប់មកទៀតដែលលើកឡើងនៅក្នុងចំណោមឯកសារទូទៅនេះ ឯកសារទាំងអស់នេះក៏ពាក់ព័ន្ធទៅនឹងក្រុមដ៏តូចមួយនៃបុគ្គលមួយចំនួននៅថ្នាក់លើបំផុតនៃរបប លន់ នល់ នៅក្នុងទីក្រុងភ្នំពេញ។ ឯកសារលេខ E3/2694, ឯកសារ E3/2700, E3/2702, D365/1.1.39 និងឯកសារ E3/604។ ឯកសារបីដំបូង គឺជាការប្រាស្រ័យទាក់ទងពី ហ្សង់ ឌីវ៉ាក់ ជាមន្ត្រីការទូតនៅស្ថានទូតបារាំង ហើយឯកសារពីរទៀត គឺអត្ថបទមកពីកាសែតភ្នំពេញប៉ុស្តិ៍ និងបាងកកប៉ុស្តិ៍ -- បាទ គឺឯកសារវ៉ាស៊ីនតោនប៉ុស្តិ៍ និងបាងកកប៉ុស្តិ៍។

[១១:៤១:៤៥]

ឯកសារទាំងប្រាំនេះ គឺបានចងក្រងនូវការគាំទ្រ ដែលរៀបរាប់អំពីការកាប់សម្លាប់អ្នកទាំងបី។ ពីរនៅក្នុងចំណោមពួកមហាក្បត់ទាំងប្រាំពីរ និង លន់ ណុន ដែលជាប្អូនប្រុសរបស់ លន់ នល់។ សារតេឡេក្រាមរបស់ ឌីវ៉ាក់ បាននិយាយថា "មនុស្ស១00នាក់ គឺថាត្រូវបានចុះចេញក្នុងនាមជាអ្នកទោសនៅចំពោះខ្មែរក្រហមនៅថ្ងៃបន្ទាប់។ មិនមានភស្តុតាងថាអ្នកនោះគឺជាអ្នកណាទេ ហើយក៏មិនមានភស្តុ-តាងបញ្ជាក់ថា មានអ្វីកើតឡើងចំពោះមនុស្សទាំងនោះដែរ"។

ឯកសារបន្ទាប់លោកប្រធាន ដូចដែលយើងខ្ញុំបានលើកឡើងហើយ គឺជាផ្នែកមួយនៃភស្តុតាងដ៏បំផុត ដែលសហព្រះរាជអាជ្ញាបានលើកឡើង។ គឺជាការបញ្ជាឲ្យសម្លាប់មនុស្សពីសមមិត្ត ពីន នេះគឺជាឯកសារ E3/832។ យ៉ាងហោចណាស់ឯកសារនេះក៏មានការពាក់ព័ន្ធតិចតួចដោយផ្នែកណាមួយដែរ ដែលជាផ្នែកមួយនៃឯកសារបង្ហាញឡើងដោយសហព្រះរាជអាជ្ញានោះ។ ហើយបើសិនណាវាជាផ្នែកទី១៥ ឬទី២០ នៃភស្តុតាងនោះ វាអាចជាការតតាំងគ្នាយ៉ាងខ្លាំង។ ក៏ប៉ុន្តែឯកសារនេះបង្ហាញថានេះគឺជាការបញ្ជាដែលចេញដោយសមមិត្ត ពីន បញ្ជាទៅដល់អ្នកណាម្នាក់ឲ្យសម្លាប់មនុស្សចំនួន១៧នាក់។ ឯកសារនេះមិនបានបង្ហាញថា បញ្ជានេះវាមកពីអ្នកណា ហើយត្រូវបញ្ជូនទៅឲ្យអ្នកណានោះទេ។ ការដែលថាបញ្ជានេះគឺវាចេញមកពី -- សូមដកស្រង់៖ "បក្សគឺមិនមានអ្វីខ្លះអះអាងនោះឡើយ"។

[១១:៤៣:៤៤]

អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មកម្មាភិបាលគ្រប់ថ្នាក់ទាំងអស់បានប្រើពាក្យថា "អង្គការ" យីហោថា "អង្គការ" ដើម្បីជាឱកាសក្នុងការអនុវត្តនូវអំណាចតិចតួចរបស់ខ្លួន។ ពីន បានប្រើឃ្លាសូមដកស្រង់ "បក្សមិនមានអ្វីនោះទេ រួមទាំងការអនុវត្តបញ្ជាពីថ្នាក់លើផង"។

ឯកសារនេះក៏បានបង្ហាញយ៉ាងច្បាស់ថា អ្នកណាក៏ដោយដែលបានសម្រេចសម្លាប់មនុស្សទាំង១៧នាក់នេះ ប្រសិនបើមានអ្នកណាសម្លាប់មែននោះ គឺមិនមែនដោយសារតួនាទីនៅក្នុងជួរកងទ័ព ឬក៏ជំហររបស់កងទ័ពនោះទេ។ ទី១ ឯកសារបានបញ្ជាក់យ៉ាងច្បាស់ហើយថា ជនរងគ្រោះ -- សូមដកស្រង់ "--ត្រូវបានសួរចម្លើយនៅមុនចេញសេចក្តីសម្រេចឲ្យសម្លាប់អ្នកទាំងនោះ"។ ប្រសិនណាមានគោលនយោបាយឲ្យសម្លាប់ទាហាន ឬមន្ត្រីទាំងអស់មានមែននោះ នោះមិនចាំបាច់ត្រូវការពិនិត្យពិច័យអ្នកណាម្នាក់ឡើងវិញនោះទេ។

បន្ទាប់មកទៀត គឺឈ្មោះជាក់លាក់មួយចំនួនដែលថាមនុស្សទាំងអស់នោះគឺមានភាពស្មោះត្រង់ គឺថាត្រូវតែវាយតម្លៃរកភាពស្មោះត្រង់របស់អ្នកទាំងអស់នោះ។ បន្ទាប់ពីលេខ១៤គឺឈ្មោះ អៀម សាយ។

ឧទាហរណ៍ ខ្ញុំសូមដកស្រង់៖ គាត់គឺជាអតីតគ្រូបង្រៀនដែលជាជនក្បត់នៅពេលដែលគាត់ជាគ្រូបង្រៀននោះ។ នៅក្នុងប្រវត្តិរូបរបស់គាត់ គាត់រិះគន់យើងយ៉ាងខ្លាំង ប្រើពាក្យពាចន៍ចិត្តសាស្ត្រ ហើយគាត់ឆ្លើយតបថាគាំទ្ររបបសាធារណរដ្ឋដាច់ខាត ហើយប្រឆាំងជាមួយបដិវត្តន៍ដាច់ខាត។

[១១:៤៥:៤២]

ខ្ញុំយោងទៅឯកសារ ERN ជាអង់គ្លេស 00068919, និងខ្មែរ 00068916។ ហើយនៅពេលនេះ គឺថាបញ្ហានេះក៏មានរៀបរាប់ចំពោះមន្ត្រីយោធាជាន់ខ្ពស់ពីរនាក់ ហើយនិងអភិបាល -- និងជំទប់ពីរនាក់។ សូមដកស្រង់៖ “សូមឱ្យពិនិត្យតាមដានបុគ្គលដែលមានឈ្មោះទាំងនេះ ហើយមួយទៀតគឺថាឯកសារនេះក៏មិនបានបញ្ជាក់ផងដែរ ថាមន្ត្រីយោធាទាំងអស់ត្រូវបានសម្លាប់ដោយសារតែគោលនយោ-បាយនោះដែរ។

បន្ទាប់មកទៀតគឺសហព្រះរាជអាជ្ញាបានបង្ហាញរបាយការណ៍ព័ត៌មានចុះថ្ងៃទី២១ ឧសភា ៧៦ ពីសារព័ត៌មាន អាហ្សង់ហ្វ្រង់ប្រេស ដែលមានឧត្តម អតីតឧត្តមសេនីយ៍ចំនួន៥៤នាក់ត្រូវបានសម្លាប់ភ្លាមក្រោយថ្ងៃ១៧ មេសា ៧៥។

និយាយរួមទៅ សហព្រះរាជអាជ្ញាបានយោងទៅលើប្រភពព័ត៌មាន ដែលគួរតែអង្គជំនុំជម្រះបញ្ជាក់ថាវាមានភាពខ្សោយយ៉ាងមែន ភាពខ្សោយយ៉ាងខ្លាំងទាក់ទងទៅនឹងភស្តុតាងទាំងនេះ។ ប៉ុន្តែឯកសារនេះ ជាពិសេសគឺមិនអាចឱ្យជឿជាក់បាន ហើយមិនមានតម្លៃភស្តុតាងអ្វីទាល់តែសោះ។ ហើយត្រូវតែច្រានចោលទាំងស្រុង។

[១១:៤៦:២៣]

ទោះបីជាអ្នកកាសែតក្តី ឬក៏អ្នកដែលគ្មានមានឈ្មោះ សូមដកស្រង់ថាជាអ្នកនាំពាក្យចលនាតស៊ូដែលបាន -- ដែលជាប្រភពព័ត៌មានក៏ដោយ។ សូម្បីតែការរៀបរាប់ប្រភពសូមដកស្រង់ថាជាអ្នកនាំពាក្យខាងចលនាតស៊ូ គឺជាការច្របូកច្របល់ ព្រោះយើងអត់ដឹងថាជាអ្នកណា។ ចលនាតស៊ូនេះគឺជាពួកប្រឆាំងជាមួយ ប៉ុល ពត ឬ? បើសិនជាអ៊ីចឹងទេ គឺថាពួកគេគឺធ្វើយ៉ាងម៉េចក៏ដោយ ធ្វើម៉េចប្រឆាំងជាការឃោសនាប្រឆាំងទៅនឹងខ្មែរក្រហម។

មានអត្ថបទសារព័ត៌មានមួយទៀត គឺមិនអាចឱ្យជឿជាក់បានទាល់តែសោះ ដោយសារតែខ្លឹម-សារគឺមិនមានន័យអ្វីនោះឡើយ។ ឯកសារនេះបញ្ជាក់អះអាងថា ឧត្តមសេនីយ៍ -- សូមដកស្រង់សម្តី៖ “--ត្រូវបានបញ្ជូនទៅរដ្ឋាភិបាលបស្ចិមប្រទេសមួយចំនួនហើយ”។ បញ្ចប់ការដកស្រង់។ ហេតុអ្វីក៏បក្ស

កុម្មុយនីស្តកម្ពុជាសម្លាប់មនុស្ស៥៤នាក់ ហើយប្រកាសទៅពិភពលោកថា គេបានធ្វើដូច្នោះមែន។ ប្រសិនបើគេចប់ប្រកាសទៅឲ្យពិភពលោកដឹងមែននោះ ហេតុអ្វីបានជាគេផ្ញើសារយ៉ាងសម្ងាត់ទៅឲ្យរដ្ឋាភិបាលបស្ចិមប្រទេស ហើយមិនឲ្យ -- ហើយម៉េចក៏មិនសរសេរឲ្យលេចឮខ្ចរខ្ចាយនៅក្នុងទង់បដិវត្តទៅ? ជាពិសេសគឺ -- ហើយអ្នកណាដែលជាជនក្បត់ទាំងប្រាំពីររូបនោះ? ហើយបើសិនណាត្រូវបានបង្ហាញទៅរដ្ឋាភិបាលមួយចំនួនឲ្យដឹងមែន ហេតុអ្វីក៏មិនមានភស្តុតាងពីប្រភពផ្សេងទៀតក្រៅពីតែប្រភពសារព័ត៌មានមកអ្នកកាសែតតែម្នាក់នោះ? ហេតុអ្វីក៏បក្សកុម្មុយនីស្តកម្ពុជាសម្រេចភ្លាមៗ បង្ហាញអំពីការកាប់សម្លាប់ក្នុងរយៈពេល១៣ខែក្រោយពីកើតឡើងនោះ? ហេតុអ្វីបានជាគេរៀបចំបញ្ជីនៅក្នុងខែធ្នូ ១៩៧៥ គឺ ៧ខែក្រោយពីការកាប់សម្លាប់។ ហើយថាតើគេទាក់ទងរដ្ឋាភិបាលបស្ចិមប្រទេសដោយរបៀបណា ដោយមិនមានទំនាក់ទំនងការទូតដោយផ្ទាល់នោះ? ការលើកឡើងទាំងអស់នេះ គ្មានអ្វីមួយដែលមានន័យនោះឡើយ។

[១១:៤៩:៣១]

បន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានពិភាក្សាទៅលើប្រវត្តិរូបពីរដែលរៀបចំឡើងដោយកម្មាភិបាលមកពីក្រសួងការបរទេស។ ឯកសារទាំងនោះមានលេខ E3/3569 និង E3/128។ សម្រាប់យើងខ្ញុំ វាហាក់បីដូចបញ្ជាក់ថាឯកសារទាំងអស់នេះ មិនមានន័យអីទាល់តែសោះ។ ដូច្នេះខ្ញុំមិនចំណាយពេលនិយាយពីឯកសារនេះទេ។ ខ្ញុំគ្រាន់តែនិយាយក្នុងថ្ងៃនេះ ថាឯកសារនេះមិនបាននិយាយអំពីការកាប់សម្លាប់ ឬក៏ការប្រព្រឹត្តដោយអមនុស្សធម៌ទៅលើនរណាម្នាក់មួយនោះឡើយ។

ឯកសារបន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានបង្ហាញនូវបញ្ជីអ្នកទោសស-២១ចំនួនបី។ មុនពេលយើងពិនិត្យមើលឯកសារជាក់លាក់ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវចំណុចជាក់ស្តែងមួយ។ មនុស្សប្រភេទ -- ប្រភេទមនុស្សផ្សេងៗគ្នាត្រូវបានចោទប្រកាន់ថាត្រូវគេបញ្ជូនទៅកាន់ស-២១។ យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាហានលន់នល់សរុបត្រូវបានគេចោទប្រកាន់ថាសម្លាប់នៅស-២១ នោះគឺមានចំនួនដល់ទៅ៣២៨នាក់។ បើសិនណាចំណុចនេះត្រឹមត្រូវគឺ ថាវាទូរលេខនេះគឺ វាស្មើនឹង ២.៥ ភាគរយនៃចំនួនអ្នកទោស ១២.០០០នាក់ នៅស-២១។

[១១:៥១:០៧]

តើច្រើនទេ? តើទាហាន លន់ នល់ មានច្រើនជាងនេះ ឬតិចជាងនេះដែល ឬក៏មានតែ ២.៥ភាគរយនៃចំនួនប្រជាពលរដ្ឋ? សហព្រះរាជអាជ្ញាអត់បាននិយាយចំណុចនេះទេ។ ដូច្នេះយើង -- ខ្ញុំគ្រាន់តែ

ដឹងថាអ្នកទាំងអស់នេះគឺជាទាហាន លន់ នល់ តែប៉ុណ្ណោះ។ ប៉ុន្តែតាមរយៈឯកសារនេះមិនមានភស្តុតាងបង្ហាញថាអ្នកណាម្នាក់ក្នុងចំណោមហ្នឹងត្រូវបញ្ជូនទៅស-២១ នោះទេ។ ត្រូវបានបញ្ជូនទៅស-២១ ដោយសារពួកគេជាទាហាន លន់ នល់ ទេ។ មិនមានភស្តុតាងណាមួយបញ្ជាក់ថាពួកនេះបញ្ជូនទៅស-២១ ទេ ដោយសារតែពួកនេះគឺជាទាហាន លន់ នល់ នោះ។

បាទ ឥឡូវនេះ សូមមើលឯកសារជាក់លាក់មួយចំនួនដែលសហព្រះរាជអាជ្ញាបានបង្ហាញ។ ប្រសិនណាយើងមើលទៅលើឯកសារទាំងនេះដោយប្រុងប្រយ័ត្នទៅ យើងនឹងឃើញថាឯកសារដំបូង, ឯកសារទី១ បង្ហាញផ្ទុយទៅវិញនូវអ្វីដែលសហព្រះរាជអាជ្ញាបញ្ជាក់ថា ឯកសារនេះវាបង្ហាញនូវភស្តុតាង។ វាមិនបានបង្ហាញនូវគោលនយោបាយនៃការសម្លាប់ទាហាន លន់ នល់ ថាពិតជាមាននោះទេ។ ហើយឯកសារពីរទៀតមិនបានបញ្ជាក់ចំណុចអ្វីសោះឡើយ មិនមានតម្លៃជាភស្តុតាងនោះឡើយ។ ឯកសារទី១ នោះគឺលោកប្រធាន E3/1539។ ឯកសារនេះបញ្ជាក់ថា ១ខែ ក្នុងរយៈពេល១ខែគឺ ក្នុងខែមីនា ១៩៦២ (*ស៊ីក*) មន្ត្រី លន់ នល់ និងទាហាន លន់ នល់ ចំនួន១៦២នាក់ត្រូវបានសម្លាប់នៅ ស-២១។

[១១:៥២:៤៨]

ប្រសិនណាជាមន្ត្រី លន់ នល់ ១៦២ នាក់ពិតជាសម្លាប់នៅក្នុងខែមីនា ១៩៧៦នោះ មិនមែនមានន័យថាគេមិនមែនសម្លាប់ក្នុងរយៈពេលជាង១ឆ្នាំនោះទេ ប្រសិនបើមានគោលនយោបាយសម្លាប់ទាហាន លន់ នល់ ទាំងអស់មែននោះ ពួកគេអាចនឹងសម្លាប់តាំងពី១១ខែដំបូងម្ល៉េះ។ ក្នុងនោះផងដែរ អង្គហេតុដែលបង្ហាញថាទាហានជាច្រើនត្រូវបញ្ជូនទៅស-២៦ (*ស៊ីក*) ក្នុងពេលតែមួយនោះ បញ្ជាក់យ៉ាងខ្លាំងថាពួកគេត្រូវបានសម្លាប់មិនមែនដោយសារតែពួកគេជាទាហាន លន់ នល់ ទេ ប៉ុន្តែវាគឺដោយសារហេតុផលជាក់លាក់ជាងនេះមួយចំនួនទៀត។ ជាក់ស្តែងអ្វីដែលកើតឡើងនៅក្នុងខែមីនា ១៩៧៦ ប៉ុន្តែយើងអត់បានដឹងថាស្អីកើតឡើងនោះទេ។ ប៉ុន្តែថាតើបក្សកុម្មុយនីស្តកម្ពុជាមិនបានសម្រេចភ្លាមៗ ត្រូវសម្លាប់ទាហាន លន់ នល់ ភ្លាមៗនោះទេឬ?

ឯកសារទី២ គឺ E3/2189 សហព្រះរាជអាជ្ញាបាននិយាយថា ឯកសារនេះបង្ហាញនូវការខិតខំប្រឹងប្រែងដើម្បីផ្តោត ដើម្បីកំណត់ទិសដៅលើមន្ត្រី លន់ នល់ ដោយសារតែចំណងជើងឯកសារនេះ -- សូមដកស្រង់ “អ្នកទោសដែលជាមន្ត្រីរដ្ឋការ” បញ្ចប់ការដកស្រង់។ យោងទៅតាម ក.ស.ព -- ហើយខ្ញុំសូមដកស្រង់ក្នុងពេលនេះ សូមដកស្រង់ “គឺចំណងជើងទាំងអស់ដែលត្រូវបានដាក់នៅក្នុងបញ្ជីអ្នកទោសស-២១ បញ្ជាក់អំពីការកំណត់គោលដៅទៅលើមន្ត្រីរដ្ឋាភិបាល ឬអ្នករដ្ឋការ”។ បញ្ចប់ការដក

ស្រង់។ ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រនោះទេ យើងគិតថាហេតុអ្វី? ប្រហែលដោយសារវាមានឈ្មោះចំនួនប្រាំមួយនាក់ យើងមិនដឹងថាហេតុអ្វីបានជាឯកសារនេះមានចំណងជើងដូចដែលវាសរសេរ ប៉ុន្តែជាក់ស្តែងវាមិនមាននិយាយអ្វីអំពីការចោទប្រកាន់ទៅលើគោលនយោបាយណាមួយនោះទេ។ ប្រសិនបើមានមែននោះនោះគឺជាគោលនយោបាយមួយដែល មានកម្រិតបំផុត។

[១១:៥៥:១៤]

ឯកសារទី៣ គឺឯកសារ E3/3597។ ប្រជាជនខ្លះនៅលើបញ្ជីហ្នឹងត្រូវបានចោទប្រកាន់ថា គឺជាអតីត និងជាមន្ត្រីរដ្ឋការ ហើយអ្នកខ្លះមិនមែននោះទេ។ ហើយសហព្រះរាជអាជ្ញាមិនបានប្រាប់យើងថាមានប៉ុន្មាននាក់នោះទេ ហើយក៏មិនបានប្រាប់ថាមានអ្នកណាខ្លះក្នុងចំណោមមនុស្សទាំងអស់ត្រូវបញ្ជូនទៅស-២១ ដោយសារតែតួនាទីពីមុនរបស់ពួកគេនៅក្នុងរដ្ឋាភិបាល។ ហើយឯកសារនេះក៏មិនមានការពាក់ព័ន្ធដែរ។ ហើយបន្ទាប់មកសហព្រះរាជអាជ្ញាបានបង្ហាញនូវកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងព្រះរាជវង្សានុវង្ស។ នេះគឺឯកសារ E3/197។ បាទ ជាថ្មីម្តងទៀតឯកសារនេះមិនបាននិយាយអំពីការសម្លាប់ ឬការប្រព្រឹត្តណាមួយទៅលើមន្ត្រីរដ្ឋាភិបាលលន់ នល់។ ហេតុដូច្នេះឯកសារនេះមិនមានការទាក់ទងគ្នា មិនមានការពាក់ព័ន្ធគ្នាទាល់តែសោះ។

ហើយបន្ទាប់មក សហព្រះរាជអាជ្ញាបានបង្ហាញនូវឯកសារស្តីអំពីការទំនាក់ទំនងផ្នែកខាងយោធា។ ឯកសារទាំងបីនេះគឺមិនមានការពាក់ព័ន្ធនោះទេ។ ឯកសារទាំងបីគឺ មួយE3/1162, E3/813 និង E3/807។ ឯកសារទាំងនេះបង្ហាញថា នៅក្នុងអង្គភាពជាក់លាក់នេះគឺថាកងទ័ពទាំងអស់ត្រូវបានគេតាមដានដើម្បីពិនិត្យមើលថាតើគេមានជាប់ទាក់ទង ឬក៏មានភាពស្មោះត្រង់ទៅនឹងរបបមុននោះដោយរបៀបណានោះ?

[១១:៥៧:០៧]

នេះគឺជាហេតុផលគ្រប់គ្រាន់ហើយដែលមិនមាននៅក្នុងរដ្ឋបដិវត្តន៍ធម្មតានោះទេ។ គឺនៅក្នុងសហរដ្ឋអាមេរិកគ្រប់បុគ្គលទាំងអស់ជនជាតិជប៉ុន គឺគេបានលើក៤ឆ្នាំនៅក្នុង -- ត្រូវបានគេឃុំខ្លួន៤ឆ្នាំនៅក្នុងមន្ទីរអប់រំកែប្រែនៅក្នុងសង្គ្រាមលោកលើកទី២។ ហើយនេះគឺជាអ្នកដែលបានវាយប្រយុទ្ធប្រឆាំងទៅនឹងបក្សកុម្មុយនីស្តកម្ពុជានោះត្រូវបានគេប្រព្រឹត្តខុសគ្នាពីប្រជាជនទូទៅ។

តើជំហររបស់សហព្រះរាជអាជ្ញានោះគឺជាអ្វី? អស់លោក លោកស្រីចៅក្រម យើងខ្ញុំមិនមាន

យោបល់អ្វីទាល់តែសោះ។

ឯកសារពីរប្រភេទទៀតដែលបង្ហាញឡើងដោយសហព្រះរាជអាជ្ញា គឺកំណត់ហេតុមកពីសហ-ករណ៍ត្រាំកក់ ហើយមានឯកសារកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនបី។ យើងទទួលស្គាល់ថា សហព្រះរាជអាជ្ញាបានរៀបរាប់កំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលជាគំរូមួយដែលគេអះអាងថាគឺជាក្រុមមួយដ៏ធំ។

លោកប្រធានជាទីគោរព! ដូចខ្ញុំបានបញ្ជាក់ពីខាងដើម យើងខ្ញុំមានគម្រោងថាបង្ហាញនូវការពិភាក្សាទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ហើយកំណត់ហេតុទាំងបីរបស់សហព្រះរាជអាជ្ញាដែលបានបង្ហាញនោះគឺជាផ្នែកមួយនៃការពិភាក្សានេះ។ ហើយកំណត់ត្រានៅសហករណ៍ត្រាំកក់ក៏ពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះផងដែរ។ ប៉ុន្តែ ខ្ញុំសូមទុកឯកសារទាំងនេះមួយអន្លើសិន សូមបន្តទៅឯកសារដែលបង្ហាញឡើងដោយសហព្រះរាជអាជ្ញាពីរបីទៀត ប៉ុន្តែដោយសារថាដល់ម៉ោងត្រូវសម្រាកនៅពេលថ្ងៃត្រង់ហើយលោកប្រធាន។

[១១:៥៨:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិប នាទីរសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីបន្តការធ្វើការកត់សម្គាល់ ឬក៏អត្ថាធិប្បាយលើឯកសារគន្លឹះដែលដាក់ឡើងដោយភាគីតំណាងសហព្រះរាជអាជ្ញា និង/ឬ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ ខ្ញុំនឹងបន្តមតិយោបល់របស់ខ្ញុំលើតម្លៃភស្តុតាងនៃឯកសារទាំងឡាយដែលបង្ហាញនៅក្នុងការបង្ហាញពាក់ព័ន្ធទៅនឹងការកំណត់យកមន្ត្រី ទាហានលន់នល់ ជាទិសដៅនៃនយោបាយនោះ។

[១៣:៣៣:៥៨]

ខ្ញុំបានចូលមកដល់មុនពេលសម្រាកពិសាអាហារថ្ងៃត្រង់នោះ គឺនៅទង់បដិវត្តខែសីហា ឆ្នាំ១៩៧៧, ឯកសារ E3/193។ សហព្រះរាជអាជ្ញាបានអះអាងនៅក្នុងការអះអាងរបស់ខ្លួនថា ឯកសារនេះមាននូវសេចក្ដីណែនាំ ដើម្បីសម្លាប់ទាហាន លន់ នល់ ដែលមានអំណាចនៅក្នុងសហករណ៍។

ជាបឋម យើងនឹងស្នើសុំឲ្យអង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារនេះគឺចុះថ្ងៃ -- ពីរឆ្នាំកន្លះមុនពេលហេតុការណ៍នៅទួលពោធិ៍ជ្រៃ បន្ទាប់ពីទួលពោធិ៍ជ្រៃ។ ដូច្នេះគឺថាបញ្ហានេះមិនពាក់ព័ន្ធទាល់តែសោះទៅនឹងគោលនយោបាយរដ្ឋ ដែលនយោបាយនេះកើតឡើងនៅខែមេសា ឆ្នាំ១៩៧៥ តែប៉ុណ្ណោះ។ ខ្លឹមសារនៃឯកសារនេះក្នុងករណីណាក្ដី មានតែមនោគមន៍វិជ្ជាដែលស្រពេចស្រពិលតែប៉ុណ្ណោះ មិនមានការណែនាំ ឬក៏ការបញ្ជាឲ្យបង្កអន្តរាយដល់អ្នកណាម្នាក់ឡើយ។

សហព្រះរាជអាជ្ញាអាចនឹងជោគជ័យក្នុងការផ្ដល់ការចាប់អារម្មណ៍ផ្សេងមួយទៀត នៅក្នុងការបង្ហាញខ្លួន។ ប៉ុន្តែគេអាចធ្វើដូច្នេះបានតែការធ្វើរឿងនេះដដែលៗ ដោយដាក់បញ្ចូលនៅជាមួយគ្នានូវកថាខណ្ឌដែលស៊ីសង្វាក់ នៅសេចក្ដីដកស្រង់បីដែលមិនពាក់ព័ន្ធនៅក្នុងទំព័របីខុសគ្នា។ ពួកគេបានប្រើសេចក្ដីយោងទៅរកទាហាន លន់ នល់ ដោយខុសបរិបទ។ ពួកគាត់ដាក់ទៅចំណុចទី២ ដែលខុសពីការណែនាំ ដែលខុសប្រធានបទបួនទំព័រ។ ពេលក្រោយនោះ និយាយថាកម្ទេចខ្មាំង ហើយបានស្នើសុំឲ្យ

អង្គជំនុំជម្រះសន្និដ្ឋានថាកម្មាភិបាលទទួលការបញ្ជូនឲ្យកម្ទេចទាហាន លន់ នល់។

[១៣:៣៦:១៥]

ការពិនិត្យដ៏លម្អិតនូវឯកសារនេះ ក៏បង្ហាញខ្លឹមសារដែលស្រាលជាងនេះ, ERN ភាសាអង់គ្លេស 00399234 ដល់ 35, ខ្មែរ 00062963 ដល់ 4, បារាំង 00611839 ដល់ 40។ ការយោងទៅរកទាហាន លន់ នល់ និយាយគ្រាន់តែឧទាហរណ៍ដែលកសិករដែលគ្មានវណ្ណៈនៅក្នុងមុខតំណែងដែលមានអំណាចនៅក្នុងសហករណ៍មួយចំនួនតែប៉ុណ្ណោះ។ ការណែនាំឲ្យកម្ទេច, នៅទំព័រ១៦, គឺមិនមែនជាការណែនាំសម្លាប់ ឲ្យសម្លាប់មនុស្សទេ ប៉ុន្តែឲ្យលុបបំបាត់មនោគមន៍វិជ្ជាតែប៉ុណ្ណោះ។ យើងពិនិត្យមើលការដកស្រង់នៅក្នុងផ្នែកនៃឯកសារនោះ បង្ហាញថា -- សូមដកស្រង់ជាសេចក្ដីដកស្រង់ដ៏វែងមួយ៖

"អ្នកណាជាអ្នកកាន់អំណាចនៅក្នុងសហករណ៍នីមួយៗ។ និយាយដោយទូទៅ នៅភូមិភាគបស្ចិមទាំងមូលមួយផ្នែកធំ យើងត្រួតត្រាសហករណ៍បានទាំងស្រុង និងអំណាចរដ្ឋរួចហើយ។ មានន័យថាវាស្ថិតនៅក្នុងដៃរបស់កម្មករ ពលកររបស់បក្សហើយ ប៉ុន្តែស្ថិតនៅក្នុងវណ្ណៈដទៃទៀតដែរអំណាចនោះ។ ប្រសិនបើវាស្ថិតនៅក្នុងអំណាចនៃរបស់ទៀត តើអំណាចនេះ បានចូលខាងបដិវត្តន៍ហើយឬនៅ? ទេពួកគេជំទាស់បដិវត្តន៍។ វាតែបញ្ហា ថាតើគេជំទាស់បដិវត្តន៍តិចតួច ឬច្រើន ឬថាតើពួកគេជំទាស់បដិបក្ខ ឬមិនទាន់ជំទាស់ជាបដិបក្ខនៅឡើយ។ បន្ទាប់ពីយើងធ្វើការវាយតម្លៃបែបនេះហើយ យើងត្រូវតែរៀបចំដឹកនាំសហករណ៍បន្ត។ រៀបចំកម្លាំងអ្វី? រៀបចំកសិករក្រ និងកសិករកណ្ដាលថ្នាក់ក្រោម ដើម្បីត្រួតត្រាសហករណ៍ ដើម្បីវាយប្រហារ និងកម្ទេចអំណាចរដ្ឋដែលត្រួតត្រានៅក្នុងសហករណ៍ ហើយអំណាចនោះទៅសហករណ៍ក្រ និងកសិករកណ្ដាលថ្នាក់ក្រោម នៅខាងក្រោម។ ឥឡូវនេះយើងអាចពិនិត្យមើល ហើយនិងវាយប្រហារនៅក្នុងភូមិភាគ អាចវាយប្រហារនៅក្នុងតំបន់ អាចវាយប្រហារនៅក្នុងស្រុក ប៉ុន្តែយើងមិនអាចមានលទ្ធភាពវាយប្រហារនៅក្នុងថ្នាក់សហករណ៍។ ជាចាំបាច់យើងត្រូវរៀបចំកម្លាំងដើម្បីប្រហារ វាយប្រហារ និងកម្ទេចខ្មាំង ហើយនិងសមាសភាពមិនល្អនៅផ្ទៃក្នុង នៅក្នុងត្រួតត្រានៅក្នុងសហករណ៍"។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១៣:៣៨:២០]

យើងខ្ញុំនឹងស្នើឲ្យអង្គជំនុំជម្រះទទួលស្គាល់រឿងពីរអំពីការដកស្រង់ដ៏ធំនេះ។ មួយគឺថាអ្វីដែលគេហៅថាវណ្ណៈដទៃ ដែលកាន់កាប់សហករណ៍មិនចាំបាច់ជាអ្នកជំទាស់បដិបក្ខ និងបដិវត្តន៍ទេ។ ទី២ គឺការណែនាំ គឺឲ្យកម្ទេចនូវអំណាចរបស់បក្ស ក្នុងវណ្ណៈដទៃទៀតដើម្បីប្រគល់ឲ្យអំណាចទៅកសិករ

ថ្នាក់ក្រោម ហើយនិងកសិករកណ្តាលថ្នាក់ក្រោម។ ដូច្នេះ គ្មានគោលនយោបាយណាក្នុងការសម្លាប់អតីតទាហាន ដែលអាចយោងចេញពីឯកសារនេះបានទេ។

ឯកសារបួនចុងក្រោយ ដែលទាំងអស់នោះអះអាងថាមានការប្រាស្រ័យទាក់ទងយោធាមកពីភូមិភាគឧត្តរ ឬក៏ភូមិភាគពាយ័ព្យ ហើយដាក់ជូនទៅមន្ទីរ៨៧០ អង្គការឬ បងប៉ុល។ ឯកសារទាំងបួននេះគឺមានលក្ខណៈស្រដៀងគ្នា។ គេរបាយការណ៍នេះបានរាយការណ៍ទៅថ្នាក់លើអំពីខ្មាំងដែលថាត្រូវបានកំណត់អត្តសញ្ញាណ ហើយអ្នកខ្លះគឺជាអតីតទាហាន លន់ នល់។ ឯកសារមួយបញ្ជាក់ថាមានការចាប់ខ្លួន ហើយឯកសារពីរមិនបាននិយាយថាត្រូវមានចាត់វិធានការអ្វីនោះទេ។

[១៣:៤១:០៨]

តេឡេក្រាមចុងក្រោយបាននិយាយថា ទាហាននោះត្រូវបានបោសសម្អាត។ ដូចដែលយើងបានឃើញហើយ ពាក្យនោះអាចមានន័យខុសៗគ្នា។ ដូច្នេះ ឯកសារបួនចុងក្រោយនេះគឺនិយាយសម្រាប់តែពីឯកសារដែលថាឯកសារសំខាន់ៗដែលសហព្រះរាជអាជ្ញាបានបង្ហាញនោះ បានស្នើគំនិតថា អ្នកណាម្នាក់នៅក្នុងមជ្ឈិមបក្សអាចបានដឹងអំពីវិធានការ ឬក៏សេចក្តីសម្រេចណាមួយប្រឆាំងនឹងអតីតទាហាន លន់ នល់ ក្រៅពីជនមហាក្បត់ទាំងប្រាំពីរនោះ។ មិនមានឯកសារណាមួយក្នុងចំណោមនេះនិយាយថាទាហាននោះត្រូវបានគេសម្លាប់ទេ។ គ្មានឯកសារណាមួយរៀបរាប់ពីវិធានការដែលមជ្ឈិមបក្សបានសម្រេចនោះទេ។ ឯកសារទាំងអស់នេះបានចុះកាលបរិច្ឆេទឆ្ងាយមុនហេតុការណ៍ទួលពោធិ៍ជ្រៃបានកើតឡើង។ ដូច្នេះឯកសារនេះមិនមានតម្លៃជាភស្តុតាងបញ្ជាក់ពីគោលនយោបាយក្នុងការសម្លាប់ទាហាន និងមន្ត្រីសាធារណរដ្ឋមកត្រឹមខែមេសា ឆ្នាំ១៩៧៥នោះទេ។

លោកប្រធាន លោក លោកស្រីចៅក្រម បញ្ហានេះគឺបញ្ចប់នូវសេចក្តីសន្និដ្ឋានលើការពិភាក្សារបស់ឯកសារដែលព្រះរាជអាជ្ញាបានដាក់ជូន។ ឥឡូវនេះយើងនឹងចូលទៅផ្នែកមួយចុងក្រោយទាក់ទងទៅនឹងការឆ្លើយតបរបស់យើងខ្ញុំទៅនឹងគោលនយោបាយដែលបានអះអាងឡើងនោះ។

[១៣:៤២:៥២]

យើងនឹងបង្ហាញនូវឯកសារមួយចំនួន ចម្លើយរបស់សាក្សីដែលសហព្រះរាជអាជ្ញាបានដាក់ជូនជាភស្តុតាងនោះ។ ចម្លើយទាំងអស់នោះនឹងបង្កើតឡើង -- បង្ហាញនូវភស្តុតាងពីរ។ ទី១ សាក្សីដែលត្រូវបានកំណត់ថាជាអ្នកដឹងពីចេតនារបស់មជ្ឈិមបក្ស ហើយនិងអំពើរបស់កងទ័ព និងកម្មាភិបាលនៅមូលដ្ឋានបាននិយាយស៊ីសង្វាក់គ្នាថាទាហាន លន់ នល់ ហើយនិងមន្ត្រី លន់ នល់ នោះគឺមិនរងផល

អាក្រក់អ្វីនោះទេ។ ទី២ ភស្តុតាងដែលសហព្រះរាជអាជ្ញាបានដាក់បង្ហាញភស្តុតាងពីគំរូនៃការសម្លាប់ដែលថាមាននោះ គឺមិនអាចជឿជាក់បានជាប្រព័ន្ធទេ ជាពិសេសតាមពន្លឺនៃភស្តុតាងជាក់ស្តែងដែលផ្ទុយពីរឿងនេះ។

លោកប្រធាន ដោយមានការអនុញ្ញាតបែបនេះ គឺថាឯកសារទាំងអស់ដែលខ្ញុំចង់បង្ហាញដំបូងនោះ គឺសេចក្តីដកស្រង់ចេញពីខ្សែវីដេអូ។ វីដេអូនោះមានចំណងជើងថា "១ថ្ងៃនៅទួលពោធិ៍ជ្រៃ"។ មួយផ្នែកនៃឯកសារនោះត្រូវបានបង្ហាញនៅក្នុងតុលាការហើយ។ ឯកសារមានលេខ E186.1R។ ផ្នែកដែលពាក់ព័ន្ធនៅក្នុងវីដេអូនោះ គឺនៅពេលវេលា ២១ រហូតដល់ ២២នាទី ៣សីហ្គុង។ នៅក្នុងនោះលោក នួន ជា បាននិយាយអំពីជំហររបស់គាត់ថា តើនយោបាយក្នុងការសម្លាប់ទាហានលន់ នល់ នោះ មានឬមិនមាន។ ដោយមានការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនអង្គជំនុំជម្រះនូវខ្សែវីដេអូដែលនិយាយអំពីទួលពោធិ៍ជ្រៃ។

[១៣:៤៤:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នេះគឺថា វីដេអូដែលបានស្នើនេះមិនស្ថិតឡើងនៅក្នុងបញ្ជីនៃការបង្ហាញឯកសារនៅតុលាការទេ។ ដូច្នេះ ខ្ញុំគិតថាមេធាវីនឹងសូមបង្ហាញនូវវគ្គទាំងស្រុងដែលបង្ហាញពីទ្រឹស្តីរបស់គាត់ យុទ្ធសាស្ត្ររបស់គាត់ដើម្បីវាយប្រហារមកលើសហព្រះរាជអាជ្ញា។ បាទ តើគាត់ចង់បង្ហាញទាំងស្រុងរបស់ នួន ជា ដែលបាននិយាយ ដែលគាត់និយាយអំពីការប្រហារជីវិតទាហាន លន់ នល់ ជាន់ខ្ពស់នោះ។ ហើយបើសិនជាសហមេធាវីស្នើបង្ហាញទាំងស្រុងនោះ គឺយើងមិនជំទាស់ទេ ប៉ុន្តែបើតែផ្នែកតូចយើងខ្ញុំសូមជំទាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានចេតនាចង់បង្ហាញផ្នែកមួយ ដែលគាត់និយាយថា ដែលថាមិនមានគោលនយោបាយបែបនោះទេ។ ខ្ញុំក៏យល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា វីដេអូហ្នឹងបន្តវែងជាងហ្នឹង គឺថាខ្ញុំមិនជំទាស់ទេបើចាក់វែងជាងនេះក៏បាន វាអាស្រ័យទៅលើការពិចារណារបស់លោកប្រធានក្នុងការណែនាំឱ្យខាងប្រព័ន្ធសោតទស្សន៍ដើម្បីបញ្ចាំង អាច៣០សីហ្គុងលើសហ្នឹងក៏បាន ខ្ញុំក៏មិនជំទាស់នោះដែរ។

បាទ សូមអរគុណ។

[១៣:៤៦:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតតាមសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ក្នុងការបង្ហាញនូវឃ្លីបវីដេអូលើអេក្រង់ទូរទស្សន៍។ ប៉ុន្តែដោយសារមានសំណើបញ្ជាក់បន្ថែមពីតំណាងសហព្រះរាជអាជ្ញា ថាឲ្យការបង្ហាញនោះមានលក្ខណៈវែងជាងសំណើសុំរបស់ខាងក្រុមមេធាវី ដើម្បីឲ្យមានភាពច្បាស់លាស់ អង្គជំនុំជម្រះក៏យល់ព្រមផងដែរលើការឲ្យដាក់បង្ហាញនូវឃ្លីបវីដេអូនៅលើអេក្រង់ទូរទស្សន៍ហ្នឹង គឺបានវែងជាងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា ប្រហែលជាអាច៣០វិនាទី ឬក៏៤០វិនាទីទៅ។

សូមឲ្យផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវឃ្លីបវីដេអូលើអេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា!

[១៣:៤៩:២៣]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"សួរ៖ អានេះសូមបញ្ជាក់អំពីចំណុចនេះមួយ ទាក់ទិននឹង -- ខ្ញុំសួរកាលមុនម្តងហើយ ប៉ុន្តែចង់បញ្ជាក់ដាក់នៅក្នុងនេះបន្តិច ដែលថាទាក់ទិននឹងទាហាន លន់ នល់ បាទ កាលដែលរំដោះថ្ងៃ១៧ មេសា ៧៥ នោះបាទ តើមានគោលនយោបាយយ៉ាងណាខ្លះចំពោះទាហាន លន់ នល់ៗ? ឬមួយក៏មាននយោបាយដោះស្រាយតែពួកពីរបីនាក់ខាងលើ តើមានអ្នកណាខ្លះ? ឬយ៉ាងម៉េចបាទ? ព្រោះថាពេលក្រោយរំដោះមកវាមានការយកទាហានទៅសម្លាប់អីចឹងបាទ អីចឹងសូមអំជួយដោះស្រាយបញ្ហាហ្នឹង តើបញ្ហាហ្នឹងយ៉ាងណាតាមអំជ្រាបហ្នឹងបាទ? ឆ្លើយ៖ តាមខ្ញុំដឹង មាគ៌ាចំពោះទាហានដែលចាញ់ មួយដាក់អាវុធៗគេដាក់អាវុធហើយហ្នឹង។ ត្បិតពីរ បញ្ជូនគេទៅស្រុកគេ ទៅផ្ទះគេនៅឯណាឲ្យគេទៅហ្នឹងទៅ អាហ្នឹងតាមខ្ញុំចាំ ប៉ុន្តែប្រតិបត្តិយ៉ាងម៉េចៗយើងមិនដឹងទេ។ សួរ៖ អ៊ំៗបញ្ជាក់មាគ៌ានយោបាយចំពោះអ្នកទាំងប៉ុន្មានបីបួននាក់ហ្នឹង បួនប្រាំនាក់ហ្នឹងយ៉ាងម៉េច គោលនយោបាយបាទ? ឆ្លើយ៖ គោលនយោបាយគឺកម្ទេច។ និយាយពាក្យងាយៗ "កម្ទេច" ព្រោះពួកនេះវាទោសធ្ងន់ណាស់ លក់ប្រទេសជាតិ ធ្វើបរិវារ*

*គេ។ អាហ្នឹងមានប៉ុណ្ណឹងបាទ។ សួរ៖ ចុះក្រោយមកអ៊ំមានបានឮគេជម្រាបទាក់ទិនទៅរឿងបញ្ហាដូចជាការក្រោយពីថ្ងៃ១៧ មេសា បីបួនប្រាំថ្ងៃហ្នឹងមានការដោះស្រាយទាហានជាច្រើនពាន់នាក់ ដូច--"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៣:៥១:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតរំឭកអង្គជំនុំជម្រះថា សហព្រះរាជអាជ្ញាទំនងជាគិតថាលោក នួន ជា មានការស្មោះត្រង់ក្នុងគំនិតវីដេអូនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥២:១២]

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍សូមចាក់ផ្សាយបន្តទៅទៀត ប្រហែលជា៣០ ទៅ ៤០វិនាទីទៀត បន្តពីអម្បាញ់មិញនេះនូវឃ្លីបវីដេអូនៅលើអេក្រង់ទូរទស្សន៍។

[១៣:៥២:៤៥]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"សួរ៖ --នៅពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ។ តើបញ្ហានេះអ៊ំមានបានជ្រាបទេពេលនោះបាទ? ឆ្លើយ៖ ពេលនោះខ្ញុំមិនដឹងទេ គឺការដោះស្រាយអីផ្សេងៗណា មិនបានដឹងទាល់តែសោះម៉ែន។ ខ្ញុំដឹងខ្លះនៅពេលដែលធ្វើសមាហរណកម្មនេះហើយ បានដឹងយ៉ាងម៉េចៗខ្លះ តិចតួចដែលគេឲ្យនិយាយ -- ដែលគេឲ្យដឹង។ ប៉ុន្តែកាលណោះអត់ដឹង ហើយបើដឹងកាលដែលដឹងថាមានបញ្ហាហ្នឹង យ៉ាងម៉េចក៏ត្រូវមានវិធានការទប់ទល់ដែរ កុំឲ្យមានអ៊ីចឹងណ៎ះ មានវិធានការទប់។ ពីព្រោះគ្នាអស់នេះគ្នាគ្មានទោសកំហុសអីទេ ជាកូនទាហានធម្មតានោះ ហើយជានិយាយរួម ដូចជាប្រជាជនធម្មតាអ៊ីចឹង"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៣:៥៣:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមជម្រាបថា ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា សហព្រះរាជអាជ្ញាទំនងជាគិតថា លោក នួន ជា មានភាពស្មោះត្រង់ល្អនៅក្នុងវីដេអូនេះ។ ពួកគាត់បាន

បញ្ជាក់នូវចម្លើយរបស់លោក នួន ជា ដែលគាត់និយាយថា ជាភស្តុតាងដាក់បន្ទុកទៅលើគាត់។ ហើយ វីដេអូនេះក៏និយាយអំពីនយោបាយជាពិសេសដែលគាត់ – លោក នួន ជា – បដិសេធថា មិនមាននយោ-បាយបែបនោះទេ ហើយគាត់និយាយថាគាត់និយាយពាក្យនេះទៅនរណាម្នាក់ដែលគាត់ទុកចិត្ត ហើយ គាត់មិនដែលបានឃើញ មិនចង់ឲ្យគេផ្សាយចម្លើយរបស់គាត់ជាសាធារណៈទេ។ ដូច្នេះចម្លើយរបស់ គាត់គឺស្មោះត្រង់។ ហើយក៏វាស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សីដទៃទៀតដែរ ដូចដែលលោក លោកស្រីនឹងបានឃើញនៅខាងក្រោមនេះ។

នៅក្នុងឯកសារបន្ទាប់ដែលយើងមានបំណងនឹងបង្ហាញនោះគឺឯកសារ E3/1593, ត្រង់ ERN ជាភាសាអង់គ្លេស 00678523, ខ្មែរ 00637444 ដល់ 45។ មិនមានអត្ថបទជាភាសាបារាំងទេ។ គឺជា សៀវភៅរបស់លោក ប៉ែន យៀវនិន ដែលមានចំណងជើងថា "របប ប៉ុល ពត ពូជសាសន៍ អំណាច និង ប្រល័យពូជសាសន៍ក្រោមរបបខ្មែរក្រហម"។ ទំព័រនេះលោក យៀវនិន បាននិយាយពីការប្រជុំមួយ ដែលគេអាចអះអាងថានឹងធ្វើឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥។ ផ្នែកមួយនៃសៀវភៅនោះ និយាយដូចខាងក្រោមនេះ៖

[១៣:៥៥:៤៩]

"ហេង សំរិន ដែលបានសិក្សាពីកិច្ចការយោធាក្រោម សុន សេន ក៏បាននៅក្នុងការប្រជុំនោះ ដែរ។ គាត់ក៏បាននឹកឃើញពីការប្រើពាក្យ គេមិនប្រើពាក្យថាសម្លាប់ទេ គេនិយាយថា កម្ចាត់ប្រជាជន នៅក្នុងរបបរដ្ឋាភិបាលចាស់។ ពាក្យថា "*ស្មេតទ័រ*" – កម្ចាត់នេះគឺកម្ចាត់ចេញមិនទុកឲ្យនៅក្នុងក្របខ័ណ្ឌ យើង។ មិនមែនមានន័យថាកម្ទេច ជាកម្ទេច។ កម្ទេចមានន័យថាសម្លាប់។ ប៉ុន្តែន័យទូទៅដែលគេប្រើ ថាកម្ចាត់។ នួន ជា បានប្រើឃ្លានេះ"។ បញ្ចប់សេចក្ដីដកស្រង់នៅក្នុងសៀវភៅ ប៉ែន យៀវនិន ត្រឹមនេះ។ ហើយខ្ញុំក៏សូមបញ្ជាក់បង្ហាញថានេះគឺជាសេចក្ដីដកស្រង់ដ៏គួរទុកចិត្តបាននៅក្នុងសៀវភៅ ប៉ែន យៀវនិន ដែលនិយាយអំពី នូ មោក នោះ ដែលខ្ញុំព្យាយាមពន្យល់ពីខាងដើមដែលខ្ញុំជំទាស់ថា ខ្លឹមសារនេះគឺមិន អាចគួរឲ្យជឿជាក់បានទេ។ ដោយហេតុថាសេចក្ដីដកស្រង់ នូ មោក ដោយសៀវភៅនេះជាពិសេស ទាញនូវសេចក្ដីដកស្រង់ជាមូលដ្ឋានមួយដែលប្រភពប្រាប់ឲ្យគាត់ដឹងនោះ។

លោកប្រធានឯកសារបន្ទាប់ដែលខ្ញុំបង្ហាញនោះគឺថានៅក្នុងសំណើដែលមេធាវីការពារក្ដី នួន ជា បានដាក់នៅក្នុងខែកុម្ភៈ ឆ្នាំនេះ។ គឺឯកសារ E236/51 ភាសាដែលខ្ញុំចង់ដកស្រង់ គឺនៅក្នុងកថាខ័ណ្ឌ ទីបីដែលនិយាយថា "ទំនាក់ទំនងរបស់ នួន ជា ជាមួយ TCW-223 គឺកើតឡើងមុនសន្និបាតទីក្រុង

ហ្សឺណែវ គឺ៦០ឆ្នាំមុននោះ”។

[១៣:៥៧:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

លោកប្រធាន នេះគឺជាឯកសារមួយដែលខ្ញុំមិនបានឃើញនៅក្នុងវិធី។ អ្វីដែលខ្ញុំបានស្តាប់ឮគឺវាហាក់ដូចជាថាមេធាវីបានអាចចេញមកអំពីពាក្យសុំខ្លួន។ ការដែលអានចេញមកពីសំណើរបស់ខ្លួនឯងគឺមិនចាត់ទុកថាឯកសារភស្តុតាង ឬដាក់ដេញដោលទេ។ ដូច្នេះ យើងសូមជំទាស់បើមេធាវីព្យាយាមអានទៅលើខ្លឹមសារសំណើរបស់ខ្លួនជាបន្តទៅទៀតនោះ។

**លោក វិចទ័រ កូប៉េ៖**

តាមពិត លោកប្រធាន យើងព្យាយាមនឹងកំណត់ឲ្យឃើញនូវបរិបទនៃការបង្ហាញភស្តុតាង។ ច្បាប់បានអនុញ្ញាតឲ្យយើងខ្ញុំបង្ហាញពីឯកសារអ្វីដែលយើងបានរៀបចំ។ ខ្ញុំមិនគិតថាមានកម្រិតថា អ្វីថាជាភស្តុតាង អ្វីជាការរៀបចំរបស់មេធាវីការពារក្តីទេ។ ដូច្នេះដោយហេតុតែមានការពិចារណា ឬក៏សម្រេចពីអង្គជំនុំជម្រះ យើងខ្ញុំនឹងដកស្រង់អំពីសំណើរបស់យើងខ្ញុំតទៅទៀត ហើយនិងយោងប្រើចេញទៅឯកសារនេះនឹងត្រូវឲ្យតុលាការចាត់ទុកថាជាឯកសារសំខាន់ផងដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៩:៥៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាលើការប្រើប្រាស់ក្នុងការអនុវត្តសិទ្ធិនៅក្នុងការបង្ហាញអត្ថាធិប្បាយ ឬការធ្វើការសង្កេតរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា មានលក្ខណៈសមស្រប។ ដូច្នេះលោកមេធាវីការពារក្តីលោកមិនអាចប្រើប្រាស់នូវវិធីសាស្ត្រក្នុងការដកស្រង់នូវសំណើសុំរបស់ខ្លួនយកមកធ្វើជាភស្តុតាងបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះបែបនេះទេ ពីព្រោះអង្គជំនុំជម្រះបានកំណត់តាមសំណើរបស់លោករួចហើយ គឺលោកឆ្លើយតបទៅនឹងបណ្តាឯកសារគន្លឹះដែលដាក់ដោយភាគីម្ខាងទៀត គឺតំណាងសហព្រះរាជអាជ្ញា ហើយនិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក។

នេះបានច្បាស់លាស់ហើយ ព្រោះលោកមេធាវីបានបញ្ជាក់ហើយថា ខ្លួនលោកមិនមានឯកសារគន្លឹះសម្រាប់ដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះទេ ប៉ុន្តែរក្សាសិទ្ធិក្នុងការអត្ថាធិប្បាយ ឬក៏កត់សម្គាល់ជំទាស់ទៅនឹងបណ្តាឯកសារមួយចំនួនដែលដាក់ឡើងដោយភាគីម្ខាងទៀត។

[១៤:០១:១៧]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ យើងខ្ញុំសូមបន្តទៅមុខទៀត។ ឯកសារបន្ទាប់ដែលខ្ញុំសូមបង្ហាញ ខ្ញុំមិនដឹងថា នៅពេលនេះ គឺអង្គជំនុំជម្រះហាមឃាត់ខ្ញុំមិនឲ្យបង្ហាញឯកសារបន្តទៀត ឬក៏យ៉ាងណានោះទេ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ--

**ប្រធានអង្គជំនុំ៖**

លោកអាចបានធ្វើការបង្ហាញឯកសារបន្តទៀត។ ប៉ុន្តែអង្គជម្រះមិនអនុញ្ញាតឲ្យលោកធ្វើបែបអម្បាញ់មិញនេះទេ! លោកដកបង្ហាញ ដកស្រង់នូវសំណើសុំរបស់លោកយកមកបង្ហាញនាពេលនេះនោះឡើយ គឺលោកអនុវត្តនៅក្នុងភារកិច្ចរបស់លោកគឺ -- ដែលតាមសំណើរបស់លោកគឺសុំធ្វើអត្ថា-ធិប្បាយ ឬក៏ឆ្លើយតបទៅនឹងបណ្តាឯកសារគន្លឹះដែលដាក់ឡើងដោយភាគីម្ខាងទៀត គឺសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់បង្ហាញចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី២៤ រហូតដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក។

[១៤:០២:១៥]

**លោក វ៉ិចទ័រ កូប៉េះ**

យើងខ្ញុំយល់លោកប្រធាន។ ខ្ញុំយល់ៗការណែនាំនេះ ទោះបីជាយើងមិននិយាយថា យើងទទួលការអនុញ្ញាតបង្ហាញនូវឯកសារគន្លឹះរបស់យើងខ្ញុំក៏ដោយ។ ការដែលណែនាំដូច្នេះ គឺទើបតែលើកឡើងក្នុងរយៈពេល២ថ្ងៃចុងក្រោយនេះទេ។ ដូច្នេះបើសិនមិនឲ្យខ្ញុំបង្ហាញឯកសារគន្លឹះរបស់ខ្ញុំមិនជាការ -- មិនជាអ្វីនោះទេ ក៏ប៉ុន្តែខ្ញុំនឹងបង្ហាញនូវអ្វីដែលនៅសល់ ហើយអ្វីដែលខ្ញុំចង់លើកឡើងពាក់ព័ន្ធទៅនឹងគោលនយោបាយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៣:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍៖**

ខ្ញុំគិតថា លោក កូប៉េ គាត់ -- លោកយល់ហើយលោកប្រធានបានបង្គាប់។ អង្គជំនុំជម្រះក៏បានបង្គាប់ថា លោកមិនអាចដកស្រង់ជាឯកសារគន្លឹះទៅតាមសេចក្តីសន្និដ្ឋាន ឬក៏សំណើសុំរបស់លោកនោះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះស្វាគមន៍យោបល់របស់លោកលើឯកសារទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយដែលមាននៅក្នុងសំណុំរឿង។ នេះជាគោលបំណងនៃវគ្គសវនាការដែលអនុញ្ញាតឲ្យលោកលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងថ្ងៃនេះ។

[១៤:០៥:១៣]

លោកអាចបន្តលើកឡើងឯកសារគន្លឹះរបស់លោក គឺបានន័យថា ឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងឯកសារដែលមាននៅក្នុងសំណុំរឿង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយធ៍។ ដូច្នេះអនុញ្ញាតឲ្យខ្ញុំលោកប្រធានបន្តឯកសារមួយទៀតដែលខ្ញុំមានបំណងធ្វើការបង្ហាញ គឺឯកសារចេញមកពីកំណត់ហេតុស្តាប់ចម្លើយ ក.ស.ច.ស ដែលមាននៅចំពោះមុខអង្គជំនុំជម្រះរូបនេះ -- ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ គឺកំណត់ហេតុរបស់សាក្សី រ៉ាចាម តុន ហៅ ភី ភួន។ ឯកសារលេខ E3/24, ចំណុចដែលដកស្រង់នោះ គឺត្រង់ ERN ជាភាសាងអង់គ្លេស 00223582, ខ្មែរគឺ 00204069។

ខ្ញុំសូមអធ្យាស្រ័យចៅក្រម ឡាវែន៍ ដោយសារតែនៅពេលនេះ ខ្ញុំអត់មានលេខ ERN ជាភាសាបារាំងទេ ខ្ញុំនឹងផ្តល់ឲ្យពេលក្រោយ។ សំណួរដែលសួរទៅកាន់សាក្សីនោះគឺថា “តើមានការបញ្ជាឲ្យធ្វើការស្វែងរកទាហាន លន់ នល់ ដែរឬទេ?” ចម្លើយរបស់លោក ភី ភួន នោះ គឺបានឆ្លើយដូចតទៅ “អត់មានទេ។ ដោយសារតែទាហានទាំងអស់នោះលើកទង់ជ័យសរួចទៅហើយ។ មានការណែនាំច្បាស់លាស់ថា កុំឲ្យប៉ះពាល់ពួកគេក្នុងពេលសង្គ្រាមលើសមរភូមិវាមានលក្ខណៈខុស។ ក៏ប៉ុន្តែនៅពេលនោះ ពួកគេចុះចាញ់ យើងមិនប៉ះពាល់ពួកគេ គ្រាន់តែស្វាគមន៍ពួកគេ ហើយឆ្លើយតបទៅនឹងសំណូមពរដែលពួកគេស្នើសុំ”។ គាត់លើកឡើងថា “ទាហានទាំងអស់នោះ ក៏ជាជនកម្ពុជាដូចយើងដែរ កុំប៉ះពាល់ពួកគេអ្វីឲ្យសោះ”។ នេះជាពាក្យសម្តីរបស់ ប៉ុល ពត។

[១៤:០៦:១២]

ប្រសិនបើអនុញ្ញាត ខ្ញុំនឹងលើកឡើងយោបល់បន្ថែមពាក់ព័ន្ធទៅនឹងកំណត់សាក្សីមួយទៀតផងដែរ។ អង្គជំនុំជម្រះប្រហែលជានៅចងចាំហើយ នៅពេលដែល ហ្វីលីព ស្បូត គាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយសម្លាប់ទាហាន លន់ នល់ ដែលគាត់លើកឡើងថាជាការពិត។ បន្ទាប់ពីយើងធ្វើការពិនិត្យទៅលើគាត់នោះ គឺគាត់អាចបញ្ជាក់ប្រភពមួយដែលគឺវាពាក់ព័ន្ធទៅនឹងការដែលបុគ្គលនោះដឹងអំពីការសម្លាប់ទាហាន លន់ នល់។ តែប្រភពនោះគឺមានចេញមកពីចម្លើយរបស់ ភី ភួន។ មានសាក្សីដទៃដែលខ្ញុំអាចដកស្រង់សម្តីរបស់ពួកគេ ក៏ប៉ុន្តែខ្ញុំនឹងលើកឡើងតែសាក្សីមួយទៀតតែប៉ុណ្ណោះ។ ខ្ញុំដកស្រង់សាក្សីមួយនេះ ដោយដើម្បីឲ្យអង្គជំនុំជម្រះមើលឃើញអំពីឧទាហរណ៍ដែលទាហានបានវាយនៅសមរភូមិ ហើយគាត់និយាយអំពីបញ្ហាដែលគាត់បានទទួលដូចៗគ្នា។ វាមាននៅក្នុងប្រតិចារឹក។ ខ្ញុំគិតថាលោកប្រធានអនុញ្ញាតឲ្យខ្ញុំលើកឡើង គឺឯកសារប្រតិចារឹកចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២។ ហើយខ្ញុំឃើញសហព្រះរាជអាជ្ញាគាត់ក្រោកឈរ ដូច្នេះបន្តទៅមុខទៀត រំលងកន្លែងនេះ។

នៅពេលនេះ អ្វីដែលខ្ញុំចង់លើកឡើងគឺខ្ញុំនិយាយអំពីកំណត់ហេតុស្តាប់ចម្លើយដែលសហព្រះរាជអាជ្ញាបានបង្ហាញ។ សហព្រះរាជអាជ្ញាអានចេញមកពីកំណត់ហេតុចំនួនបីនៅក្នុងតុលាការ។ នៅពេលដែលគាត់បានបញ្ចប់ សហព្រះរាជអាជ្ញាបានលើកឡើង ខ្ញុំសូមលើកឡើងដកស្រង់សម្តីរបស់ពួកគាត់។ “មានកំណត់ហេតុសាក្សីជាច្រើនទៀតដែលខ្ញុំអាចអានឲ្យអង្គជំនុំជម្រះ។ អ្នកដែលត្រូវបានយើងកំណត់នៅក្នុងកំណត់ហេតុ ដែលថាជាសាក្សីពាក់ព័ន្ធអាចបង្ហាញអំពីគោលនយោបាយ”។ បញ្ចប់ការដកស្រង់។

[១៤:០៨:១៦]

ខ្ញុំចង្អុលចំណុចនេះ ទៅកាន់អង្គជំនុំជម្រះដោយសារតែវាបង្ហាញយ៉ាងច្បាស់អំពីខ្លឹមសារនៃរឿងក្តីរបស់សហព្រះរាជអាជ្ញា។ ភស្តុតាងផ្ទាល់នៃស្តីអំពីបញ្ហាគោលនយោបាយ គឺវាមិនមានឡើយ។ ដូច្នេះសហព្រះរាជអាជ្ញាព្យាយាមឲ្យអង្គជំនុំជម្រះនេះ វិលវល់ទៅនឹងចម្លើយដែលលើកឡើងថា ការកាប់សម្លាប់នោះគឺវាបានកើតឡើង ហើយវាលក្ខណៈរីករាលដាល ហើយបានធ្វើឡើងគោរពទៅតាមគោលនយោបាយ។ ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា នៅពេលដែល ហ្វីលីព ស្បូត បានផ្តល់សក្ខីកម្មនោះ គឺវាក៏មានសារៈសំខាន់ដែលទៅលើចម្លើយរបស់គាត់ ហើយគាត់មានការលើកឡើងទៅលើបញ្ហាគោលនយោបាយនេះផងដែរ។

ខ្ញុំលើកឡើងចំណុចនេះ ដើម្បីពន្យល់យោបល់របស់ខ្ញុំ ដើម្បីឆ្លើយឲ្យបានត្រឹមត្រូវនូវអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង ជាពិសេសនៅក្នុងការបង្ហាញឯកសារគន្លឹះ។ ខ្ញុំត្រូវលើកឡើងសេចក្តីសន្និដ្ឋានទូទៅអំពីចម្លើយរបស់សាក្សីដែលមានប្រតិចារឹក។ ជំហររបស់សហព្រះរាជអាជ្ញាមានលក្ខណៈសំខាន់ណាស់។ ខ្ញុំសូមដកស្រង់ឡើងវិញ គាត់លើកឡើងថា មានចម្លើយសាក្សីជាច្រើនដែលលើកឡើងអំពីគោលនយោបាយនេះ។ យើងបានធ្វើការវិភាគដោយផ្ទាល់ទៅលើចម្លើយដែលវាពាក់ព័ន្ធទៅនឹងគោលនយោបាយនេះ ហើយយើងបានមើលចម្លើយដែលបានដកស្រង់នៅក្នុងចំណុចចំនួនពីរ។ ទី១ គឺយើងមើលចម្លើយដែលដកស្រង់ ក.ស.ច.ស ពាក់ព័ន្ធទៅនឹងអ្វីដែលគាត់លើកឡើងនៅក្នុងដីកាដំណោះស្រាយ។ ហើយយើងបានមើលទៅលើបញ្ជីចម្លើយ និងបណ្តឹងរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយករួចមកហើយនោះ។

[១៤:១០:០៦]

យើងបានរកឃើញចម្លើយប្រហែលជាង១០០ ដែលសហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញា សហមេធាវីនាំមុខ រួមគ្នាបានលើកឡើងថា វាពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយក្នុងការកំណត់គោលដៅទាហាន និងមន្ត្រីរដ្ឋការសម័យសាធារណរដ្ឋខ្មែរ។ ខ្ញុំដឹងថា ១០០ហ្នឹងច្រើនណាស់ស្តាប់ទៅ។ ប៉ុន្តែនិយាយឲ្យត្រង់ទៅ សហព្រះរាជអាជ្ញាគឺគាត់បានបង្ហាញជំហររបស់គាត់ដូចដែលគាត់បានលើកឡើងរួចមកហើយនៅពេលដែលគាត់បង្ហាញអំពីឯកសារគន្លឹះ។ ចំណុចហ្នឹងហើយដែលយើងឲ្យមានការជំនុំជម្រះធ្វើការតេស្តសាកល្បងទៅលើភស្តុតាង ដើម្បីឲ្យយើងពិនិត្យភស្តុតាងទាំងអស់នោះមានលក្ខណៈប្រុងប្រយ័ត្នដោយមិនលម្អៀង ហើយថាតើវាមានចន្លោះប្រហោងដែរឬទេនៅក្នុងចម្លើយភស្តុតាងទាំងអស់នោះ។

ដូចដែលខ្ញុំបានលើកឡើង យើងបានអាន យើងខ្ញុំបានអានកំណត់ហេតុទាំងអស់នោះបានលម្អិត យើងមិនអាចនៅក្នុងពេលនេះបង្ហាញឯកសារចម្លើយជាង១០០នេះក្នុងលក្ខណៈមួយត្រឹមត្រូវ ឲ្យបានត្រឹមត្រូវបំផុតនោះទេ ដោយសារតែយើងខ្ញុំមិនមានពេលវេលា ក៏ប៉ុន្តែខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា សូម្បីតែមួយនៅក្នុងកំណត់ហេតុហ្នឹងគឺមិនមានសាក្សីណាមួយគាត់បានលើកឡើងថា គាត់បានឃើញនូវការកាប់សម្លាប់នោះឡើយ។ យើងខ្ញុំសូមលើកឡើងថាទោះបីជាសហព្រះរាជអាជ្ញាលើកឡើងក៏ដោយដែលគាត់លើកឡើងថាមានគោលនយោបាយតម្រូវឲ្យសម្លាប់ទាហាន លន់ នល់ និងមន្ត្រី លន់ នល់ នៅក្នុងប្រទេសនោះ គឺការលើកឡើងនេះគឺវាមានលក្ខណៈចម្លែកណាស់ ក៏ប៉ុន្តែការអះអាងរបស់សហ-

ព្រះរាជអាជ្ញានៅក្នុងពេលគាត់បង្ហាញឯកសារគន្លឹះរបស់គាត់នោះ មិនទំនងជាអ៊ីចឹងនោះទេ។

[១៤:១២:០៥]

សាក្សីនៅក្នុងចម្លើយជាង១០០នោះ គាត់មិនបានឃើញនូវការកាប់សម្លាប់នោះទេ។ អ៊ីចឹងចម្លើយនោះបានលើកឡើងអ្វីខ្លះ? គេលើកឡើងចំណុចនានា សាក្សីខ្លះគាត់លើកឡើងថា គាត់ឃើញទាហាន និងមន្ត្រីសាធារណរដ្ឋត្រូវបានគេបំបែកចេញពីក្រុមធំៗ ក៏ប៉ុន្តែមិនដឹងថាមានជោគវាសនាអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះទេ។ យើងបានលើកឡើងរួចមកហើយ ហេតុអ្វីបានជាភស្តុតាងប្រភេទហ្នឹងមិនគួរឲ្យជឿជាក់បាន ហើយវាមិនមានតម្លៃជាភស្តុតាងនោះ យើងខ្ញុំបានបង្ហាញរួចមកហើយ។ សាក្សីផ្សេងទៀតបានឃើញបានលើកឡើងថាគាត់ឃើញសាកសពទាហាននៅតាមផ្លូវ នៅក្នុងឬក៏ជុំវិញទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ភ្លាមតែម្តង។ ដោយសារតែទាហានទាំងអស់នោះត្រូវបានចុះចាញ់នៅក្នុងពេលសង្គ្រាម ដូច្នេះគឺសាកសពដែលឃើញនៅតាមផ្លូវនោះ វាជារឿងមួយដែលយើងនិយាយសាមញ្ញថាជា -- គ្មានអ្វីដែលវាគិតថាវាកើតវិញពីការកាប់សម្លាប់នោះទេ។ វាជារឿងសាមញ្ញ។

[១៤:១៣:១៧]

ចម្លើយទាំងអស់នោះរបស់សាក្សីជាង១០០នោះ គឺគាត់បានត្រឹមតែលើកឡើងថា មិត្តភក្តិរបស់គេ សាច់ញាតិរបស់គេដែលធ្វើការនៅក្នុងរបប លន់ នល់ ត្រូវបានគេសម្លាប់។ នៅក្នុងករណីភាគច្រើនគ្មានហេតុផលណាមួយដែលគេលើកឡើងថា អ្នកដែលត្រូវបានគេសម្លាប់នោះ ដោយសារតែពួកគេជាទាហាន លន់ នល់ នោះទេ។ ចម្លើយទាំងបីដែលលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងបទបង្ហាញរបស់គាត់នោះ គឺវាពាក់ព័ន្ធទៅនឹងការចោទប្រកាន់តែប៉ុណ្ណោះ។ ឯកសារទី១ គឺឯកសារ D25/28 ពាក់ព័ន្ធទៅនឹងគុកក្រាំងតាចាន់ ដែលនៅក្នុងសហករណ៍ត្រាំកក់។ សាក្សីបានលើកឡើង ខ្ញុំសូមដកស្រង់៖ "នៅពេលពួកគេមកដល់ទីនោះ ពួកគេបាន គេឲ្យពួកគេធ្វើប្រវត្តិរូប ហើយអ្នកដែលលើកឡើងក្នុងប្រវត្តិរូបថាជាទាហាននោះនឹងបាត់ខ្លួន"។ ក៏ប៉ុន្តែចម្លើយនេះបានបង្ហាញថា -- នៅត្រង់ERN ជាភាសាអង់គ្លេស 00223475, ចម្លើយនេះបានលើកឡើងថា សាក្សីគ្មានតួនាទីអ្វីសោះនៅក្នុងមន្ទីរសន្តិសុខ ឬគុកក្រាំងតាចាន់នោះ។ គាត់គ្រាន់តែបានទៅទីនោះម្តងដើម្បីធ្វើការពិនិត្យទៅលើករណីដែលបានកើតឡើងដោយ-សារតែមានបុគ្គលម្នាក់ត្រូវបានគេចោទថាត្រូវបានគេរំលោភ។ ដូច្នេះ គាត់មិនបានដឹងអ្វីផ្ទាល់អំពីការកើតឡើងនៅគុកនោះឡើយ។

[១៤:១៤:៤៥]

សាក្សីនៅក្នុងចម្លើយទី២ គឺឯកសារ D232/44 បានប្រាប់ចៅក្រមស៊ើបអង្កេតថា តាមអ្វីដែលគាត់ដឹងនោះអ្នកដែលត្រូវបានគេជម្លៀសនោះត្រូវបានគេយកទៅសម្លាប់ចោល។ បន្ទាប់មក គាត់បានលើកឡើងថា អ្នកដែលបញ្ជាក់ថាពួកគេជាទាហាន លន់ នល់ នៅពេលដែលពួកគេមកដល់។ ខ្ញុំសូមដកស្រង់ "ក្រោយមកគ្រាន់តែបាត់ខ្លួនប៉ុណ្ណោះ"។ គាត់ក៏ -- សាក្សីនេះបានលើកឡើងថា មានមនុស្សជាច្រើនទៀតត្រូវបានគេសម្លាប់ ក៏ប៉ុន្តែគាត់មិនថាអ្វីដែលគាត់បានដឹងនេះគឺជាការដឹងដោយផ្ទាល់នូវហេតុការណ៍អ្វីដែលគាត់បានឃើញនោះទេ ក្រោយពីពួកគេបាត់ខ្លួន។

សាក្សីនៅក្នុងកំណត់ហេតុទី៣ ឯកសារ D125/91 បានលើកឡើងថា -- ខ្ញុំដកស្រង់សម្តីគាត់ "គាត់ឃើញគេបណ្តើរមនុស្សរាប់រយនាក់ទៅសម្លាប់ចោល"។ បញ្ចប់ការដកស្រង់សម្តីរបស់គាត់។ គាត់មិនបានលើកឡើងថា គាត់បានឃើញការសម្លាប់នោះដោយផ្ទាល់នោះទេ គ្មានការបង្ហាញណាមួយនៅក្នុងចម្លើយដែលថាគាត់ដឹងនេះពីណាមកទេ។ ហើយអ្នកស៊ើបអង្កេតនោះក៏មិនខ្វល់សួរចំណុចហ្នឹងទៀតទៅកាន់សាក្សីរូបនេះ។

[១៤:១៥:៥៧]

លោកប្រធាន ខ្ញុំឱ្យអង្គជំនុំជម្រះធ្វើការពិនិត្យមើលចម្លើយទាំងបីនេះឡើងវិញ ដែលសហព្រះរាជអាជ្ញាគាត់បានជ្រើសរើសយកមកធ្វើជាគំរូនៃភស្តុតាង ដែលបង្ហាញថាអតីត និងមន្ត្រីរដ្ឋការសម័យសាធារណរដ្ឋខ្មែរត្រូវបានគេសម្លាប់ជាលក្ខណៈប្រព័ន្ធ។ ភស្តុតាងប្រភេទ គឺវាមិនស៊ីសង្វាក់គ្នានៅក្នុងពេលដេញដោលនោះទេ ដូចដែលយើងបានឃើញកាលពីការស្តាប់សាក្សីរបស់លោកសាក្សីពីរនាក់ គឺលោក ឡាំ ហើយជាមួយនឹងសាក្សីមួយរូបទៀត។

ហើយខ្ញុំនឹងធ្វើការពិភាក្សាលើភស្តុតាងសាក្សីទាំងពីរនោះទេ លោកប្រធាន លោក លោកស្រីចៅក្រមបានស្តាប់ហើយប្រាកដជាចាំ។ វាបានបង្ហាញថានៅក្នុងពេលផ្តល់សក្ខីកម្មនោះ គ្មានសាក្សីទាំងពីរនោះគឺគាត់បានបង្ហាញថា ដូចដែលអ្វីដែលគាត់បានលើកឡើងនោះទេ -- ដូចអ្វីដែលគេបានលើកឡើងនោះទេ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកមេធាវី!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធានសូមអរគុណ។ ខ្ញុំចង់ឲ្យឱកាសទៅដល់មេធាវីការពារក្ដីធ្វើការបង្ហាញតាមរបៀបរបស់គាត់។ យើងមិនជំទាស់នូវការលើកឡើងនូវយោបល់អំពីតម្លៃនៃចម្លើយទាំងបីនោះទេ។ ប៉ុន្តែអ្វីដែលខ្ញុំជំទាស់នោះគឺថា គាត់ព្យាយាមនៅពេលនេះធ្វើសេចក្ដីសន្និដ្ឋាន និងផ្ដល់ទឡ្ហីករណ៍អំពីភាពជឿជាក់ចំពោះសាក្សីដែលមកផ្ដល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះនេះ។

[១៤:១៧:២៩]

ខ្ញុំក៏ជំទាស់ផងដែរ ចំពោះការព្យាយាមរបស់គាត់នាពេលមុនៗ ដែលគាត់ជាអ្នកឆ្លើយខ្លួនឯងទៅលើខ្លឹមសារដែលគាត់បានពិនិត្យមើល។ គាត់បានលើកឡើងថា ចម្លើយទាំងអស់នោះមិនបានលើកឡើងអំពីការកាប់សម្លាប់ទាហាន លន់ នល់ នោះទេ។ គាត់ថាការលើកឡើងដូច្នេះ នៅក្នុងចម្លើយគឺមិនត្រឹមត្រូវនោះទេ។ មេធាវីការពារក្ដីនៅពេលនេះមិនមែនជាសាក្សីនោះទេ។ គាត់មានលទ្ធភាពបង្ហាញចម្លើយសាក្សីដែលគាត់ចង់ គាត់មានសិទ្ធិផ្ដល់យោបល់ ក៏ប៉ុន្តែគាត់មិនមែននៅទីនេះមកផ្ដល់សេចក្ដីសង្ខេបចម្លើយរបស់សាក្សីនោះទេ គឺគាត់មិនអាចផ្ដល់ទឡ្ហីករណ៍នៅទីនេះទេ។ ខ្ញុំជំទាស់ទៅលើការផ្ដល់ទឡ្ហីករណ៍ និងការធ្វើសេចក្ដីសន្និដ្ឋានទៅលើចម្លើយរបស់សាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំមានចំណុចមួយ ឬក៏ពីរតែប៉ុណ្ណោះដែលចង់លើកឡើងចុងក្រោយ ពាក់ព័ន្ធទៅនឹងគោលនយោបាយក្នុងការកំណត់គោលដៅទាហាន និងមន្ត្រីរដ្ឋការលន់ នល់។ បន្ទាប់មកខ្ញុំនឹងបញ្ចប់លើបញ្ហាគោលនយោបាយ ឬក៏ចំណុចដែលខ្ញុំឆ្លើយតបទៅលើឯកសារគន្លឹះ។

[១៤:១៨:៤២]

យោបល់របស់ខ្ញុំចុងក្រោយ គឺមានដូចតទៅ: វាទំនងជាបង្ហាញឲ្យឃើញថា តាមរយៈចម្លើយដែលលោកប្រធាន និងលោក លោកស្រីចៅក្រមបានលើកឡើងនៅក្នុងពេលរៀបចំសវនាការថ្ងៃទី១៣ ខែមិថុនា ដែលអង្គជំនុំជម្រះបានប្រជុំនាពេលនោះ ក៏បានប្រជុំពិចារណាទៅលើចម្លើយរបស់សាក្សី។ ជំហររបស់យើងខ្ញុំ គឺថាសេចក្ដីសម្រេចនាពេលនោះ គឺធ្វើឡើងដោយមិនបានពិនិត្យទៅលើច្បាប់ដែលអនុវត្តជាធរមានបាន ជាការរំលោភសិទ្ធិរបស់លោក នួន ជា។ ប្រសិនបើចម្លើយរបស់សាក្សីទទួលយកបាននោះ គឺថាអង្គជំនុំជម្រះគួរតែពិនិត្យទៅលើសេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១២, សេចក្ដីសម្រេចលេខ E96/7។ អង្គជំនុំជម្រះបានសម្រេចទៅលើបញ្ហានេះ ក៏ប៉ុន្តែប្រសិនបើ

ទទួលយកចម្លើយទាំងអស់នោះនោះ ដោយមិនឲ្យដេញដោលនោះ យើងគួរតែផ្ដល់តម្លៃតិចតួចបានហើយ។

[១៤:១៩:៥២]

ដោយសារហេតុនេះ ខ្ញុំគិតថា ឯកសារកំណត់ហេតុទាំងអស់នោះវាគ្មានតម្លៃអ្វីដែលខ្លាំងក្លានោះទេ ហើយយើងត្រូវពិចារណាចំណុចនេះឲ្យបានហ្មត់ចត់លោកប្រធាន។ ទោះបីជាយើងបានដោះស្រាយទៅលើបញ្ហាទាំងឡាយពាក់ព័ន្ធទៅនឹងការទុកចិត្តនៃចម្លើយ និងតម្លៃនៃភស្តុតាង ហើយទទួលយកកំណត់ហេតុទាំងអស់នោះក៏ដោយ យើងនៅតែមិនអាចបង្ហាញថា គោលនយោបាយនៃការកាប់សម្លាប់ទាហាន និងមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរនោះមិនមានឡើយ។ ដោយសារហេតុនេះគឺដោយសារតែហេតុការណ៍ទាំងអស់នោះ វាកើតឡើងទៅនឹងហេតុការណ៍នៅភូមិភាគពាយ័ព្យ និងនិរតី។ ហើយប្រសិនបើគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជាមានអត្ថិភាពមែននោះ ភស្តុតាងនោះនឹងបង្ហាញការកាប់សម្លាប់នៅទូទាំងប្រទេស។

ភស្តុតាងបានបង្ហាញអំពីការកាប់សម្លាប់នៅភូមិភាគចំនួនប្រាំ ក្នុងចំណោមភូមិភាគចំនួនប្រាំពីរនោះ យើងមិនឃើញមានឡើយ។ ជាការពិត យើងមិនបានបង្ហាញចំណុចទាំងអស់នេះក្នុងលក្ខណៈប្រព័ន្ធនៅក្នុងថ្ងៃនេះ ក៏ប៉ុន្តែយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការពិនិត្យទៅលើកំណត់ហេតុសាក្សីចំនួនបីដែលសហព្រះរាជអាជ្ញាស្នើសុំនៅក្នុងពេលប្រជុំរៀបចំសវនាការនៅថ្ងៃ១៣ ខែមិថុនា ដែលសាក្សីពាក់ព័ន្ធទៅនឹងភូមិភាគពាយ័ព្យ និងនិរតី។ សាក្សីទាំងបីនោះ ដូចដែលសហព្រះរាជអាជ្ញាបានបង្ហាញគឺគាត់មកពីភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។

[១៤:២១:៣៧]

ដីកាដំណោះស្រាយត្រង់កថាខណ្ឌ២០៩ គឺបានលើកឡើងថា “មន្ត្រីទាំងឡាយត្រូវបានគេកំណត់គោលដៅ”។ នេះគឺជាការវិភាគរបស់យើងខ្ញុំ និងការបង្ហាញរបស់ខ្ញុំពាក់ព័ន្ធទៅនឹងចំណុចនេះ ហើយយើងខ្ញុំនឹងលើកឡើងចំណុចលម្អិតនៅក្នុងសេចក្ដីសន្និដ្ឋានបិទការដេញដោលរបស់ខ្ញុំ។

លោកប្រធាន លោក លោកស្រីជាទីគោរព! ទាំងអស់នេះគឺជាយោបល់របស់ខ្ញុំឆ្លើយតបទៅនឹងការបង្ហាញឯកសារគន្លឹះពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅលើខ្មាំង។ នៅពេលនេះខ្ញុំសូមចូលទៅដល់ការឆ្លើយតបរបស់ខ្ញុំពាក់ព័ន្ធទៅនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញា និងមេធាវីតំណាងបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ។

នៅពេលនេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យទៅលើដីកាដំណោះស្រាយ ដូចដែលអង្គជំនុំជម្រះបានជ្រាបរួចមកហើយ ចំណងជើងនៃគោលនយោបាយនេះនៅក្នុងដីកាដំណោះស្រាយគឺការចាត់ចែងរៀបចំទៅលើការរៀបការ។ ក៏ប៉ុន្តែអង្គហេតុជាក់លាក់ គឺចោទប្រកាន់លក្ខណៈជាក់លាក់ជាងនេះ។

[១៤:២២:៥៥]

កថាខណ្ឌ២១៦បានលើកឡើងថា -- គឺកថាខណ្ឌ២១៦ នៅក្នុងដីកាដំណោះស្រាយលើកឡើងថា "បក្សកុម្មុយនីស្តកម្ពុជាបង្ខំឲ្យប្តីប្រពន្ធរៀបការជាមួយគ្នានៅពេលដែលក្រោយពីពួកគេកាន់កាប់នៅលើទឹកដីប្រទេសកម្ពុជានៅមុនឆ្នាំ៧៥ និងបន្តធ្វើដូច្នេះរហូតទៅដល់ថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៩"។ កថាខណ្ឌ២១៨ លើកឡើងថា "ភស្តុតាងបានបង្ហាញថាបក្សកុម្មុយនីស្តកម្ពុជាបង្ខំឲ្យប្រជាជនរៀបការនៅដើមឆ្នាំ១៩៧៤"។ ការចោទប្រកាន់ផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយក៏មានលក្ខណៈស្រដៀងគ្នានេះដែរ។ បញ្ហាចោទនៅក្នុងការបង្ហាញឯកសារនេះ គឺថាតើបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយមួយក្នុងការបង្ខំប្រជាជនឲ្យរៀបការជាមួយគ្នាដែរឬទេ? ដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ បទបង្ហាញរបស់សហព្រះរាជអាជ្ញាចោទប្រកាន់ថា "ប្តីប្រពន្ធត្រូវបានគេបង្ខំឲ្យរៀបការជាមួយគ្នា ដោយសារថាគោលនយោបាយនោះវាបានជួយសម្រេចទៅដល់គោលដៅនៃបដិវត្តន៍"។

នៅពេលនេះ យើងសូមឲ្យអង្គជំនុំជម្រះចោទសំណួរសាមញ្ញមួយ។ ប្រសិនបើការរៀបការដោយបង្ខំគឺជាគោលការណ៍ចម្បងនៃបដិវត្តន៍ក្នុងការសម្រេចគោលដៅថា បដិវត្តន៍នេះវាមានលក្ខណៈសំខាន់នោះ តើហេតុអ្វីយើងមិនឃើញថាគោលនយោបាយនោះត្រូវបានគេប្រកាសក្តែងៗដោយបក្សទៅ? សំណួរយើងអាចសួរថា តើបក្សកុម្មុយនីស្តកម្ពុជានេះមានការអៀនខ្មាសចំពោះគោលបំណងរបស់ខ្លួនដែលខ្លួនគិតថាសំខាន់នោះ ឬក៏យ៉ាងម៉េច? ហើយហេតុអ្វីបានជាបក្សនោះគាត់មិនលើកឡើងឲ្យច្បាស់លាស់ថាប្រជាជនទាំងអស់ត្រូវតែចាកចេញពីក្រុង ហើយរស់នៅតាមសហករណ៍នៅតាមទីជនបទ?

[១៤:២៥:00]

យើងឃើញមានចំណុចស៊ីសង្វាក់គ្នាមួយនៅក្នុងឯកសារបង្ហាញដោយសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាមិនបានលើកឡើងអំពីការរៀបការដោយបង្ខំនោះទេ។ ឯកសារទាំងអស់នេះភាគច្រើនដែលសហព្រះរាជអាជ្ញាបានបង្ហាញគ្មាននិយាយអ្វីទាល់តែសោះអំពីការរៀបការ។ សហព្រះរាជអាជ្ញាស្នើ សុំអង្គជំនុំជម្រះឲ្យធ្វើដំណើររួមជាមួយពួកគាត់នេះនៅក្នុងការបង្ហាញហេតុផលមួយដែលមានលក្ខណៈស្មុគស្មាញ។ សហព្រះរាជអាជ្ញាចង់ឲ្យអង្គជំនុំជម្រះសម្រេចដូចតទៅ៖ ទី១ បក្សកុម្មុយនីស្តកម្ពុជាមាន

គោលបំណងរបស់គេដូចជាការបង្កើនចំនួនប្រជាជន។ ការបង្កើនប្រជាជននេះវាអាចពាក់ព័ន្ធដោយមិនច្បាស់លាស់ទេជាមួយគោលនយោបាយនៃការរៀបការដោយបង្ខំ។ ហើយសម្រេចចំណុចទី២ ដែលថាការរៀបការដោយបង្ខំនោះគឺបានកើតឡើង។ ហេតុដូច្នេះ អង្គជំនុំជម្រះចង់ឲ្យអង្គជំនុំជម្រះសម្រេចថាការរៀបការដោយបង្ខំនោះត្រូវ -- គឺពិតជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:២៦:០៥]

ជាការពិតវាមិនគ្រប់គ្រាន់នោះទេ ប្រសិនបើ -- បើសិនជាការរៀបការដោយបង្ខំនោះស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះវគ្គនេះ។ ប៉ុន្តែវាមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនោះឡើយ។ ដោយវាមានន័យថា ភស្តុតាងនៃការរៀបការដោយបង្ខំមិនអាចទទួលយកបាននោះទេ។ វាមានន័យថាអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងនៅសល់នោះវាគឺជាទ្រឹស្តីនយោបាយមួយដែលមិនច្បាស់លាស់។

ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការពិនិត្យឯកសារដែលពាក់ព័ន្ធទៅនឹងគោលនយោបាយ ហើយខ្ញុំសូមបង្ហាញអង្គជំនុំជម្រះថាការកំណត់លក្ខណៈនៃភស្តុតាងទាំងអស់នោះគឺវាមានលក្ខណៈមួយត្រឹមត្រូវ។

សហព្រះរាជអាជ្ញាចាប់ផ្តើមបង្ហាញឯកសារលើការរៀបការដោយបង្ខំ ដោយខ្លួនជឿថាឯកសារទាំងអស់នោះវាពាក់ព័ន្ធទៅនឹងគោលនយោបាយ។ គោលបំណងចុងក្រោយរបស់របបនោះគឺកំណើនប្រជាជន។ ការសម្ភាសរបាយការណ៍ទាំងអស់នេះរួមទាំងទស្សនាវដ្តីទង់បដិវត្តន៍ឯកសារលេខ E3/25 សុន្ទរកថារបស់ អៀង សារី, ឯកសារE3/1586 និងការសម្ភាសជាមួយនឹង នួន ជា, ឯកសារលេខ E3/686។ ឯកសារទាំងអស់នេះត្រូវបានគេលើកឡើងថា វាជាផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាបង្កើនចំនួនប្រជាជនកម្ពុជា ពី១៥ ទៅ២០លាន ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយពេលរំដោះ។

[១៤:២៧:៥២]

នៅក្នុងការយល់ឃើញរបស់សហព្រះរាជអាជ្ញា ដើម្បីសម្រេចឲ្យបាននូវកំណើនប្រជាជននេះបក្សកុម្មុយនីស្តកម្ពុជាត្រូវតែបង្ខំពលរដ្ឋកម្ពុជាឲ្យរៀបការដោយបង្ខំ។ ទោះបីជាទឡ្ហីករណ៍ដែលថាផែនការបង្កើនចំនួនប្រជាជននោះមានអត្ថិភាពក៏ដោយ នៅពេលដែលយើងអានឯកសារនោះ គឺគ្មានការលើកឡើងអំពីការរៀបការដោយបង្ខំនៅក្នុងឯកសារទាំងអស់នោះឡើយ។ ជាការពិត ឯកសារនោះលើកឡើងផ្សេងពីនោះទៅវិញ ហើយនិយាយដោយត្រង់ទៅក្នុងលក្ខណៈមួយជាក់ស្តែងអំពីវិធីក្នុងការបង្កើនប្រជាជន។ ឧទាហរណ៍គេលើកឡើងអំពីការលើកកម្ពស់បទដ្ឋានរស់នៅ និងសុខភាពប្រជាជនសាមញ្ញនៅទូទាំងប្រទេស។

ឯកសារ E3/25 គឺជាឯកសារទង់បដិវត្តន៍ពីខែធ្នូ ឆ្នាំ៧៦ ទៅមករា ឆ្នាំ៧៧។ សហព្រះរាជអាជ្ញាបានដកស្រង់នូវអត្ថបទដូចតទៅនេះ គឺត្រង់ ERN 00491435។ “យើងត្រូវការមនុស្សពី ១៥ ទៅ ២០លានដើម្បីបំពេញតម្រូវការដីរបស់យើង។ ដើម្បីឲ្យប្រជាជនមានការកើនឡើងជាដរាបនោះ ជីវភាពរបស់ប្រជាជនត្រូវតែមានលក្ខណៈល្អជាងមុន ហើយពួកគាត់ត្រូវតែមានសុខភាពល្អ។ មធ្យោបាយនេះគឺអាចបង្កើនផលិតកម្មបានយ៉ាងលឿន”។

[១៤:២៩:២៣]

ឯកសារ E3/1586 សុន្ទរកថារបស់លោក អៀង សារី ដែលសហព្រះរាជអាជ្ញាអះអាងថាវាពាក់ព័ន្ធនោះ គឺត្រង់ ERN00079815, គឺលើកឡើងចំណុចដូចគ្នា៖ “យើងព្យាយាមយ៉ាងលឿន ដើម្បីលើកកម្ពស់លក្ខខណ្ឌរស់នៅនិងសុខភាពរបស់ប្រជាជន ដោយសារតែយើងត្រូវការប្រជាជនពី ១៥ ទៅ ២០លាននាក់ក្នុងរយៈពេល១០ឆ្នាំខាងមុខ”។ បញ្ចប់ការដកស្រង់។

ឯកសារទាំងអស់នេះគឺមិនមានតម្លៃភស្តុតាងនោះទេ។ ឯកសារទាំងអស់នេះគឺមិនពាក់ព័ន្ធទាំងអស់នោះឡើយ គឺវាគ្រាន់តែបង្ហាញអំពីអត្ថិភាពនៃគោលយោបាយ នៃគោលដៅនយោបាយរួមមួយតែប៉ុណ្ណោះ។ វាគ្មានហេតុផលជាក់ស្តែងណាមួយបង្ហាញអំពីគោលបំណងនៃការបង្ខំឲ្យប្រជាជនរៀបការជាមួយគ្នានោះឡើយ។ ឯកសារនេះ គឺបានបង្ហាញចំណុចមួយដែលផ្សេងពីនេះ ហើយលើកឡើងអំពីវិធីសាស្ត្រក្នុងការសម្រេចបានគោលដៅនេះ។ ឯកសារនេះ គឺបានបង្ហាញដោយសហព្រះរាជអាជ្ញា ហេតុដូច្នេះហើយ ដោយមូលហេតុនេះហើយ គួរតែច្រានចោលទាំងអស់ឯកសារនេះ។

[១៤:៣០:៤១]

បន្ទាប់មក សហព្រះរាជអាជ្ញាបានបន្តបង្ហាញឯកសារដែលរៀបរាប់លម្អិតអំពីទស្សនទានបក្សកុម្មុយនីស្តកម្ពុជាស្តីអំពីការរៀបការ និងគ្រួសារ។ សហព្រះរាជអាជ្ញាលើកឡើងថា -- ក្នុងពេលដែលគាត់បង្ហាញឯកសារនោះគាត់លើកឡើងថា របបនោះជឿជាក់ថាទស្សនទានតាមទំនៀមទម្លាប់លើបញ្ហាគ្រួសារនោះ គឺលើកឡើងដោយគ្រូ តាមរយៈគ្រួសារបដិវត្តន៍ ហើយការថែទាំចំពោះសមាជិកគ្រួសារនីមួយៗលើសពីចលនាសង្គមនោះ គឺជាការលើកឡើងមួយមិនត្រឹមត្រូវ។ បានន័យថា សហព្រះរាជអាជ្ញាព្យាយាមច្របល់ទឹកនិងស្រាចូលគ្នា បានន័យថាពួកគេគាត់បានលើកឡើងពីទ្រឹស្តីនយោបាយមួយដែលមិនមានលក្ខណៈច្បាស់លាស់ ហើយបង្វិលវាទៅគោលនយោបាយជាក់លាក់បង្ហាញអំពីការបង្ខំប្រជាជនឲ្យរៀបការ។

[១៤:៣១:៤៤]

ឯកសារទង់បដិវត្ត ឯកសារទស្សនាវដ្តីទង់បដិវត្តមួយពីខែតុលា ឆ្នាំ១៩៧៦ គឺបានបង្ហាញជាឧទាហរណ៍មួយដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង។ ឯកសារលេខ E3/10, ERN គឺមានលេខ 00450539។ ខ្ញុំសូមអធ្យាស្រ័យអង្គជំនុំជម្រះ ដោយសារតែយើងខ្ញុំលើកឡើងតែ ERN ជាភាសាអង់គ្លេស ហើយចំពោះ ERN ផ្សេងទៀត ខ្ញុំនឹងបង្ហាញនាពេលក្រោយ។ ឯកសារនេះ គឺឯកសារ E3/10 ហើយឯកសារនេះបានលើកឡើងដូចតទៅ ខ្ញុំសូមដកស្រង់៖ “ទ្រព្យសម្បត្តិឯកជន និងទ្រព្យសម្បត្តិរបស់របបផ្សេងទៀត កម្មសិទ្ធិឯកជននៅក្នុងអង្គការដោយបុគ្គលម្នាក់ ឬដោយគ្រួសារមួយ ដោយបនឬក្រុមមួយ ហើយបើទោះជាមានមនោគមន៍វិជ្ជា ឬមាគ៌ាបក្សក៏ដោយ គឺជាការអនុវត្តខុស។ ឧទាហរណ៍អ្នកដែលគិតអំពីគ្រួសារ ផលប្រយោជន៍គ្រួសារ គឺជាអ្នកបោកបញ្ឆោតទៅលើបដិវត្តន៍ ហើយអ្នកទាំងអស់នេះ គឺមិនមែនជាអ្នកស្វែងរកសេចក្តីរួមរស់នៅក្នុងបក្សឡើយ”។

ឯកសារមួយទៀត គឺឯកសារ E3/750 ទស្សនាវដ្តីយុវជនបដិវត្តន៍ ខែវិច្ឆិកា ឆ្នាំ៧៥, ERN 00522461, អត្ថបទនេះលើកឡើងដូចតទៅ ខ្ញុំសូមដកស្រង់៖ “នៅក្នុងជួរបដិវត្តន៍របស់យើង យុទ្ធជនយុទ្ធនារីបដិវត្តន៍របស់យើង និងកម្មាភិបាលបានលះបង់កម្មសិទ្ធិឯកជន ដូចជាផ្ទះសម្បែង ដីស្រែចម្ការគ្រួសារ ឪពុកម្តាយ សាច់ញាតិ កូនចៅ និងទ្រព្យសម្បត្តិដទៃទៀត ដើម្បីបម្រើបក្សបដិវត្តន៍ និងប្រជាជន”។ ដោយយើងបានឃើញពិសេសហើយ គឺថាមិនមានការបង្ហាញច្បាស់លាស់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំទេនៅក្នុងឯកសារនេះ។ ដូច្នេះយើងសូមស្នើតុលាការបញ្ជាក់ថាឯកសារនោះមិនពាក់ព័ន្ធហើយនិងគ្មានតម្លៃជាភស្តុតាងទេ។

[១៤:៣៤:១៤]

ឯកសារមួយទៀត ដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ គឺយុវជនបដិវត្តន៍។ គឺឯកសារ E3/766 ហើយខ្ញុំនឹងដកស្រង់ចេញពី ERN 00524181។ ទស្សនាវដ្តីនេះគឺបាននិយាយអំពី គឺជាអំពីការប្រៀបធៀបក្មេងអាយុ ១៥ឆ្នាំ។ សូមដកស្រង់៖ “ខ្ញុំមិនមានឪពុកម្តាយ បងប្អូនបង្កើត ខ្ញុំជាកុមារនៃបក្សកុម្មុយនីស្តកម្ពុជា។ ឪពុកម្តាយរបស់ខ្ញុំ ហើយនិងបងប្អូនរបស់ខ្ញុំ ត្រូវបានសម្លាប់ ហើយកម្ទេចដោយខ្មាំងយួននៅក្នុងការឈ្លានពានឆ្នាំ១៩៧៦។ អ្នកភូមិរបស់ខ្ញុំ ផ្ទះរបស់ខ្ញុំ ស្រូវអង្ករ ត្រូវបានលួចប្លន់ដោយខ្មាំងយួន ហើយយកវិលត្រឡប់ទៅស្រុកគេវិញ។ ឥឡូវនេះ ខ្ញុំរស់នៅក្នុងគ្រួសារថ្មី។ ក្រុមគ្រួសាររបស់ខ្ញុំគ្មានអ្នកណាម្នាក់ក្រៅពីបក្សកុម្មុយនីស្តកម្ពុជា ដូច្នេះខ្ញុំត្រូវតែព្យាយាមស្រឡាញ់អង្គការអស់ពី

ដួងចិត្ត"។ សូមបញ្ចប់សេចក្ដីដកស្រង់។

ជាបឋម លោកប្រធាន លោក លោកស្រីចៅក្រម ឯកសារនេះគឺមិនមានអ្វីក្រៅអំពី -- មិនមាននិយាយពីការរៀបអាពិហ៍អាពាហ៍ដោយបង្ខំទេ តាមពិតគឺមិននិយាយអំពីការរៀបការទៅទៀត។ ដូច្នេះ សូមអង្គជំនុំជម្រះបដិសេធចោលឯកសារ ដោយសារមូលហេតុនេះឯង។ ប៉ុន្តែយើងសូមបន្ថែមថាទោះបីជាមានសារដែលសហព្រះរាជអាជ្ញាចង់បង្ហាញថាមានការបកស្រាយដ៏តិចតួចអំពីឯកសារនេះក៏ដោយ។ យើងយល់ឃើញថា សហព្រះរាជអាជ្ញាគិតថាឯកសារនេះបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានលើកទឹកចិត្តឱ្យមនុស្សគិតអំពីបក្សជាជាងក្រុមគ្រួសាររបស់ខ្លួន។

[១៤:៣៦:១៤]

ហើយយើងខ្ញុំសូមជម្រាបថា នេះគឺជាការយោងដ៏សមស្របក្នុងការបង្កើតរឿងរ៉ាវនេះ ដែលថាបក្សកុម្មុយនីស្តកម្ពុជាប្រាប់ប្រជាជនរបស់ខ្លួនថា ខ្លួននឹងការពារពួកគេនៅក្នុងពេលដែលកាន់កាប់អំណាច។ ដូច្នេះទាក់ទងនឹងឃោសនា ទាក់ទងទៅនឹងការលុបបំបាត់គ្រួសារឯណោះវិញ ដែលអាចនឹងធ្វើ បង្ហាញថាកុមារនោះមិនមានឪពុកម្ដាយ។ គាត់មិនចង់នៅក្នុងក្រុមគ្រួសារ គាត់ចង់នៅជាមួយអង្គការ។ នេះហើយគឺនិយាយអំពីកុមារម្នាក់នេះ ឪពុកម្ដាយរបស់ខ្លួនត្រូវសម្លាប់ដោយខ្មាំងវៀតណាមដែលគេនិយាយថា ជាខ្មាំង សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា។ យើងខ្ញុំជម្រាបថា ប្រសិនបើបក្សព្យាយាមលុបបំបាត់ក្រុមគ្រួសារនោះ គឺជារឿងល្អ នេះគឺជារឿងចុងក្រោយដែលថាគេមានតែរឿងកុមារម្នាក់ដែលប្រាប់ថា គ្រួសាររបស់ខ្លួនត្រូវបានបំផ្លាញដោយវៀតណាម។

លោកប្រធាន ខ្ញុំមើលម៉ោងថាអាចនឹងដល់ម៉ោងសម្រាក។ ដូច្នេះ ខ្ញុំត្រូវបន្តទៅទៀតបន្ទាប់ពីសម្រាកក៏បាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកប្រធាន។ បាទ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ស្ទើរតែពេញ១ថ្ងៃហើយ យើងខ្ញុំជិតបញ្ចប់បទបង្ហាញរបស់ខ្ញុំហើយ ហើយខ្ញុំនេះទំនងប្រហែលជានិយាយតែ៣៥ ទៅ៤០នាទីតែប៉ុណ្ណោះ។ ហើយដូចដែលយើងខ្ញុំបានកត់សម្គាល់អីចឹង ខ្ញុំសូមលើកឡើងថា កាលពីម្សិលមិញគឺជាថ្ងៃពិសេសមួយ គឺថាម្សិលមិញគឺជាថ្ងៃកំណើតរបស់កូនក្តីរបស់ខ្ញុំនៅឆ្នាំនេះគាត់មានអាយុចូល៨៧ឆ្នាំ។ ខ្ញុំសូមអបអរសាទរចំពោះគាត់ ហើយសង្ឃឹមថាគាត់នឹងអាយុវែងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

លោកប្រធានគ្រាន់តែកំណត់សម្គាល់ដោយខ្លីទេ។ នៅពេលនេះ ខ្ញុំសូមចូលទៅដល់ចំណុចចុងក្រោយរបស់យើងខ្ញុំពាក់ព័ន្ធទៅនឹងឯកសារដែលយើងខ្ញុំបានដាក់បង្ហាញ -- ដែលសហព្រះរាជអាជ្ញាដាក់បង្ហាញពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ។

[១៥:០៤:០០]

នៅពេលនេះខ្ញុំសូមចាប់ផ្តើមដោយលើកឡើងអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងថាជាឯកសារសំខាន់បំផុតនាសម័យនោះពាក់ព័ន្ធទៅនឹងទស្សនទានរបស់បក្សកុម្មុនីស្តកម្ពុជា អំពីគ្រួសារ និងការរៀបចំការរៀបការ។ ឯកសារបោះពុម្ពផ្សាយរបស់បក្សចុះខែ -- ចុះថ្ងៃចាប់ពីខែកុម្ភៈ ឆ្នាំ៧៤ មានចំណងជើងថា "លោកទស្សនៈបដិវត្តន៍ និងមិនបដិវត្តន៍ពាក់ព័ន្ធទៅនឹងការបញ្ជាកសាងគ្រួសារ"។ ឯកសារនេះគឺឯកសារមានលេខ E3/775។

ជាថ្មីម្តងទៀត លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! គ្មានអ្វីនៅក្នុងឯកសារនេះបានលើកឡើងបង្ហាញអំពីការរៀបការដោយបង្ខំ ហើយគោលនយោបាយលម្អិតដែលលើកឡើងក្នុងនោះមិនមានលក្ខណៈឧក្រិដ្ឋឡើយ។ ERN ត្រង់លេខ 00417944 ឯកសារបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "ត្រឡប់នៅក្នុងសង្គមចាស់មុនរំដោះ យុវជនជាច្រើនបានក្តោបក្រសោបលោកទស្សនៈនៃវណ្ណៈជិះជាន់។ ពួកគេស្វែងរកប្រពន្ធដើម្បីកសាងគ្រួសារ ហើយនិងស្វែងរកការលោភលន់ផ្នែកសម្ភារៈផ្ទាល់

ខ្លួន។ បានន័យថាពួកគេបានព្យាយាមរកផលប្រយោជន៍គ្រួសារ ឬក៏សុភមង្គលគ្រួសារដោយធ្វើការបំបែកផលប្រយោជន៍ និងជោគវាសនារបស់ជាតិ និងប្រជាជនទាំងមូល។ ប៉ុន្តែបញ្ហាគ្រួសារនេះបានបន្ត ហើយមិនអាចបែងចែកគ្នារវាងជាតិ និងប្រជាជនឡើយ ប្រសិនបើជាតិត្រូវបានជ្រៀតជ្រែក ហើយប្រជាជនក្លាយទៅជាទាសករ គ្រួសាររបស់យើងក៏ក្លាយជាទាសករផងដែរ”។

[១៥:០៥:៥២]

ឯកសារបន្តត្រង់លេខ ERN 00417943, ខ្ញុំសូមដកស្រង់៖ “នៅក្នុងយុគសម័យថ្មីនេះ កុំតក់ក្រហល់ កុំក្តៅតាមចិត្ត យើងមិនមែនជ្រើសរើសអ្នកណាម្នាក់ដែលស្អាត ហើយនិងដឹងតែពីស្លៀកពាក់តែងខ្លួនលេងនោះទេ ហើយនិងតែងខ្លួនតាមរបៀបចក្រពត្តិទំនើបនោះទេ ឬក៏ជាកូនអ្នកមានស្តុកស្តម្ភនោះឡើយ ឬក៏អ្នកដែលមានលទ្ធភាពវប្បធម៌ក្នុងសង្គមចាស់ខ្ពស់ ឬអ្នកដែលមានសមត្ថភាពពូកែនិយាយ ឬក៏អ្នកដែលជាកម្មាភិបាលសម្លែងតែកាំភ្លើងនោះឡើយ។ អ្នកទាំងអស់នោះត្រូវតែមានសីលធម៌រស់នៅស្អាតស្អំ មាននយោបាយស្អាតស្អំ ដោយមិនពាក់ព័ន្ធជាមួយខ្សែខ្មាំង ឬក៏ធាតុមិនល្អ”។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

ចំណុចដំបូងដែលយើងទទួលស្គាល់អំពីចម្លើយនេះ គឺថាចម្លើយនេះមិនមាននិយាយអំពីការរៀប-ការដោយបង្ខំនោះទេ។ ចំណុចទី២ ការលើកឡើងនៅក្នុងនេះគឺគ្រាន់តែបង្ហាញអំពីជម្រើសតែប៉ុណ្ណោះ។ ហេតុអ្វីបានជាបក្សលើកទឹកចិត្តមនុស្សកុំឱ្យតក់ក្រហល់ ក្តៅតាមចិត្ត ឬក៏ជ្រើសរើសអ្នកដែលមានរូបរាងស្អាត ប្រសិនបើសេចក្តីសម្រេចទាំងអស់នោះបានសម្រេចជាមុនដោយបក្សរួចទៅហើយនោះ។

[១៥:០៧:៣២]

ជាការពិតចំណាងជើងនៅក្នុងការពិភាក្សាក្នុងឯកសារនេះខ្លួនឯង ខ្ញុំសូមដកស្រង់ “គឺគេសរសេរថាតើយើងយុវជនបដិវត្តន៍ជ្រើសរើសប្រពន្ធដោយរបៀបណា?” ដើម្បីឱ្យប្រាកដឯកសារ E3/775 បង្កប់ន័យថា បក្សចាប់អារម្មណ៍ទៅលើអ្នកណារៀបការជាមួយអ្នកណា។

លោក លោកស្រីចៅក្រមជាទីគោរព! ឪពុកម្តាយខ្ញុំនោះក៏គាត់គិតអ៊ីចឹងដែរ គឺថាតើខ្ញុំគួរតែរៀបការជាមួយនរណា? ប៉ុន្តែមិនមែនមានន័យថា ខ្ញុំរៀបការដោយការរៀបចំដោយគាត់នោះឡើយ។ នៅក្នុងឯកសារដដែលនេះ សហព្រះរាជអាជ្ញាលើកឡើងត្រង់ចំណុច ERN 00417943។ ខ្ញុំសូមដកស្រង់៖ “នៅពេលរៀបការវាចាំបាច់ធ្វើសំណើដោយស្មោះត្រង់ទៅអង្គការ ទៅសហករណ៍ ទៅសមូហ-ភាព ដើម្បីឱ្យគាត់ដោះស្រាយ។ បញ្ហាកសាងគ្រួសារមិនថាលទ្ធផលសេចក្តីសម្រេច ការវិភាគយ៉ាង

ម៉ែចរបស់អង្គការ ឬសមូហភាពនោះទេ សេចក្តីសម្រេច ឬការវាយតម្លៃទាំងអស់នោះ ត្រូវតែគោរពតាមជាដាច់ខាត”។

[១៥:០៨:៤២]

ជាថ្មីម្តងទៀតឯកសារដែលខ្ញុំដកស្រង់នេះ ចេញពីឯកសារលេខ E3/775។ អត្ថបទនេះដដែលមិនមានលើកឡើងអំពីការរៀបការដោយបង្ខំនោះទេ គឺគ្រាន់តែណែនាំឲ្យប្រជាជនធ្វើសំណើទៅអង្គការតែប៉ុណ្ណោះ តើសំណើទាំងអស់នេះ -- តើសំណើទាំងអស់នោះអំពីរៀបការជាមួយនរណា? តើសំណើទាំងអស់នោះអំពីរៀបការនៅពេលណា? ឬសំណើទាំងអស់នោះអំពីពិធីរៀបការ?

អ្នកទាំងអស់នោះគឺថា អាចជំទាស់ទៅនឹងការរៀបការដោយបង្ខំ។ យើងមិនអាចត្រូវគេបង្ខំឲ្យធ្វើការស្នើសុំនោះទេ ការបកស្រាយមួយអំពីឯកសារនេះ គឺវាមិនមែនជាការគ្រប់គ្រងទៅលើប្រជាជនថាមិនអាចរៀបការបាននោះទេ ក៏ប៉ុន្តែ -- ហើយយើងមិនឯកភាពថា ឯកសារនេះវាមានន័យដូច្នោះឡើយ។ ប៉ុន្តែគោលនយោបាយនៃការផ្គូរផ្គងគូស្រករ និងការបញ្ជានោះ គឺជាអំពើហិង្សា ឬដោយបង្ខំរៀបការឬយ៉ាងម៉េច?

[១៥:០៩:៥៥]

ឯកសារផ្សេងទៀតបានបង្ហាញអំពីគោលបំណងទូទៅរបស់សហគមន៍នៅក្នុងការងារផ្សេងៗ។ ឯកសារ E3/773 ជាកិច្ចសម្ភាសន៍ជាមួយ នួន ជា, ត្រង់ ERN 00711651, និយាយអំពីគោលបំណងក្នុងការបង្កើតសង្គមដោយមិនមានការផឹកស៊ី លេងល្បែង ឬក៏សម្ភារនិយម។

ឯកសារ E3/169 យុវជនទង់បដិវត្តន៍ដែលលើកឡើងដោយ ដកស្រង់ដោយសហព្រះរាជអាជ្ញាត្រង់ ERN 00815131។ ខ្ញុំសូមដកស្រង់៖ “យើងបានមកដល់យុគសម័យថ្មី ដែលយើងមានភាពស្មើគ្នាទាំងអស់គ្នា”។ ហើយខ្ញុំសូមដកស្រង់៖ “នៅពេលនេះគ្មាននរណាម្នាក់អាចកេងប្រវ័ញ្ចលើអ្នកដទៃនោះទេ”។

ឯកសារ E3/770 ឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធទៅនឹងការកសាងគ្រួសារ ត្រង់ ERN 00417945, បានធ្វើការរំឭកទៅដល់កម្មាភិបាល “មិនត្រូវទុកប្រពន្ធឲ្យធ្វើការ ឲ្យចម្អិនអាហារ មើលថែទាំកូន ឬក៏មើលថែទាំផ្ទះនោះទេ។ កុំគិតថាប្រពន្ធប្តីរបស់អ្នក គឺជាអ្នកដែលអាចអប់រំអ្នកបាន”។ ឯកសារទាំងអស់នេះគឺមិនពាក់ព័ន្ធទាំងអស់តែម្តងបើសិនយើងមើលទៅលើឯកសារនេះ។

[១៥:១១:៣៥]

ឯកសារចុងក្រោយរបស់សហព្រះរាជអាជ្ញាដែលចោទប្រកាន់អំពីការរៀបការដោយបង្ខំនោះ គឺគាត់បង្ហាញអំពីកិច្ចសម្ភាសន៍ជាមួយ អៀង សារី នៅក្នុងខែធ្នូ ឆ្នាំ៨០, ឯកសារលេខ E3/681។ នៅក្នុងកិច្ចសម្ភាសន៍នោះ អៀង សារី បានដកស្រង់ត្រង់ ERN 00122194 ដោយគាត់បានលើកឡើងថាចាប់ពីពេលនេះទៅ -- ខ្ញុំសូមដកស្រង់៖ “ការរៀបអាពាហ៍ពិពាហ៍គឺមានសេរីភាពហើយគ្រួសារអាចរស់នៅជាមួយគ្នាបាន” បញ្ចប់ការដកស្រង់។ សហព្រះរាជអាជ្ញាឃើញនៅក្នុងការទទួលស្គាល់នេះថាការរៀបការដោយបង្ខំកាលពីលើកមុនគឺជាបទដ្ឋានទំនៀមទម្លាប់ ក៏ប៉ុន្តែទោះបីជាការសន្និដ្ឋានអាចធ្វើឡើងដោយផ្អែកទៅលើការសម្ភាសនេះ អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅចន្លោះឆ្នាំ៧៥-៧៩ ក៏ដោយក៏វាគ្មានការបញ្ជាក់ណាមួយអំពីករណីដែលថាការរៀបការដោយបង្ខំនោះត្រូវបានគេអនុវត្តនោះឡើយនៅមុនពេលនោះ។

[១៥:១២:៤១]

ជាការពិត ឯកសារនេះមិនបានបង្កប់ន័យថា បក្សជាសម្រេចថាឲ្យត្រូវរៀបការជាមួយអ្នកណាហើយបង្ខំអ្នកទាំងអស់នោះឲ្យគោរពតាមនោះទេ។

ឯកសារចុងក្រោយ គឺបង្ហាញដោយដើមបណ្ដឹងរដ្ឋប្បវេណី គឺបង្ហាញអំពីស្ត្រីដែលត្រូវបានបង្ខំដោយបក្សរៀបការជាមួយនឹងបុរសដែលពួកគាត់មិនមែនជាអ្នកជ្រើសរើស។ នៅពេលដែលយើងនិយាយអំពីឯកសារនេះ គឺឯកសារនេះនិយាយអំពីការអនុវត្តនៃ គោលនយោបាយចោទប្រកាន់ហើយវានៅក្រៅវិសាលភាពនៃការជំនុំជម្រះ។ ដូចដែលយើងបានលើកទឡ្ហីករណ៍ពាក់ព័ន្ធទៅនឹងសហករណ៍ដូចគ្នានោះដែរ គ្មានការពិចារណាលក្ខណៈប្រព័ន្ធណាមួយអំពីភស្តុតាងនេះ ជាពិសេសចំពោះសក្ខីកម្មដែលសាក្សីមកផ្ដល់នូវចំពោះមុខអង្គជំនុំជម្រះ។ អាស្រ័យហេតុនេះគ្មានភស្តុតាងណាមួយដែលបង្ហាញថាការជ្រើសរើសនូវឯកសារទាំងអស់នេះគឺជាតំណាងនៃការអនុវត្តនៅក្នុងប្រទេសកម្ពុជាជារួមនោះទេ។ គ្មានភស្តុតាងណាមួយបង្ហាញថា នួន ជា ឬគណៈអចិន្ត្រៃយ៍ឲ្យបានដឹងថា ពិធីរៀបការទាំងអស់នេះបានកើតឡើងនោះទេ។ ឯកសារទាំងអស់នេះត្រូវតែច្រានចោលដោយអង្គជំនុំជម្រះ ដោយមិនគិតថាតើវាពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយឬក៏មិន ពាក់ព័ន្ធនោះឡើយ។

[១៥:១៣:៥៦]

លោកប្រធាន នៅពេលនេះខ្ញុំសូមឆ្លើយ ចូលទៅដល់ការឆ្លើយតបពាក់ព័ន្ធទៅនឹងការបង្ហាញ

ឯកសារពាក់ព័ន្ធទៅសហករណ៍ និងការដ្ឋានការងារ។ យើងខ្ញុំនឹងបង្ហាញដោយខ្លីសង្ខេបទេ អំពីការបង្ហាញ ការឆ្លើយតបទៅនឹងការបង្ហាញឯកសារគន្លឹះផ្នែកនេះ។

ជាកិច្ចចាប់ផ្ដើម យើងខ្ញុំសូមធ្វើការបង្ហាញការសង្កេតនៃវិសាលភាពនៃការជំនុំជម្រះក្នុងដំណាក់កាលនេះជាមុនសិន។ យើងខ្ញុំមិនចង់លើកឡើងសាជាថ្មីនោះទេ ក៏ប៉ុន្តែចំណុចនេះវាមានសារសំខាន់ត្រូវលើកឡើងដដែល។ បញ្ហាពាក់ព័ន្ធទៅនឹងសហករណ៍ ថាតើវាជាគោលនយោបាយឧក្រិដ្ឋក្នុងការបង្កើតសហករណ៍ ឬក៏ការដ្ឋានការងារដែរឬទេ? អង្គជំនុំជម្រះគឺត្រូវតែកម្រិតខ្លួនឯង ពិនិត្យទៅលើ ភស្តុតាងអំពីចេតនារបស់បុគ្គលនៅថ្នាក់កំពូលនៃមជ្ឈិមបក្ស ដែលត្រូវបានគេចោទប្រកាន់ថាជាអ្នកបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។

ឯកសារទាំងអស់នោះ គឺជាកំណត់ហេតុកិច្ចប្រជុំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ និងឯកសារបោះពុម្ពផ្សាយចេញដោយផ្ទាល់ពីមជ្ឈិមបក្ស។ ភស្តុតាងដទៃទៀតត្រូវតែដកចេញ។ ឯកសារទាំងអស់នោះដែលត្រូវដកចេញ រួមទាំងភស្តុតាងបង្ហាញអំពី ថាតើសហករណ៍ ឬក៏ការដ្ឋានការងារនោះដំណើរការជាក់ស្ដែងយ៉ាងណា និងខ្លឹមសារនៃទំនាក់ទំនងការធ្វើរបាយការណ៍ពីរ និងមកពីថ្នាក់ខ្ពស់ៗ។ ដូចដែលអង្គជំនុំជម្រះបានជ្រាបរួចមកហើយ ជំហររបស់មេធាវីការពារក្ដី នួន ជា គឺតាំងពីមុនមកគឺថាលក្ខខណ្ឌស្ថានភាពនោះវាមានភាពខុសៗគ្នានៅតាមភូមិភាគ ស្រុក សូម្បីនៅតាមសហករណ៍ជិតៗនោះក៏ដោយភស្តុតាងបានបង្ហាញគាំទ្រជំហររបស់យើងដូច្នេះ។

[១៥:១៦:០០]

ហ្វ្រង់ស្វ័រ ប៉ុងស្វ៉ដែលស្នាដៃឯកសាររបស់គាត់នេះ បានបង្ហាញកំណត់អំពីរបបកម្ពុជាប្រជាធិបតេយ្យ គឺគាត់លើកឡើងថា ស្ថានភាពនោះ គឺវាមិនដូចគ្នានៅគ្រប់ទីកន្លែងនៅក្នុងប្រទេសនោះឡើយ។ គាត់ក៏បានពន្យល់ថាព័ត៌មានដែលគាត់បាន ទទួលបាននេះ គឺពីការសម្ភាសជាមួយនឹងអ្នកជនភៀសខ្លួននៅតាមព្រំដែនថៃ ហើយអ្នកទាំងអស់នោះ ភាគច្រើនមកពីភូមិភាគពាយ័ព្យ។ ភស្តុតាងដទៃទៀត បានបង្ហាញថា លក្ខខណ្ឌនៅភូមិភាគពាយ័ព្យអាចមានលក្ខណៈលំបាកជាងភូមិភាគដទៃនៅក្នុងប្រទេស។ ដោយសារហេតុផលនេះហើយ ភស្តុតាងនៃការអនុវត្តវាមិនសមស្រប ហើយវាធ្វើឲ្យប៉ះពាល់ដល់កូនក្ដីរបស់ខ្ញុំ។ ដូចដែលអង្គជំនុំជម្រះមានបំណងធ្វើការសម្រេចអំពីគោលនយោបាយឧក្រិដ្ឋក្នុងការបង្កើតសហករណ៍ និងការដ្ឋានការងារក៏ដោយ អង្គជំនុំជម្រះត្រូវតែធ្វើការសម្រេចដោយផ្អែកទៅលើភស្តុតាងដោយផ្ទាល់ បង្ហាញអំពីចេតនារបស់មជ្ឈិមបក្ស។

[១៥:១៧:០៧]

អង្គជំនុំជម្រះត្រូវរកឲ្យឃើញដោយផ្អែកទៅលើភស្តុតាងថា នួន ជា និងមេដឹកនាំដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា អនុវត្តគោលនយោបាយមួយដើម្បីបង្កើតសហករណ៍ និងការដ្ឋានការងារក្នុងគោលបំណងឧក្រិដ្ឋ។ អាស្រ័យហេតុនេះ យោបល់ដំបូងដែលយើងខ្ញុំសូមបង្ហាញទៅលើឯកសារបង្ហាញដោយសហព្រះរាជអាជ្ញា គឺដូចមុន។ គ្មានឯកសារណាមួយមានភស្តុតាងដោយផ្ទាល់បង្ហាញអំពីចេតនាឧក្រិដ្ឋ សូម្បីតែប្រភេទណាក៏ដោយ។ ការបង្កើតសហករណ៍ និងការដ្ឋានការងារ គឺមិនមែនវាជាការងារខុសច្បាប់នោះទេ។ សមូហភាពមិនមែនខុសច្បាប់នោះទេ។

សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការទាញសន្និដ្ឋានឧក្រិដ្ឋ -- ភាពឧក្រិដ្ឋពីរចំណុចនេះ ដោយមិនពិចារណាអំពីផលប៉ះពាល់ទៅលើប្រជាជន រួមទាំងដីដែលមិនអាចផ្គត់ផ្គង់ទៅលើការងារដែលកំពុងធ្វើ។ ផ្ទុយទៅវិញមកវិញ ឯកសារដែលបង្ហាញដោយសហព្រះរាជអាជ្ញា បានបង្ហាញថាគោលបំណងចម្បងនៃសហករណ៍គឺដើម្បីចិញ្ចឹមប្រជាជន លើកកម្ពស់សុខមាលភាពរបស់ពួកគេ និងផ្តល់ប្រទេសនេះឡើងវិញនូវអ្វីដែលបាត់បង់ក្នុងពេលសង្គ្រាម និងគ្រោះទុរ្ភិក្ស។ ឧទាហរណ៍សហព្រះរាជអាជ្ញា បានបង្ហាញឯកសារ E3/11 ដែលជាឯកសារទស្សនាវដ្តីទង់បដិវត្ត ពីខែកញ្ញា -- ចុះខែកញ្ញា ឆ្នាំ៧៧ ERN ជាភាសាអង់គ្លេសគឺ 00486256។ ឯកសារនេះបានលើកឡើងថា សហករណ៍ -- ខ្ញុំសូមដកស្រង់៖

[១៥:១៨:៥៤]

"បានផ្លាស់ប្តូរដីជនបទរបស់យើងដែលមិនល្អ គ្មានជីជាតិ គ្មានទឹកឲ្យទៅជាទីជនបទមួយដែលមានភោគផលផ្តល់នូវកន្លែងស្តុកទឹកដែលមានទំហំគ្រប់ទំហំ និងបណ្តាញប្រឡាយសម្រាប់ដីស្រែ និងចម្ការរបស់យើង"។

ឯកសារបក្សកុម្មុយនីស្តកម្ពុជាបីទៀតដែលបង្ហាញដោយសហព្រះរាជអាជ្ញា ឯកសារ E3/773 វាជាឯកសារយុវជនទង់បដិវត្ត ខែឧសភា ឆ្នាំ៧៦ ឯកសារ E3/5, ឯកសារយុវជនទង់បដិវត្តខែសីហា ឆ្នាំ៧៥ ឯកសារ E3/729, យុវជនទង់បដិវត្ត ខែតុលា ឆ្នាំ៧៥។ ឯកសារនេះបង្ហាញដូចគ្នា។ ឯកសារបង្ហាញថា "សហករណ៍ និងការដ្ឋានត្រូវបានបង្កើតឡើង ដើម្បីបង្កើនផលិតកម្មស្រូវ ហើយផលិផលដទៃទៀត ដើម្បីផ្គត់ផ្គង់ប្រជាជននៅក្នុងសហករណ៍របស់យើង ដើម្បីឲ្យពួកគេមានអាហារគ្រប់គ្រាន់ហូប"។

ចំណុចដែលខ្ញុំលើកឡើងចុងក្រោយអម្បាញ់មិញនេះ គឺដកស្រង់ចេញពីឯកសារដែលមានលេខ E3/733 ត្រង់ ERN 00357874។ ឯកសារបានកំណត់ហេតុបីច្បាប់ពីគណៈអចិន្ត្រៃយ៍: ឯកសារ E3/182, E3/229 និង E3/235។ កំណត់ហេតុទាំងអស់នេះ តាមទ្រឹស្តីគឺផ្តល់ជាភស្តុតាងជាក់ស្តែងដែលបង្ហាញថា គោលនយោបាយឧក្រិដ្ឋត្រូវបានអនុវត្តពីថ្នាក់លើ។ ប៉ុន្តែឯកសារនេះនិយាយឲ្យពិតប្រាកដទៅ លើកឡើងអំពីអ្វីខ្លះ? ឯកសារនេះបានលើកឡើងថា “បក្សគួរតែពិនិត្យមើលកំពង់ផ្ទាំងដែលជាអាចទីតាំងសម្រាប់ធ្វើព្រលានយន្តហោះ”។ ចំណុចនេះលើកឡើងនៅក្នុងឯកសារទាំងបី ហើយផលិតកម្មស្រូវនៅក្នុងប្រទេសនោះ គឺជាគោលដៅសំខាន់ដែលត្រូវលើកម្ពស់។

[១៥:២០:៥៨]

ចំណុចនេះ គឺស្ថិតមានលើកឡើងនៅក្នុងឯកសារ E3/213 និងឯកសារ E3/230។ ហើយអ្វីដែលគួរភ្ញាក់ផ្អើលនោះ គឺមានការលើកឡើងអំពីការខិតខំធ្វើយ៉ាងណាផលិតនោះកើនពី៥០.០០០ ទៅ ៦០.០០០តោនក្នុងមួយឆ្នាំ គឺផលិតផលអំបិល។ ចំណុចនេះគឺដកស្រង់ចេញឯកសារ E3/230។

ដីកាដំណោះស្រាយចោទប្រកាន់ថា ពាក់ព័ន្ធទៅនឹងសហករណ៍និងការដ្ឋានការ បក្សមានគោល-ដៅផលិតកម្មមិនច្បាស់លាស់ដែលខ្លួនចង់បាន តាមរយៈមធ្យោបាយចាំបាច់។

សហព្រះរាជអាជ្ញាមិនបានបង្ហាញឯកសារណាមួយដែលបង្ហាញថា មេដឹកនាំបក្សជឿថាផែនការទាំងអស់នេះមិនមានលក្ខណៈសមហេតុផលនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នូវចម្លើយសាក្សីដែលគាំទ្រដល់ការរៀបរាប់អំពីស្ថានភាពលំបាកនៅក្នុងសហករណ៍ និងការដ្ឋានការងារ។

អង្គជំនុំជម្រះបានជម្រាបរួចមកហើយ យើងគិតថាចំណុចនេះមិនអាចទទួលយកបាននោះទេ គ្មានមធ្យោបាយណាមួយដែលយើងដឹងថា តើបណ្តឹង ឬក៏ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះទាំងអស់នោះ គឺសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានជ្រើសរើសដើម្បីបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនោះ វាតំណាងនូវបទពិសោធន៍របស់អ្នកធ្វើការនៅទីនោះក្នុងកម្រិតណានោះទេ។ ហេតុដូច្នេះហើយ គឺឯកសារទាំងអស់នេះមិនអាចទទួលយកបានឡើយ។

ដីកាដំណោះស្រាយចោទប្រកាន់ថា គោលបំណងរបស់សហករណ៍គឺដើម្បីស្វែងតាមដាន ការពារ និងកម្ទេចខ្មាំង។ ដើម្បីគាំទ្រចំណុចនេះ សហព្រះរាជអាជ្ញាបានបង្ហាញឯកសារ E3/748 គឺជាទស្សនា-វដ្តីទង់បដិវត្តចុះខែតុលា ឆ្នាំ៧៥។

[១៥:២៣:០៤]

សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងតុលាការនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ប្រតិចារឹក ត្រង់ទំព័រ៧ បានបង្ហាញថា "ឯកសារនេះបានបង្ហាញអំពីការងារសហករណ៍ ជាពិសេសនៅតាមតំបន់សន្តិសុខ ហើយបានបង្ហាញអំពីការស្វែងរកខ្មាំង"។ បញ្ចប់ការដកស្រង់។

ជាក់ស្តែងឯកសារ E3/748 ពុំបានលើកឡើងអំពីការស្វែងរកខ្មាំងទាល់សោះ។ ប៉ុន្តែមានតែបញ្ជី ត្រង់ ERN ជាភាសាអង់គ្លេស 00495826 តែប៉ុណ្ណោះ ដែលបង្ហាញថាការងារចំនួនប្រាំមួយដែលសហករណ៍បានសម្រេចបានរួមទាំងផលិតកម្ម ពាណិជ្ជកម្ម អប់រំនយោបាយ និង -- ដកស្រង់៖ "ការអនុវត្តការងារនៅក្នុងតំបន់យោធាដើម្បីធានាសន្តិសុខនិងការការពារប្រទេស"។ សូមបញ្ចប់ការដកស្រង់។

យើងមានការឯកសារជាច្រើនទៀត ដែលយើងចង់លើកឡើងអំពីឯកសារប្រភេទនេះ។ ជាដំបូងវាគាំទ្រទៅដល់ការលើកឡើងរបស់ នួន ជា កូនក្តីរបស់យើងខ្ញុំថា គោលបំណងរបស់សហករណ៍ គឺខាងផ្នែកសេដ្ឋកិច្ចតែប៉ុណ្ណោះ។ គឺមានន័យថា គោលបំណងគឺដើម្បីផលិតកម្ម និងពាណិជ្ជកម្ម។ នៅក្នុងសង្គមកសិកម្ម ថាតើសហករណ៍ផលិតអ្វី? និងធ្វើពាណិជ្ជកម្មអ្វី? គឺស្បៀងអាហារ។ ដូច្នេះ ឯកសាររបស់សហព្រះរាជអាជ្ញាបានបង្ហាញថា គោលបំណងចម្បងមួយរបស់ប្រព័ន្ធសហករណ៍ គឺដើម្បីរៀបចំប្រព័ន្ធផលិតកម្ម និងការបែងចែកស្បៀងអាហារ។

[១៥:២៤:៤៨]

ចំណុចទី២ វាគ្មានអ្វីឧក្រិដ្ឋ ឬជំទាស់ក៏បាននោះទេ អំពីការរចនាសម្ព័ន្ធសង្គមមូលដ្ឋាន ស្តីអំពីការការពារសន្តិសុខ និងការការពារ។ នៅក្នុងគ្រប់សង្គមមនុស្សក្នុងប្រវត្តិសាស្ត្រពិភពលោកបានរៀបចំខ្លួនឯងក្នុងវិធីមួយដើម្បីជាប្រយោជន៍ដល់សន្តិសុខខ្លួនឯង។ ហេតុអ្វីបានជាយើងគិតថាបក្សកុម្មុយនីស្តកម្ពុជាធ្វើឡើងផ្ទុយពីគេ?

ទី៣ ការលើកឡើងអំពីពាក្យថា សន្តិសុខគឺវាមិនមានចំណុចណាមួយលើកឡើងថាវាមិនត្រូវនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលថាជាការគោលដៅទៅលើមនុស្សនោះទេ។ ជាការពិតភស្តុតាងបានបង្ហាញថាប្រព័ន្ធសហករណ៍ គឺជាទិដ្ឋភាពសំខាន់មួយរបស់ជោគជ័យយោធាបក្សកុម្មុយ-នីស្តកម្ពុជានៅក្នុងខែមេសា ឆ្នាំ៧៥។ អង្គជំនុំជម្រះបានសម្រេចរួចហើយថា ជម្លោះប្រដាប់អាវុធកើតមាននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេញមួយរបបយុត្តាធិការរបស់តុលាការ។ គ្មានហេតុផលណាមួយដែលសហករណ៍មិនអាចបន្តដើរតួនាទីនៅក្នុងការការពារខ្លួនឯងនោះឡើយ។

[១៥:២៦:០៣]

ចំណុចចុងក្រោយ ប្រសិនបើសហករណ៍គឺធ្វើឡើងដើម្បីប្រឆាំងនឹងប្រព័ន្ធស៊ើបការណ៍ យើងអាចថាហេតុអ្វីបានជាអ៊ីចឹង? ហេតុអ្វីបានជាវាខុសច្បាប់? សហព្រះរាជអាជ្ញាក៏បានបង្ហាញឯកសារ E3/50 ដែលទំនងជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាប្រារព្ធខួបលើកទី៣ នៃអង្គការសហករណ៍កសិករ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ៧៦។ សហព្រះរាជអាជ្ញាបានតវ៉ាថាឯកសារនេះគ្មានលក្ខណៈមូលដ្ឋានសារវន្ត ដោយសារតែវាបានបង្ហាញអំពីតួនាទីរបស់សហករណ៍នៅក្នុងការប្រយុទ្ធប្រឆាំងខ្មាំង និងការគ្រប់គ្រងរបប។ ប៉ុន្តែឯកសារនេះគ្រាន់តែរៀបរាប់អំពីការគាំទ្ររបស់កម្មករ អ្នកធ្វើការនៅក្នុងសហ-ករណ៍ របស់យោធាតែប៉ុណ្ណោះ។ ហើយយើងអាចយល់បាន ជាពិសេសវាសមហេតុផលនៅក្នុងសភាពនៃប្រទេសមួយដែលកំពុងជួបប្រទះនឹងសង្គ្រាមនាពេលនោះ។

ចំណុចចុងក្រោយ -- លោកប្រធានជាទីគោរព! សហព្រះរាជអាជ្ញាបានបង្ហាញឯកសារដើម្បីគ្រាន់តែបង្ហាញថាសហករណ៍ និងការដ្ឋានការងារត្រូវបានបង្កើតឡើងដើម្បីលុបបំបាត់វិស័យឯកជនហើយជំនួសមកវិញនូវរបបសមូហភាពមួយតែប៉ុណ្ណោះ។ ឧទាហរណ៍ឯកសារ E3/729 ឯកសារយុវជនទង់បដិវត្ត ខែតុលា ឆ្នាំ៧៥ រៀបរាប់ -- ត្រង់ ERN ជាភាសាអង់គ្លេស 00357903 -- អំពីរៀបដែលសហករណ៍ ខ្ញុំសូមដកស្រង់៖ “ទទួលខុសត្រូវចំពោះការចាត់ចែងរៀបចំឲ្យមានសុខដុមទៅលើការអប់រំ និងការកសាងប្រជាជនជាង២លាននាក់ដែលទើបតែរំដោះពីការគ្រប់គ្រងរបស់ពួកអាក្បត់។” បញ្ចប់ការដកស្រង់។

[១៥:២៨:១៦]

ឯកសារ E3/11, ឯកសារទស្សនាវដ្តីទង់បដិវត្តន៍ពីខែកញ្ញា ឆ្នាំ៧៧ រៀបរាប់អំពីគោលបំណងក្នុងការបង្កើតសហករណ៍មួយដែលមានរបៀបរៀបរយត្រឹមត្រូវមានសុខដុម និងស្អាតស្អំ និងមានលក្ខណៈសមូហភាព។ ហើយឯកសារ E3/16 សៀវភៅចំណងជើងថា “ប្រវត្តិសាស្ត្រប្រទេសកម្ពុជា” សរសេរដោយ ខៀវ សំផន រៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតសង្គមមួយដែលកម្មករក្រីក្រស្ថិតនៅក្នុងការគ្រប់គ្រងភូមិ និងសហករណ៍របស់ពួកគេ។ លើសពីនេះ ឯកសារលើកឡើងដោយសហព្រះរាជអាជ្ញា រួមទាំងឯកសារ E3/146, E3/273 និង E3/193 បានបង្ហាញថា នៅក្នុងប្រព័ន្ធសហករណ៍ថ្មីនេះ អ្នកដែលមានមិនអាចទាញប្រយោជន៍ពីអ្នកក្របាននោះទេ។

[១៥:២៩:០៩]

សរុបមកវិញ លោកប្រធាន លោក លោកស្រីជាទីគោរព! ខ្ញុំសូមលើកឡើងជាថ្មីនូវអ្វីដែលខ្ញុំ

បានលើកឡើង។ បដិវត្តន៍សង្គមនិយមដើម្បីគោលបំណងអនុវត្តសមូហភាព វាមិនមែនជាឧក្រិដ្ឋកម្មមួយនោះទេ។

លោកប្រធាន! ចំណុចយោបល់ចុងក្រោយខ្លីទេ ដែលខ្ញុំលើកឡើងអំពីគោលនយោបាយនៃការជម្លៀសដោយបង្ខំ។ វាជាយោបល់មួយខ្លីទេ ដែលខ្ញុំសូមលើកឡើង។ ដោយសារតែលោកប្រធានបានជ្រាបហើយ នួន ជា បានទទួលស្គាល់ថា គាត់ចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចជម្លៀសទីក្រុងភ្នំពេញ ហើយពាក់ព័ន្ធទៅនឹងគោលនយោបាយ។ និយាយឲ្យជាក់លាក់ទៅ ខ្ញុំសូមជំទាស់ជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា មិនមែនថាខាងនោះមានការចិត្តចង់ជម្លៀសប្រជាជននោះទេ។ ចំពោះគោលនយោបាយឧក្រិដ្ឋនោះ មិនមែនថាវាជាបញ្ហាមួយដូចគ្នាទេ វាជាបញ្ហាដោយឡែក ហើយដូចដែល នួន ជា បានលើកឡើងអ៊ីចឹង គាត់មិនមែនជំទាស់ថាមិនមានការជម្លៀសទីក្រុងភ្នំពេញនោះទេ។

ខ្ញុំសូមលើកឡើងជាមួយនឹងសហព្រះរាជអាជ្ញាត្រង់ពីរចំណុច។ ខ្ញុំសូមលើកឡើងជូនអង្គជំនុំជម្រះថា តម្លៃនៃភស្តុតាងនៃបទបង្ហាញរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងទៅនឹងការជម្លៀសដោយបង្ខំនោះ គឺគ្មានតម្លៃភស្តុតាងអ្វីទាល់តែសោះ។

[១៥:៣០:៤៦]

សហព្រះរាជអាជ្ញាបានប្រើប្រាស់ឯកសារមួយដើម្បីព្យាយាមបង្ហាញថាមនុស្ស -- ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ គឺជាខ្មាំងគិតមកត្រឹមថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥។ ហើយដើម្បីឲ្យយើងខ្ញុំអាចបញ្ជាក់ចំណុចរបស់យើងខ្ញុំបាន លោក លោកស្រីចៅក្រម អាចយោងទៅលើទឡ្ហីករណ៍របស់ខ្ញុំពាក់ព័ន្ធទៅនឹងបញ្ហាខ្មាំងនេះពីខាងដើម។ ការលើកឡើងរបស់ភាគីសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ហើយវាគឺបង្ហាញអំពីគោលបំណងនយោបាយមួយដែលមិនច្បាស់លាស់។

ទី២ ឯកសាររបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី គឺគាត់មិនបានបង្ហាញថាវាជាផែនការមួយដែលវាមានលក្ខណៈស្របច្បាប់រហូតនោះឡើយ។ យើងដឹងហើយថាការជម្លៀសទីក្រុងភ្នំពេញមានកម្រិតមួយទាបតែប៉ុណ្ណោះ ពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាងដែលយើងបានលើកឡើងពីដំបូងរួចមកហើយនៅក្នុងយោបល់ សេចក្ដីសន្និដ្ឋានរបស់ខ្ញុំពីដំបូង។

[១៥:៣១:៥៦]

ទី៣ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយទាហាន និងកម្មាភិបាលនៅពេលជម្លៀស។

សហព្រះរាជអាជ្ញាមិនបានបង្ហាញឯកសារ បង្ហាញទៅលើចំណុចនេះទេ។ កូនក្ដីរបស់ខ្ញុំ និងមេដឹកនាំដទៃទៀត មិនបានផ្ដល់បញ្ជាឲ្យប្រព្រឹត្តហេតុការណ៍ដូច្នេះនោះឡើយ។

ជាការពិតលោកប្រធាន យើងខ្ញុំសូមបញ្ជាក់ឲ្យបានជាក់លាក់ទៅលើចំណុចទាំងអស់នេះ ក៏ប៉ុន្តែចំណុចជាក់លាក់នោះ គឺថា យើងខ្ញុំនឹងធ្វើការបង្ហាញនៅក្នុងដីកាបញ្ចប់ការពិភាក្សាដេញដោលក្នុងខែតុលា។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ដែលអនុញ្ញាតឲ្យខ្ញុំធ្វើការឆ្លើយតប និងផ្ដល់យោបល់។ នេះដល់ដែលខ្ញុំបញ្ចប់ការបង្ហាញឆ្លើយតបរបស់ខ្ញុំរួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះផ្ដល់វេទិកាជូនទៅមេធាវីជាតិការពារក្ដីលោក នួន ជា។ សូមអញ្ជើញបាទ!

[១៥:៣៣:១៥]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

ដូចសហភាតារបស់ខ្ញុំលោក វ៉ិចទ័រ កូប៉េ បានចង្អុលបង្ហាញយ៉ាងវែងរួចមកហើយ គ្មានបំណងបង្ហាញការឆ្លើយតបរបស់ នួន ជា ចំពោះការចោទប្រកាន់ជាច្រើនពាក់ព័ន្ធនឹងតួនាទីរបស់គាត់ក្នុងកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលអង្គជំនុំជម្រះបានជ្រាប នួន ជា ទទួលស្គាល់ថា គាត់ជាអនុលេខាបក្សកម្ពុជា។ នៅក្នុងបក្សនោះ លោក នួន ជា មានតួនាទីដឹកនាំក្នុងវិស័យអប់រំ តែគាត់បដិសេធដាច់អហង្ការគាតមិនមានតួនាទីណាមួយនៅក្នុងកិច្ចការយោធា ឬសន្តិសុខ ឬជាមេរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅស-២១ នោះទាល់តែសោះ។

តាមពិតគាត់ក៏បានបដិសេធចំពោះការចោទប្រកាន់យ៉ាងពិបាកយល់ដោយសហព្រះរាជអាជ្ញាថាគាត់ជានាយករដ្ឋមន្ត្រីស្ដីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជិតមួយឆ្នាំផងដែរ។ សហព្រះរាជអាជ្ញាបានចំណាយពេលយ៉ាងច្រើននៃបទបង្ហាញរបស់ពួកគេដោយផ្តោតទៅលើចំណុចទាំងឡាយខាងលើនេះ ដោយសារវាជាចំណុចសំខាន់នៃការជំទាស់។ ខ្ញុំនឹងផ្តោតការកត់សម្គាល់របស់ខ្ញុំទៅលើឯកសារនានាដែលពាក់ព័ន្ធនឹងចំណុចទាំងឡាយ។

[១៥:៣៥:០៨]

ដូចសហភាគីរបស់ខ្ញុំលោក វ៉ិចទ័រ កូប៉េ ដែរ ការបង្ហាញរបស់ខ្ញុំនឹងមិនធ្វើការឆ្លើយតបទូលំទូលាយឡើយ។ ផ្ទុយទៅវិញខ្ញុំនឹងធ្វើការពន្យល់ត្រួសៗអំពីតួនាទីរបស់ នួនជា និងអត្ថាធិប្បាយមួយចំនួនអំពីភាពជឿជាក់បាននៃភស្តុតាងរបស់សហព្រះរាជអាជ្ញា និងថាភស្តុតាងគាំទ្របានកម្រិតណា។ ឬជាញឹកញយមិនបានគាំទ្រដល់ការអះអាងដ៏ទូលំទូលាយ និងមិនច្រើន -- និងមិនមានហេតុផលជាក់លាក់អំពីតួនាទីរបស់ នួន ជា ក្នុងកម្ពុជាប្រជាធិបតេយ្យឡើយ។

មុនខ្ញុំផ្តើមធ្វើការអត្ថាធិប្បាយទាំងនេះ អនុញ្ញាតឲ្យខ្ញុំនិយាយជាទូទៅ ត្រួសៗអំពីគុណភាពនៃភស្តុតាង ជាពិសេសទាក់ទងនឹងយថាភាពរបស់ឯកសារ។ អង្គជំនុំជម្រះនឹងនៅចាំថា កាលពីដំណាក់កាលដំបូងនៃការជំនុំជម្រះនេះលោក នួន ជា បានស្នើអង្គជំនុំជម្រះផ្តល់ឲ្យគាត់នូវសំណៅដើមរបស់ឯកសារនានា។ អង្គជំនុំជម្រះបានបដិសេធសំណើនោះ នៅពេល នួន ជា ស្នើសុំជាបន្តបន្ទាប់នូវសំណើដើម ហើយសំណើទាំងនោះត្រូវបានបដិសេធដែរ។ ទាំងសហព្រះរាជអាជ្ញានិង អង្គជំនុំជម្រះមិនបានយកចិត្តលើសំណើទាំងនេះទេ។ អង្គជំនុំជម្រះមិនដែលប៉ុនប៉ងផ្តល់ឲ្យ នួន ជា នូវឯកសារដើមតែមួយក៏គ្មានដែរ។ ផ្ទុយទៅវិញសំណើរបស់គាត់ត្រូវបានគេចាត់ទុកថាជាកិច្ចប្រឹងប្រែងមួយដើម្បីរាំងដំណើរការនីតិវិធី និងជ្រៀតជ្រែកកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះដើម្បីចេញការវិនិច្ឆ័យមួយឲ្យបានឆាប់តែប៉ុណ្ណោះ។

[១៥:៣៧:២៦]

លោកស្រី លោកចៅក្រម សំណើរបស់លោក នួន ជា មានហេតុផលត្រឹមត្រូវ។ថ្វីបើអង្គជំនុំជម្រះសម្រេចថាសច្ចធារណ៍នៃយថាភាពត្រូវអនុវត្តតែ បើពុំមានឯកសារដើម ឬទទួលបានសិទ្ធិ--

**ប្រធានអង្គជំនុំ៖**

លោក សុន អរុណ ផ្អាកបន្តិចសិនមានការជំទាស់ពីតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់ខ្ញុំនោះគឺថា នេះគឺជាបញ្ហានោះវាចូលទៅដល់និយាយអំពីការទទួលយកភស្តុតាង។ គាត់មិនបាននិយាយអំពីតម្លៃនៃភស្តុតាងទេ គាត់បានលើកសេចក្តីសន្និដ្ឋាន ហើយគាត់លើកឡើងជាយូរមកហើយ ប៉ុន្តែមានភស្តុតាងបញ្ជាក់គឺថាតុលាការទាំងឡាយនៅក្នុងពិភពលោកនេះប្រើច្បាប់ចម្លងដែលមានបញ្ជាក់ថាជាឯកសារអាចទទួលបាន។ ប៉ុន្តែមេធាវីបានលើក

បញ្ហាដែលគួរតែលើកឡើងយូរមកហើយ ហើយក៏មានការសម្រេចរួចមកហើយដែរ។ ដូច្នេះ ខ្ញុំសូមជំទាស់ចំពោះការអះអាងបែបនេះ។

[១៥:៣៨:៣៩]

**លោក សុន អរុណ៖**

ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំទៅព្រះរាជអាជ្ញា។ ការស្នើរបស់លោក នួន ជា រកឯកសារដើមតាំងពីមុនដំបូងមកដល់ថ្ងៃនេះ នួន ជា មិនដែលបានទទួលឯកសារដើមមួយ មកមើល មកប្រៀបធៀប ថាតើនេះជាឯកសារដើមដែលគាត់បានប្រើប្រាស់តាំងពីដើមមកទេ មិនដែលមានទេ។ ហើយខ្ញុំឡើងនិយាយនេះក្នុងចាប់ផ្តើមពីយថាភាពនៃចម្លើយទៅនឹងព្រះរាជអាជ្ញាដែលដាក់ឯកសារគន្លឹះមកនោះតិចទៀតនឹងដល់កន្លែងដែលព្រះរាជអាជ្ញាចង់បាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤០:៥៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកមានការចាប់អារម្មណ៍ថា នៅពេលនេះអង្គជំនុំជម្រះបានដាក់កំណត់កាលវិភាគសម្រាប់ធ្វើសវនាការ គឺដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ហើយភាគីខាងមេធាវីការពារក្តីបានបង្ហាញជំហរច្បាស់លាស់ហើយថា ខ្លួននឹងលើកឡើងនូវការកត់សម្គាល់ ឬក៏អត្ថាធិប្បាយជំទាស់ទៅនឹងបណ្តាឯកសារគន្លឹះ ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយចំណែកឯលោកដែលបានលើកឡើងអម្បាញ់មិញនេះ គឺទី១ គឺយថាភាពនៃឯកសារនេះ អង្គជំនុំជម្រះបានសម្រេចម្តងរួចហើយ។ បញ្ហានេះមិនអាចលើដូច្នេះបានទេ។ បញ្ហាទី២ តាមការបង្ហាញរបស់លោកនេះ គឺហាក់ដូចជាមានការមិនច្បាស់លាស់រវាងការកត់សម្គាល់ ឬក៏អត្ថាធិប្បាយលើបណ្តាឯកសារគន្លឹះដែលដាក់ឡើងដោយភាគីម្ខាងទៀតជាមួយនិងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ដូច្នេះ សូមលោករៀបចំនូវការធ្វើបទបង្ហាញរបស់លោកពាក់ព័ន្ធទៅនឹងអ្វីដែលអង្គជំនុំជម្រះបានដាក់ពេលវេលាជូន ហើយតាមសំណើសុំរបស់មេធាវីការពារក្តីដែលបានស្នើសុំនៅក្នុងកិច្ចប្រជុំរៀបចំសវនាការកន្លងមក។

សូមអញ្ជើញបន្ត!

[១៥:៤២:១៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្ថែម។ ខ្ញុំមិនសូមឲ្យមានការពិចារណាលើសេចក្ដីសម្រេចឡើងវិញនោះទេ។ ប៉ុន្តែតាមពិតខ្ញុំដឹងថា សហសេវិករបស់ខ្ញុំព្យាយាមអះអាងផ្ដល់នូវទទ្បីករណ៍ថ្ងៃនេះ គឺមិនមែនជាសេចក្ដីអះអាងទូទៅទេ។ ទូទៅនិយាយពីការទទួលយក ប៉ុន្តែគាត់លើកឡើងពីទទ្បីករណ៍ជាក់លាក់ទាក់ទងទៅនឹងឯកសារជាក់លាក់មួយចំនួនដែលលើកឡើងដោយសហព្រះ-រាជអាជ្ញា ដែលនិយាយអំពីតម្លៃជាភស្តុតាង។ បាទ មិននិយាយអំពីភាពទទួលយកបានទេ។ អ្វីដែលគាត់នឹងជម្រាបនោះ គឺឯកសារទាំងប្រាំនេះ ដែលបង្ហាញឡើងដោយសហព្រះរាជអាជ្ញាទៅជូនអង្គជំនុំជម្រះនោះ ដែលសហព្រះរាជអាជ្ញាអះអាងថា ដែលមានចំណារក្រហម គឺតាមពិតគឺជាចំណាររបស់កូនក្ដីយើងខ្ញុំនោះ។ ដូច្នេះមេធាវីជាតិលោក សុន អរុណ គាត់នឹងនិយាយអំពីបញ្ហានោះ គឺគាត់នឹងនិយាយអំពីតម្លៃជាភស្តុតាងនៃឯកសារប្រាំរបស់ស-២១នោះ ដោយហេតុថា សហព្រះរាជអាជ្ញាបានបដិសេធមិនបានបង្ហាញច្បាប់ដើមនូវឯកសារប្រាំនោះ ដែលមានអានុភាពផ្ទាល់ទៅលើបញ្ហាដែលទាក់ទងទៅនឹងតម្លៃជាភស្តុតាង។ ដូច្នេះ យើងខ្ញុំជាចាំបាច់មិនអះអាងអំពីយថាភាពដែលផ្សារភ្ជាប់ទៅនឹងភាពអាចទទួលយកបានទេ។ ប៉ុន្តែអ្វីដែលលោក នួន ជា បានបដិសេធនោះថា ជាចំណារ ឬជាហត្ថលេខារបស់គាត់នោះ នេះគឺមេធាវីជាតិគាត់នឹងលើកឡើងពីតម្លៃជាភស្តុតាងនៃឯកសារទាំងអស់នោះ។

[១៥:៤៤:១០]

នេះជាការល្អ ដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកមេធាវីគាត់លើកឡើងនូវអំណះអំណាងដែលថាបញ្ចប់នូវសេចក្ដីឆ្លើយតបរបស់គាត់។ យើងមិនលើកជាឯកសារទាំងអស់ទេ គឺមានតែឯកសារប្រាំទាំងអស់នោះទេដែលមានៗការអះអាងថា មានចំណាររបស់ជនជាប់ចោទនៅក្នុងខាងឆ្វេងដៃ។ នេះបញ្ហាបច្ចេកទេស គឺថាយើងអះអាងភាគច្រើន គឺនិយាយអំពីតម្លៃជភស្តុតាង មិនមែននិយាយជាសំខាន់ទៅលើភាពអាចទទួលយកបាននៃភស្តុតាងនោះទេ។ ដូច្នេះ សូមអនុញ្ញាតលោកប្រធាន លោកលោកស្រីចៅក្រម ឲ្យមេធាវីជាតិបានបញ្ចប់នូវទទ្បីករណ៍របស់មេធាវី សុន អរុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការជំទាស់ទេ តាមពិតនោះ បើសិនជាមេធាវីលើកឡើង

ពីបញ្ហាប្រាំនោះ។ ប៉ុន្តែយើងខ្ញុំព្អការ ទឡ្ហីករណ៍ទូទៅជំទាស់អំពីថាតើត្រូវយកច្បាប់ដើម ឬច្បាប់ចម្លង។ ខ្ញុំសូមកែតម្រូវ គឺថាលោកមេធាវីជាតិបានអះអាងថា សហព្រះរាជអាជ្ញាបានច្រានចោលមិនទទួល -- មិនព្រមបង្ហាញនូវឯកសារច្បាប់ដើម។ គឺមិនមែនសហព្រះរាជអាជ្ញាជាអ្នកមានច្បាប់ដើមទេ គឺសហចៅក្រមស៊ើបអង្កេតដែលប្រមូលបាន ហើយបានដាក់ច្បាប់ចម្លងនៅក្នុងសំណុំរឿង។ រីឯច្បាប់ចម្លងនេះឯងដែលភាគីអាចបើកមើលបាន។

[១៥:៤៥:៤៦]

និយាយអំពីឯកសារប្រាំនេះ គឺថាមានឯកសារនោះ គឺជាច្បាប់ចម្លង។ បើសិនជាមេធាវីការពារក្តីនៅតែចង់បានមើលឯកសារច្បាប់ដើម ឬក៏អាចស្នើទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជាទៅឡូលស្លែង គឺអាចស្នើសុំមើលបាន។ សាធារណជនគេអាចធ្វើដូច្នោះបាន។ ដូច្នេះហើយ ហើយការដែលមេធាវីអះអាងថា សហព្រះរាជអាជ្ញាមិនបង្ហាញ ឬក៏មិនឱ្យពួកគាត់មើលបាន នេះជាព័ត៌មានដែលមិនត្រឹមត្រូវទេ។ ដូច្នេះ គឺសហព្រះរាជអាជ្ញាមិនជំទាស់ទេ ប្រសិនបើជាមេធាវីចង់និយាយអំពីបញ្ហាលម្អិតនៅក្នុងឯកសារទាំងប្រាំនេះ យើងខ្ញុំមិនជំទាស់ទេ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីជាតិ លោក សុន អរុណ បញ្ជាក់ឱ្យច្បាស់។ ពីព្រោះលោកបានលើកឡើងមានលក្ខណ:ទូទៅ។ អម្បាញ់មិញនេះ គឺលោកលើកជាទូទៅតែម្តង។ វាខុសពីអ្វីដែលបានលើកឡើងបញ្ជាក់ដោយមេធាវីសហភាតារបស់លោក មេធាវី វ៉ិចទ័រ កូប៉េ ដែលបានលើកឡើងជាក់លាក់នូវចំពោះឯកសារចំនួនប្រាំ។ ចំពោះឯកសារចំនួនប្រាំនេះ គឺអង្គជំនុំជម្រះមិន -- តំណាងសហព្រះរាជអាជ្ញាក៏មិនជំទាស់ដែរ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែសូមលើកឡើងជាក់លាក់នូវការកត់សម្គាល់ ឬក៏អត្ថាធិប្បាយលើកបណ្តាឯកសារទាំងប្រាំនោះបានហើយ។ ជៀសវាងលោកលើកទូទៅ វាចូលទៅក្នុងរឿងដើម ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ។ ហើយទី២ គប្បីមានប្រយ័ត្នប្រយែងផងដែរ រវាងការកត់សម្គាល់ ឬអត្ថាធិប្បាយលើកឯកសារជំទាស់ទៅលើឯកសារគន្លឹះ ហើយទៅនឹងការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលប៉ុណ្ណឹងទេ។ សូមអញ្ជើញបន្ត!

[១៥:៤៧:៣៨]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានបានបំភ្លឺ ខ្ញុំនឹងបន្តទៅទៀត។ លោកស្រី លោកចៅក្រម សំណើ

របស់លោក នួន ជា មានហេតុផលត្រឹមត្រូវ។ ថ្វីបើអង្គជំនុំជម្រះសម្រេចថា សច្ចធារណ៍នៃយថាភាពត្រូវអនុវត្ត តែបើពុំមានឯកសារដើម ឬទទួលបានសិទ្ធិក្នុងការស៊ើបសួរ នួន ជា នឹងមិនមានឱកាសពិតប្រាកដដើម្បីតតាំងសច្ចធារណ៍នៃយថាភាពឡើយ។

យើងខ្ញុំស្នើសុំលោកស្រី លោកចៅក្រម កត់សម្គាល់ថា វាមានបញ្ហាច្បាប់ធ្ងន់ធ្ងរនៅជុំវិញប្រភពដើម ខ្សែសង្វាក់នៃការរក្សា និងយថាភាពរបស់ឯកសារនៅក្នុងសំណុំរឿង។ ឯកសារសម័យខ្មែរក្រហមភាគច្រើនត្រូវបានប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារទាំងនេះ ដែលត្រូវបានផ្តល់មកតុលាការនេះ មិនបានទុកនៅ អ.វ.ត.ក ទេ តែ--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដូចជាអត់អីផ្លាស់ប្តូរផង! អានោះទូទៅហើយលោកមេធាវី អំមិញគឺលោកមេធាវីអន្តរជាតិបានធ្វើអន្តរាគមន៍ គឺមានតែឯកសារជាក់លាក់ចំនួនប្រាំទេដែលពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខស-២១ ដែលមានចំណារបស់លោក នួន ជា ដែលបង្ហាញឡើងដោយសហព្រះរាជអាជ្ញាកន្លងមក។ អំមិញលោកបន្តទៀត លោកនៅតែបន្តនូវលក្ខណៈទូទៅដដែល បញ្ហានេះអង្គជំនុំជម្រះបានជម្រាបរួចហើយ ថាបានសម្រេចរួចហើយ។

[១៥:៤៩:២៧]

**លោក សុន អរុណ៖**

បើដូច្នេះ ខ្ញុំនឹងរំលងនូវសុន្ទរកថារបស់ខ្ញុំ ហើយខ្ញុំនឹងឆ្លងទៅដល់មុខងាររបស់លោក នួន ជា ដែលព្រះរាជអាជ្ញាបានលើកមកធ្វើជាឯកសារគន្លឹះ គឺមុខងារទី១ គឺនាយករដ្ឋមន្ត្រីស្តីទី។

ពេលនេះ ងាយទៅមើលតួនាទីជាក់លាក់របស់ នួន ជា វិញ។ ខ្ញុំសូមចាប់ផ្តើមដោយការពិភាក្សាអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញាថា នួន ជា ធ្លាប់ជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យរវាងខែកញ្ញា ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧។ លោកស្រី លោកចៅក្រម ខ្ញុំនឹងមិនចំណាយពេលវេលាច្រើនដើម្បីពិភាក្សាលើចំណុចនេះទេ ខ្ញុំគ្រាន់តែចង់លើកចំណុចខ្លីពីរ។

ទី១ ជាបឋម សហព្រះរាជអាជ្ញាមិនបានអះអាងថា ក្នុងតួនាទីនាយករដ្ឋមន្ត្រីស្តីទី នួន ជា មានការទទួលខុសត្រូវថ្មីណាមួយនោះទេ។ នៅដំណាក់កាលនេះ យើងមិនធ្វើការអត្ថាធិប្បាយអំពីតួនាទីជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យនោះទេ។ តែខ្ញុំចង់សង្កត់ធ្ងន់ថា ពុំមានការចោទប្រកាន់ពីសហព្រះរាជអាជ្ញាថានៅពេល នួន ជា ក្លាយជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជា ហើយថាតួនាទីរបស់គាត់បានធ្វើ

ឲ្យមានការផ្លាស់ប្តូរណាមួយពិតប្រាកដ។ ពុំមានការទំនាស់ -- ជំទាស់ (សូមទោស) ពុំមានការជំទាស់នៅទីនេះអំពីអំណាចជាក់លាក់របស់ នួន ជា។

[១៥:៥១:១៦]

ទី២ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះកត់សម្គាល់លើអង្គហេតុដែលថា នួន ជា មិនដែលជំទាស់អំពីតួនាទីរបស់គាត់ជាអនុលេខបក្សកុម្មុយនីស្តកម្ពុជា។ តាមពិតគាត់យល់ព្រម ហើយមោទនភាពថា គាត់កាន់កាប់តួនាទីនៃអំណាចនៅក្នុងឋានៈនុក្រមខ្មែរក្រហម តែគាត់ជំទាស់ដាច់ខាតថាគាត់ជានាយករដ្ឋមន្ត្រីស្តីទី គាត់ពិតជាមិនអាចនឹកឃើញអំពីរឿងហ្នឹងទេ។ លោកស្រី លោកចៅក្រម! នៅក្នុងទស្សនៈរបស់ខ្ញុំវាមានការទទួលខុសត្រូវ ព្រោះមិនទាន់តិចបំផុតដែលអាស្រ័យថាតើ នួន ជា ធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទីដែរឬទេ? សម្រាប់មូលហេតុនេះ ខ្ញុំនឹងមិនចំណាយពេលដ៏មានតម្លៃនេះដើម្បីជំទាស់ដែរ។ តែសម្រាប់មូលហេតុនេះ យើងខ្ញុំស្នើអង្គជំនុំជម្រះយល់ថា នួន ជា មិនមានហេតុផលកុហក់អំពីតួនាទីរបស់គាត់ឡើយ។

[១៥:៥២:៣២]

បន្ទាប់ទៅនេះ ខ្ញុំសូមនិយាយអំពីកិច្ចការដែលព្រះរាជអាជ្ញាលើកនៅក្នុងឯកសារគន្លឹះអំពីកិច្ចការយោធា និងសន្តិសុខ។

លោកប្រធាន ពេលនេះខ្ញុំនឹងផ្តោតទៅលើតួនាទីតាមការសង្កត់ -- សន្មត (សុំទោស) តាមការសន្មតរបស់នួន ជា ក្នុងកិច្ចការយោធា និងសន្តិសុខ។ ភស្តុតាងចម្បងរបស់សហព្រះរាជអាជ្ញាដែលថា នួន ជា មានតួនាទីក្នុងកិច្ចការយោធា និងសន្តិសុខ គឺផ្អែកលើសារទូរលេខមួយចំនួន។ អនុលោមតាមសហព្រះរាជអាជ្ញា សារទូរលេខទាំងនេះបង្ហាញថា នួន ជា មានតួនាទីក្នុងកិច្ចការយោធា និងសន្តិសុខ។ តាមពិតសាទូរលេខទាំងនេះបង្ហាញថា នួន ជា ក៏ជាមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតរបស់កម្ពុជាប្រជា-ធិបតេយ្យ អាចជាម្តងកាលទទួលព័ត៌មានអំពីប្រតិបត្តិការយោធា។ មិនមានអ្វីទាល់តែសោះ នៅក្នុងសារទូរលេខទាំងនេះបញ្ជាក់អំពីតួនាទីក្នុងកម្ពុជាប្រជាធិបតេយ្យ អំពីការទទួលខុសត្រូវយោធា និងសន្តិសុខឡើយ។ យើងបានត្រួតពិនិត្យសារទូរលេខទាំង១៥ ដែលសហព្រះរាជអាជ្ញានិយាយថា មានបង្ហាញអំពីតួនាទី នួន ជា ក្នុងកិច្ចយោធា និងសន្តិសុខ។

[១៥:៥៤:១១]

ដោយសារជាបញ្ហាបឋម វាហាក់ដូចជាថាលេខឯកសារចំនួនប្រាំដែលផ្តល់ដោយសហព្រះរាជ

អាជ្ញាអាចមានកំហុស។ លេខឯកសារមិនឆ្លើយតបទៅនឹងខ្លឹមសាររបស់ឯកសារ។ ឯកសារដែលសហព្រះរាជអាជ្ញាផ្តល់មានដូចជា E3/1112, E3/1123 -- សូមទោសម្តងទៀត ដូចជា មានដូចជា E3/1122, E3/1123, E3/1124, E3/1125 និងE3/1126។ យើងគិតថាលេខរបស់ឯកសារគួរតែជាលេខ E3/1222 រហូតដល់លេខ E3/1226។ វាគួរតែចាប់ផ្តើមពីលេខ 12 មិនមែន 11 ទេ។ យើងស្នើសហព្រះរាជអាជ្ញាឲ្យត្រួតពិនិត្យលេខឯកសារឡើងវិញនៅពេលនេះ។ ដោយសារពុំមានពេលវេលាគ្រប់គ្រាន់ យើងនឹងពិនិត្យឯកសារនីមួយៗនោះទេ។ ខ្ញុំនឹងអានជូនអង្គជំនុំជម្រះឲ្យបានឆាប់។ លេខឯកសារដែលត្រឹមត្រូវមានដូចតទៅ៖ E3/1222, E3/1223, E3/1224, E3/1225, E3/1226, E3/1235, E3/892, E3/1154, E3/181, E3/867, E3/519, E3/1144, E3/1077, E3/1008 និង E3/156។

[១៥:៥៦:៣៦]

លោកប្រធាន! ថាតើមានអ្វីដូចគ្នានៅក្នុងសារទូរលេខទាំងនេះ? មានបញ្ហាសំខាន់ពីរ ជាបឋមសារទូរលេខទាំងនេះកើតឡើងនៅរយៈពេលចុងក្រោយនៃកម្ពុជាប្រជាធិបតេយ្យ។ សារទូរលេខមួយក្រុមមានសារទូរលេខកើតឡើងរវាងខែតុលា ឆ្នាំ១៩៧៦។ ខ្លឹមសាររបស់វា -- ខ្លឹមសាររបស់សារទូរលេខទាំងប្រាំ ទាំងប្រាំមួយនេះទាក់ទងនឹងប្រធានបទដូចតទៅ -- ដូចៗគ្នា។ សារទូរលេខប្រាំមួយផ្សេងទៀតកើតឡើងក្នុងរយៈពេលដូចគ្នា គឺក្រោយខែកុម្ភៈ ឆ្នាំ១៩៧៨។ អង្គហេតុនេះគឺមានសារៈសំខាន់សម្រាប់គោលបំណងនៃការជំនុំជម្រះនេះ។ បទល្មើសភាគច្រើនដែលត្រូវចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះត្រូវបានគេសន្មតថា បានកើតឡើងនៅខែមេសា ឆ្នាំ១៩៧៥ បទល្មើសផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី២ កើតឡើងនៅចុងឆ្នាំ១៩៧៥ និង ៧៦ ឥឡូវនេះដោយសារមេធាវីការពារ នួន ជា បានលើកឡើងថា ច្រើនដងមកហើយភស្តុតាងបង្ហាញថានៅខែមេសា ឆ្នាំ១៩៧៥ មជ្ឈិមបក្សមិនមានកងទ័ពខ្លួនឯងទេ សូម្បីសហព្រះរាជអាជ្ញាអះអាងថា ប៉ុល ពត ទើបតែចាប់ផ្តើមបង្រួបបង្រួមកងទ័ពនៅខែកក្កដា ឆ្នាំ១៩៧៥ ប៉ុណ្ណោះ។ ភស្តុតាងបង្ហាញថាដំណើរការបង្រួបបង្រួមកងទ័ពប្រព្រឹត្តទៅដោយសន្សឹមៗ ហើយមិនដែលធ្វើបានទាំងស្រុងទេ។

អង្គជំនុំជម្រះគប្បីពិនិត្យមើលទៅលើអង្គហេតុដែលថា សហព្រះរាជអាជ្ញាមិនអាចរកបានសូម្បីឯកសារតែមួយដែលបង្ហាញពីតួនាទីរបស់ នួន ជា ក្នុងកិច្ចការយោធានៅមុនខែតុលា ឆ្នាំ១៩៧៦ គឺរយៈពេលជាងមួយឆ្នាំ ក្រោយការបង្កើតកងពលធំនានារបស់មជ្ឈិម។

[១៥:៥៩:០៩]

ឯកសាររបស់សហព្រះរាជអាជ្ញាមិនពាក់ព័ន្ធតួនាទីរបស់ នួន ជា ក្នុងកិច្ចការយោធានៅឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៦ ទេ។ អង្គជំនុំជម្រះគប្បីយល់ថាពុំមានភស្តុតាងណាដែលបង្ហាញថា នួន ជាមានតួនាទីក្នុងកិច្ចយោធា -- កិច្ចការយោធានៅក្នុងយុត្តាធិការពេលវេលានៃការជំនុំជម្រះនេះឡើយ។

បើទោះបី នួន ជា ម្តងម្កាលបានទទួលព័ត៌មានពីប្រតិបត្តិការយោធានៅចុងឆ្នាំ១៩៧៦ ក៏មិនអាចបង្ហាញអំពីតួនាទីរបស់គាត់ក្នុងកិច្ចការយោធា ឬសន្តិសុខនៅពេលនោះដែរ។ សារទូរលេខភាគច្រើនដែលបង្ហាញដោយសហព្រះរាជអាជ្ញា បង្ហាញតែពីការធ្វើបច្ចុប្បន្នភាពមកមជ្ឈិមបក្ស អំពីការធ្វើសង្គ្រាមរបស់ប្រទេសកម្ពុជាជាមួយវៀតណាមប៉ុណ្ណោះ។

អង្គជំនុំជម្រះនេះ រកឃើញនៅក្នុងសាលក្រម ឌុច ថាជាជម្លោះប្រដាប់អាវុធអន្តរជាតិមួយបានកើតឡើងរវាងកម្ពុជា និងវៀតណាម ចាប់តាំងពីការផ្តើមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរហូតទល់នឹងការបញ្ចប់របបនេះ។ ការឈ្លានពានទ្រង់ទ្រាយធំពីរកើតឡើងក្នុងអំឡុងឆ្នាំ១៩៧៧ នៅក្រោមកាលៈទេសៈនេះ តើសហព្រះរាជអាជ្ញាបង្ហាញ នួន ជា ដែលត្រូវចោទប្រកាន់ថាជាមនុស្សមានអំណាចទី២របស់ប្រទេស បញ្ជាកងទ័ពនៅសមរភូមិនោះមិនពិតទេ។ តើពួកគេបង្ហាញគាត់បានធ្វើផែនការយុទ្ធ-សាស្ត្រសឹកយ៉ាងប្រយ័ត្នប្រយែងនោះក៏មិនពិតដែរ។ តើពួកគេបង្ហាញថាគាត់ចេញបញ្ជាទៅមេបញ្ជាការកងទ័ពនោះក៏រឹតតែមិនពិតទៅទៀត។

[១៦:០១:២០]

សារទូរលេខទាំងនេះបង្ហាញថា អំឡុងពេល១៩ខែ នួន ជា បានទទួលការធ្វើបច្ចុប្បន្នភាពកម្រាស់បីទំព័រ ដែលរៀបរាប់យ៉ាងស្រពិចស្រពិលអំពីស្ថានភាពនៅព្រំដែន។ ពុំមានភស្តុតាងណាដែលបង្ហាញថា នួន ជា ស្នើសុំឱ្យបញ្ជូនមកគាត់នូវរបាយការណ៍ទាំងនោះដែរ។ មិនមានភស្តុតាងច្បាស់លាស់ដែលបង្ហាញថាគាត់បានទទួលរបាយការណ៍បែបនេះដែរ ហើយក៏មិនមានភស្តុតាងដែលថាគាត់បានចាត់វិធានការដើម្បីឆ្លើយតបទៅនឹងរបាយការណ៍បែបនេះក៏អត់ទេដែរ។

សហព្រះរាជអាជ្ញាជោគជ័យក្នុងការបង្ហាញចរិតលក្ខណៈនៃតួនាទីរបស់ នួន ជា ក្នុងកិច្ចការយោធា និងសន្តិសុខ ប្រហែលជាមិនមែនតួនាទីដែលពួកគេមានបំណងយោងនោះទេ។ លោកប្រធានអនុញ្ញាតឱ្យខ្ញុំលើកចំណុចចុងក្រោយអំពីសារទូរលេខទាំងនេះ។ សហព្រះរាជអាជ្ញាលើកឡើងកាលពីសប្តាហ៍កន្លងមកថា ឯកសារទាំងនេះបង្ហាញតួនាទីរបស់ នួន ជា ទាក់ទងនឹងសន្តិសុខផ្ទៃក្នុង និងវិន័យ

កម្មាភិបាល។ លោកស្រី លោក ចៅក្រម វាជាការពិតដែលថាអាចមានសារទូរលេខបួន ឬប្រាំដែលពិពណ៌នាខ្លីៗអំពីបញ្ហាសន្តិសុខផ្ទៃក្នុង។ ខ្ញុំគិតថាប្រសិនបើលោក លោកស្រីចៅក្រមពិនិត្យសារទូរលេខនេះ លោក លោកស្រីចៅក្រមនឹងយល់ថា សារទូរលេខទាំងនេះទាក់ទងជាចម្បងតែយុទ្ធការយោធាទេ។ សារទូរលេខនេះអាចមានព័ត៌មានខ្លះអំពីវិន័យបក្ស។ ប៉ុន្តែវាច្បាស់លាស់ណាស់សារទូរលេខទាំងនេះ គឺគ្រាន់តែផ្តល់ដំណឹងមកមជ្ឈិមបក្សអំពីបច្ចុប្បន្នភាពនៃយោធាប៉ុណ្ណោះ។

[១៦:០៣:៤៨]

មានតែករណីលើកលែងមួយទេ គឺឯកសារ E3/1154 ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង ឯកសារនេះហាក់បីដូចជាលិខិតមួយមកពីកម្មាភិបាលម្នាក់ដែលស្វែងរកការអភ័យទោស។ បើសិនលោក លោកស្រីចៅក្រមអានប្រយោគដំបូងនៃឯកសារនេះ វាមានន័យថា "ជាបឋមខ្ញុំសូមបងអធ្យាស្រ័យចំពោះការខុសឆ្គងដែលខ្ញុំបានសរសេរសំបុត្រខុសលក្ខខណ្ឌចាត់តាំងជូនបងផ្ទាល់"។ នេះជាសាររបស់អ្នកផ្ញើមក។ ហេតុដូច្នេះ ឯកសារនេះបង្ហាញពីភាពផ្ទុយ ពីអ្វីដែលសហព្រះរាជអាជ្ញាលើកឡើង។ ឯកសារនេះបង្ហាញថា បញ្ហាវិន័យផ្ទៃក្នុងមិនស្ថិតនៅក្រោមការទទួលខុសត្រូវធម្មតារបស់ នួន ជា ទេ។ លោកស្រី លោក ចៅក្រម! ភស្តុតាងតែមួយគត់ផ្សេងទៀតដែលសហព្រះរាជអាជ្ញាផ្អែកដើម្បីបង្ហាញតួនាទីរបស់ នួន ជា ក្នុងកិច្ចការយោធា និងសន្តិសុខ គឺការថ្លែងរបស់គាត់នៅសៀវភៅ និងវីដេអូ របស់ ថេត សម្បត្តិ។ លោក កូប៉េ បានអត្ថាធិប្បាយលើភស្តុតាងនោះរួចហើយ។ ការអត្ថាធិប្បាយរបស់គាត់ក៏អនុវត្តដូចគ្នានៅទីនេះដែរ។

[១៦:០៥:២០៨]

សម្រាប់មូលហេតុទាំងអស់លោក លោកស្រី លោកចៅក្រម ភស្តុតាងបង្ហាញឲ្យច្បាស់ថា នួន ជា មិនមានតួនាទីណាមួយជាដុំកំភួនទាំងក្នុងកិច្ចការយោធា និងសន្តិសុខនោះទេ។

ខ្ញុំចូលទៅក្នុងវគ្គមួយទៀត គឺមន្ទីរស-២១--

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ឥឡូវនេះដល់ពេលសម្រាកហើយ ហើយទំនងនៅវែងដែរទេ ព្រោះលោកត្រូវប្រើប្រាស់ពេលវេលាមួយៗ ប្រហែលជាពាក់--

**លោក សុន អរុណ៖**

ប្រហែលជាមួយម៉ោង។

**ប្រធានអង្គជំនុំ៖**

--មួយម៉ោងទៀត ដូចនៅវែងដែរ។ អ៊ីចឹងគឺគប្បីបន្តទៅធ្វើនៅថ្ងៃស្អែកណ៎ះលោកមេធាវីបាទ។

បាទ អរគុណលោកមេធាវី។ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកថ្ងៃអង្គារ ទី០៩ ខែកក្កដា ឆ្នាំ២០១៣ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការស្អែក នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការលើភស្តុតាង គឺការដាក់ឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ ដោយការស្តាប់នូវការកត់សម្គាល់ ឬអត្ថាធិប្បាយជំទាស់ដោយក្រុមមេធាវីការពារក្តី នួន ជា ហើយជនជាប់ចោទ នួន ជា និងក្រុមមេធាវីការពារក្តី ខៀវ សំផន ជនជាប់ចោទ ខៀវ សំផន លើបណ្តាឯកសារគន្លឹះដែលបានដាក់បង្ហាញនូវចំពោះមុខអង្គជំនុំជម្រះរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅសវនាការកាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ និងសហសវនាការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកន្លងមក។ សូមភាគីនៃរឿងក្តី មន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឱ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*